**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale da Droit et des Sciences Economiques**

**Royal University of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# លំហូរនីតិវិធី
# នៃការជំនុំជម្រះក្តីលើកទី១

ស្រាវជ្រាវពីថ្ងៃទី ២៧ មេសា ឆ្នាំ២០២១ ដល់ថ្ងៃទី ២៥ មិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **តាំង ឆៃហេង**

**ឡុង ឈុនហ្វា**

សាស្ត្រាចារ្យណែនាំ

លោក **ទេព សុខ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំបាទឈ្មោះ **តាំង នៃហេង** និងខ្ញុំបាទ **ឡុង ឈុនហ្វា** ជានិស្សិត ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២១ ឆ្នាំសិក្សា ២០១៧-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមថ្លែងនូវកតញ្ញូតាធម៌ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

លោកឪពុក **តាំង ណាំព្រែក** និងអ្នកម្តាយ **ស្រ៊ុន គាង** និងលោកឪពុក **ឡុង ពិសិដ្ឋ** និងអ្នកម្តាយ **លី គីមហៀង** ដែលលោកទាំងទ្វេរបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា អប់រំ និងផ្តល់ដំបូន្មានល្អៗ ប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងហ៊ានលះបង់ទាំងកម្លាំងកាយចិត្ត លះបង់គ្រប់យ៉ាងដើម្បីឱ្យកូនបានសិក្សា ក្រេបជញ្ជក់យកចំណេះដឹង និងទំនុកបម្រុងគ្រប់សព្វបែបយ៉ាងដល់រូបកូន ទាំងផ្នែកស្មារតី និងសម្ភារៈរហូតដល់ តាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ ក្នុងគោលបំណងចង់ឱ្យរូបកូនក្លាយជា បញ្ញាជនមួយរូប ដែលអាចជាកម្លាំងចលករក្នុងការជួយលើកស្ទួយដល់សង្គមជាតិយើង។ ក្នុងនាមពួកយើងខ្ញុំ ជាកូនៗគ្មានអ្វីតបស្នងដើម្បីឱ្យសាកសមនោះទេ គឺមានតែការខិតខំប្រឹងប្រែងសិក្សារៀនសូត្រ ឱ្យអស់ពីកម្លាំង កាយចិត្ត ដើម្បីកុំឱ្យកម្លាំងញើសឈាម ដែលលោកអ្នកមានគុណទាំងទ្វេរ បានចំណាយរសាត់បាត់បង់ដោយ ឥតន័យ។ ទន្ទឹមនឹងនេះកូនៗសង្ឃឹមថាលោកទាំងទ្វេរនឹងសប្បាយចិត្ត និងមានមោទនភាពលើលទ្ធផលដែល កូនៗបានខិតខំប្រឹងប្រែងអស់រយៈពេលជាច្រើនឆ្នាំកន្លែងមកនេះ។

**ឯកឧត្តម លុយ ចន្ណា** និងសាស្ត្រចារ្យ ទាំងអស់នៃសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយបង្ហាត់បង្ហាញ តាមរយៈការបង្រៀនយ៉ាងយកចិត្តទុកដាក់ និងអស់ពីកម្លាំងកាយចិត្តដល់ពួកខ្ញុំបាទ រយៈពេល ៤ ឆ្នាំកន្លងមកនេះ។

លោកសាស្ត្រាចារ្យ **ទេព សុខ** ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ ណែនាំ បង្ហាត់បង្ហាញ ពន្យល់ រំលឹក កែតម្រូវ ព្រមទាំងបង្កភាពងាយស្រួលដល់ការតម្រង់ទិសក្នុងការសរសេរសារណា នេះឡើង។

ជាចុងក្រោយ យើងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តសិទ្ធិផងទាំងពួងដែលមាននៅលើលោកនេះឱ្យជួយតាម ថែរក្សាអស់លោកអ្នកមានគុណទាំងឡាយឱ្យជួបតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់ពេលវេលាកុំបីឃ្លាងឃ្លាត ឡើយ ៕

# អារម្ភកថា

ក្រោយពីបានឆ្លងកាត់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ អស់រយៈពេល០៤ឆ្នាំ នៅសាលាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នូវមុខវិជ្ជាជាច្រើនដែលទាក់ទងនឹងវិស័យច្បាប់នៅក្នុងប្រទេសកម្ពុជា ហើយជាពិសេសទាក់ទងនឹង **ក្រមរដ្ឋប្បវេណី** និង **ក្រមនីតិវិធីរដ្ឋប្បវេណី** ដែលធ្វើឱ្យយើងខ្ញុំទាំងពីរបានទទួលចំណេះដឹងយ៉ាងទូលំទូលាយ ប្រកបដោយភាពច្បាស់លាស់ ក្រោមការយកចិត្តទុកដាក់ពីសំណាក លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ នានា។ ដោយមានការជ្រោមជ្រែង និងការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់ក្នុងការបង្ហាត់បង្រៀនអស់ពីកម្លាំងកាយចិត្តទាំងអស់នេះហើយ ទើបធ្វើឱ្យយើងខ្ញុំអាចឈានមកដល់ការចងក្រងសារណាថ្នាក់បរិញ្ញាបត្រជំនាន់ទី២១ និងដើម្បីចូលរួមចំណែកក្នុងការចែករំលែកចំណេះដឹងមួយចំនួនដល់និស្សិតជំនាន់ក្រោយផង។

ក្នុងការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ យើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយដែលទាក់ទងយ៉ាងច្រើនលើសលប់ទៅនឹងក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានប្រធានបទ "លំហូរនីតិវិធីនៃការជំនុំជម្រះក្តីលើកទី១" ។ ការជ្រើសរើសប្រធានបទនេះឡើងមក គឺដើម្បីឱ្យនិស្សិតផ្នែកនីតិសាស្ត្រឆ្នាំទី៤ គ្រប់រូប យល់ដឹងកាន់តែច្បាស់អំពីលំហូរនីតិវិធីនៃការដោះស្រាយវិវាទរដ្ឋប្បវេណី តាមរយៈប្រព័ន្ធតុលាការ។

យើងខ្ញុំសង្ឃឹមថា សារណានេះនឹងអាចជាឯកសារជំនួយសារតី និងជាឯកសារសម្រាប់សិក្សាស្រាវជ្រាវរបស់មិត្តនិស្សិត ជាពិសេសគឺនិស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ពីព្រោះពួកគាត់កំពុងសិក្សាលើមុខវិជ្ជា នីតិវិធីរដ្ឋប្បវេណីនេះស្រាប់ ហើយលើសពីនេះទៅទៀតយើងខ្ញុំចង់បន្សល់ទុកនូវស្នាដៃមួយសម្រាប់ជាការចងចាំមួយដែលមិនអាចបំភ្លេចបាន ដែលយើងខ្ញុំក៏ធ្លាប់ជាអតីតនិស្សិតនៅសាលាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះផងដែរ។

យើងខ្ញុំ ក៏សូមអភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គងទាំងឡាយដោយប្រការណាមួយដោយអចេតនា នូវពាក្យពេចន៍ ក៏ដូចជាអក្ខរាវិរុទ្ធទាំងឡាយដែលមាននៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ ហើយយើងខ្ញុំនឹងទទួលស្វាគមន៍ជានិច្ចនូវរាល់ការរិះគន់ក្នុងន័យស្ថាបនានូវចំណេះដឹងរបស់យើងខ្ញុំ ដើម្បីបំពេញចំណុចខ្វះខាតទាំងនោះឱ្យមកជាល្អគ្រប់ជ្រុងជ្រោយវិញ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១

## សញ្ញាណទូទៅនៃនីតិវិធីរដ្ឋប្បវេណី

**១.១ គោលបំណងនៃប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី** ........ ៤

**១.២ គោលការណ៍មូលដ្ឋានសំខាន់ៗនៅក្នុងនីតិវិធីរដ្ឋប្បវេណី** ........ ៥

១.២.១ គោលការណ៍មូលដ្ឋាននៃនីតិវិធីរដ្ឋប្បវេណី ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ........ ៥

១.២.១.១ ឯករាជ្យភាពនៃអំណាចតុលាការ និង ការធានាក្នុងមុខងាររបស់ចៅក្រម ........ ៥

១.២.១.២ គោលការណ៍នៃការជម្រះក្តីតាមច្បាប់ ........ ៥

១.២.២ ការធានានូវសិទ្ធិទាមទារសវនាការ ........ ៥

១.២.៣ គោលការណ៍ចំពោះមុខ ........ ៦

១.២.៤ ការទទួលខុសត្រូវរបស់តុលាការ និង ភាគី ........ ៧

១.២.៥ ភាសាដែលប្រើក្នុងតុលាការ សិទ្ធិរបស់ភាគីក្នុងការស្នើសុំឱ្យមានអ្នកបកប្រែ ........ ៧

១.២.៦ ការចូលរួមរបស់តំណាងអយ្យការ ........ ៧

១.២.៧ គោលការណ៍ផ្សេងៗទៀតនៃការជម្រះក្តី ........ ៨

## ជំពូកទី២

## នីតិវិធីមុនពេលសវនាការ

**២.១ ការដាក់ពាក្យបណ្តឹង** ........ ៩

២.១.១ អត្ថន័យនៃពាក្យបណ្តឹង ........ ៩

២.១.២ របៀបដាក់ពាក្យបណ្តឹង ........ ៩

២.១.៣ ប្រភេទនៃបណ្តឹង ........ ១០

២.១.៣.១ បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក ........ ១០

២.១.៣.២ បណ្តឹងទាមទារឱ្យបញ្ជាក់ ........ ១១

២.១.៣.៣ បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ........ ១២

២.១.៤ ការចាត់ចែងពាក្យបណ្តឹង ........ ១៣

២.១.៤.១ ការទទួលពាក្យបណ្តឹង ........ ១៣

២.១.៤.២ ការពិនិត្យពាក្យបណ្ដឹង ........ ១៤
២.១.៤.៣ ការបញ្ជូនពាក្យបណ្ដឹង ........ ១៥
២.១.៤.៤ ការកំណត់កាលបរិច្ឆេទដំបូងនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល និង ការកោះហៅភាគី... ១៦
**២.២ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ........ ១៧
២.២.១ គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ១៧
២.២.២ ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ១៨
២.២.២.១ ការសាកល្បងផ្សះផ្សា ........ ១៨
២.២.២.២ ការរៀបចំការអះអាងរបស់គូភាគី ........ ១៩
២.២.២.៣ ការកំណត់ចំណុចវិវាទ ........ ២០
២.២.២.៤ ការរៀបចំនូវភស្តុតាង ........ ២២
២.២.៣ ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ២៣
២.២.៣.១ ការបញ្ជាក់នូវអង្គហេតុដែលត្រូវបំភ្លឺ ........ ២៣
២.២.៣.២ ការកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ........ ២៣
២.២.៣.៣ អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ២៣

## ជំពូកទី៣

## នីតិវិធីក្នុងពេលសវនាការ

**៣.១ នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់** ........ ២៤
៣.១.១ អត្ថន័យនៃការទាញហេតុផលដោយផ្ទាល់មាត់ ........ ២៤
៣.១.២ ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់ ........ ២៤
៣.១.៣ ដំណើរការក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ........ ២៥
៣.១.៣.១ សេចក្ដីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ........ ២៥
៣.១.៣.២ ការពិនិត្យភស្តុតាង ........ ២៦
៣.១.៣.២.១ ការសាកសួរសាក្សី ........ ២៦
៣.១.៣.២.២ ការសាកសួរសាមីភាគី ........ ២៧
៣.១.៣.២.៣ កោសលវិច័យ ........ ២៨
៣.១.៣.២.៣ ភស្តុតាងជាឯកសារ ........ ២៨
៣.១.៣.២.៤ ការត្រួតពិនិត្យ ........ ២៨
៣.១.៣.៣ ការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន ........ ២៩

៣.១.៣.៤ ការបំបែក និង ការបញ្ចូលសំណុំរឿង........................................................................ ៣០
៣.១.៣.៥  ការបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់.................................................................. ៣០
**៣.២ ការប្រកាសសាលក្រម**.............................................................................................. ៣០
៣.២.១ អត្ថន័យនៃសាលក្រមចុងក្រោយ.............................................................................. ៣០
៣.២.២ ប្រភេទនៃសាលក្រមចុងក្រោយ................................................................................ ៣១
៣.២.៣ ការបង្កើតសាលក្រម ................................................................................................ ៣១
៣.២.៣.១ ការបង្កើតខ្លឹមសារនៃសាលក្រម.......................................................................... ៣១
៣.២.៣.២ ការបង្កើតលិខិតសាលក្រម.................................................................................. ៣២
៣.២.៤ របៀបនៃការប្រកាសសាលក្រម ................................................................................. ៣៣
**សេចក្តីសន្និដ្ឋាន**................................................................................................................ ៣៥
**អនុសាសន៍** ....................................................................................................................... ៣៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ក្រមនីតិវិធីរដ្ឋប្បវេណី គឺជាបទដ្ឋានមួយដែលកំណត់អំពីបែបបទដែលតុលាការ ក៏ដូចជាភាគី នៃរឿងក្តីត្រូវប្រតិបត្តិតាមនៅក្នុងដំណើរការនៃការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណី ដើម្បីឱ្យការដោះស្រាយវិវាទមានភាពឆាប់រហ័ស និងទទួលបានយុត្តិធម៌ដល់គូភាគី។ នៅក្នុងការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណី ភាគីនៃវិវាទមានជម្រើសជាច្រើនក្នុងការដោះស្រាយ ពោលគឺភាគីអាចធ្វើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ឬក៏ធ្វើការដោះស្រាយវិវាទតាមរយៈប្រព័ន្ធតុលាការ ដែលជាការដោះស្រាយវិវាទដោយបង្ខំ។ ជាទូទៅក្នុងករណីដែលមានវិវាទរដ្ឋប្បវេណីកើតមានឡើង ភាគីមានស្វ័យភាពក្នុងការជ្រើសរើស នូវវិធីក្នុងការដោះស្រាយវិវាទដែលបានកើតមាននោះ។ ក្នុងករណីខ្លះភាគីទាំងសងខាង អាចធ្វើការបញ្ចប់វិវាទដែលបានកើតមាននោះនៅក្រៅប្រព័ន្ធតុលាការបានតាមរយៈការចរចាគ្នាជាដើម ក៏ប៉ុន្តែមានករណីខ្លះការចរចាគ្នាក្រៅប្រព័ន្ធតុលាការមិនអាចធ្វើទៅបាននោះទេ ដូចនេះ ភាគីអាចជ្រើសរើសការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការបាន ។

ដោយហេតុថា ការដោះស្រាយវិវាទតាមរយៈប្រព័ន្ធតុលាការមានលក្ខណៈស្មុគស្មាញ ដែលតម្រូវឱ្យភាគីមានការយល់ដឹងផ្នែកច្បាប់ច្រើន ទើបក្នុងពេលដោះស្រាយវិវាទរដ្ឋប្បវេណីតាមរយៈប្រព័ន្ធតុលាការ ចៅក្រម ក្រឡាបញ្ជី មេធាវី និងភាគី ត្រូវគោរពតាមវិធាននៃក្រមនីតិវិធីរដ្ឋប្បវេណីឱ្យបានល្អ។ ដោយឃើញនូវចំណុចទាំងអស់នេះហើយ ទើបយើងខ្ញុំសម្រេចជ្រើសរើសយក លំហូរនីតិវិធីនៃការជំនុំជម្រះក្តីលើកទី១ នេះមកធ្វើជាប្រធានបទសារណាដើម្បីបកស្រាយក្នុងគោលបំណង បង្ហាញឱ្យឃើញពីសារៈសំខាន់នៃ លំហូរនីតិវិធីនៃការដោះស្រាយរឿងក្តីរដ្ឋប្បវេណី ដែលធ្វើឡើងនៅតាមបណ្តាសាលាដំបូងរាជធានី-ខេត្ត។

ដើម្បីធ្វើការសិក្សាឱ្យបានស៊ីជម្រៅ និង មានភាពកាន់តែច្បាស់លាស់ទៅលើប្រធានបទសារណាខាងលើនេះ យើងខ្ញុំបានលើកឡើងនូវចំណោទបញ្ហាគតិយុត្តមួយចំនួន យកមកធ្វើការដោះស្រាយ ដែលចំណោទបញ្ហាគតិយុត្តនោះរួមមាន៖ បន្ទាប់ពីដើមចោទបានដាក់ពាក្យបណ្តឹងចំពោះចុងចម្លើយនៅឯសាលាដំបូងរាជធានី-ខេត្ត តើភាគីត្រូវធ្វើអ្វីខ្លះ? ហើយចាប់តាំងពីការដាក់ពាក្យបណ្តឹងរបស់ដើមចោទ រហូតដល់ទទួលបានសាលក្រម មានដំណើរការយ៉ាងដូចម្តេច?

ដើម្បីជាបច្ច័យដល់និស្សិតផ្នែកនីតិសាស្ត្រឆ្នាំទី៤កំពុងតែសិក្សាមុខវិជ្ជានីតិវិធីរដ្ឋប្បវេណីផង និងជាអនាគត ចៅក្រម មេធាវី ក្រឡាបញ្ជី ហើយក៏អាចជាភាគីនៅក្នុងតុលាការផងដែរនោះ ទើបពួកយើងខ្ញុំបាទជ្រើសរើសយកប្រធានបទ លំហូរនីតិវិធីនៃការជំនុំជម្រះក្តីលើកទី១ នេះឡើងដើម្បីជាប្រទីបបំភ្លឺផ្លូវដល់និស្សិតទូទៅ និងជាពិសេសចំពោះនិស្សិតផ្នែកនីតិសាស្ត្រ យល់កាន់តែច្បាស់នូវនីតិវិធីនៃការជំនុំជម្រះរឿងក្តីរដ្ឋប្បវេណី តាមរយៈប្រព័ន្ធតុលាការ។

ដោយសង្កេតឃើញថា នៅក្នុងការដោះស្រាយរឿងក្តីរដ្ឋប្បវេណីមាននីតិវិធីជាច្រើនដែលចៅក្រមត្រូវយកមកប្រើប្រាស់ក្នុងការដោះស្រាយទៅលើប្រភេទនៃរឿងក្តី ដោយក្នុងនោះយើងសង្កេតឃើញមានដូចជា៖ នីតិវិធីបណ្តឹង នីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និងនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលជាដើម មិនតែប៉ុណ្ណោះក្នុងនីតិវិធីនីមួយៗមានភាពបទបែនច្រើន ដែលភាគីទាំងសងខាងប្រើសិទ្ធិតាមផ្លូវច្បាប់ក្នុងការជំទាស់នីតិវិធីនីមួយៗបាន ដែលធ្វើឱ្យការដោះស្រាយរឿងក្តីមានរយៈពេលយូរ។ ដោយហេតុថា នីតិវិធីបណ្តឹងត្រូវបានប្រើប្រាស់ច្រើន នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដូចនេះការស្រាវជ្រាវលើប្រធានបទ លំហូរនីតិវិធីនៃការជំនុំជម្រះក្តីលើកទី១នេះ យើងខ្ញុំធ្វើការស្រាវជ្រាវតែលើលំហូរនីតិវិធីនៃការជំនុំជម្រះក្តីលើកទី១ ដែលធ្វើនៅក្នុងនីតិវិធីបណ្តឹងធម្មតា តែប៉ុណ្ណោះ។ ម្យ៉ាងទៀតការស្រាវជ្រាវប្រធានបទមួយនេះទៀតសោត គឺផ្តោតសំខាន់លើលំហូរនីតិវិធីនៃការដោះស្រាយរឿងក្តីរដ្ឋប្បវេណី ដែលប្រព្រឹត្តទៅដោយគ្មានការដាក់ពាក្យបណ្តឹងផ្សេងៗក្រៅពីបណ្តឹងដើមនោះទេ ពោលគឺជាលំហូរនីតិវិធីមួយដែលប្រព្រឹត្តទៅដោយមិនមានឧបសគ្គអ្វីនោះឡើយ ពោលគឺ ចាប់តាំងពីការដាក់ពាក្យបណ្តឹង រហូតដល់ចេញសាលក្រមចុងក្រោយ។

ការសិក្សាស្រាវជ្រាវនេះ នឹងជាឯកសារជំនួយស្មារតីដល់និស្សិតផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ដែលកំពុងសិក្សាលើមុខវិជ្ជា៖ នីតិវិធីរដ្ឋប្បវេណី ក៏ដូចជាមិត្តនិស្សិតទូទៅដែលមានបំណងចង់យល់ដឹងអំពីនីតិវិធីនៃការដោះស្រាយវិវាទរដ្ឋប្បវេណី តាមរយៈប្រព័ន្ធតុលាការ ព្រោះថាគ្រប់បុគ្គលទាំងអស់អាចមានវិវាទរដ្ឋប្បវេណីនៅតុលាការនៅថ្ងៃណាមួយ។

ក្នុងការស្រាវជ្រាវដើម្បីចងក្រងសារណានេះឡើង យើងខ្ញុំផ្អែកលើការសិក្សាពីប្រភពច្បាប់ នៃព្រះរាជាណាចក្រកម្ពុជាដែលនៅជាធរមានតែប៉ុណ្ណោះ ជាពិសេសគឺក្រមនីតិវិធីរដ្ឋប្បវេណីដែលប្រកាសឱ្យប្រើនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ព្រមទាំងសៀវភៅផ្សេងៗដែលទាក់ទិននឹងវិស័យរដ្ឋប្បវេណី។

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាគតិយុត្តខាងលើ និង ដើម្បីធ្វើការសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយ និងកាន់តែមានភាពស៊ីជម្រៅ ហើយច្បាស់លាស់ទៀតនោះ យើងខ្ញុំបានធ្វើការចែងចែកជា ០៣ (បី) ជំពូកធំៗ ដែលក្នុងនោះរួមមាន៖

សេចក្តីផ្តើម៖ ផ្នែកនេះចង់បង្ហាញឱ្យឃើញអំពី លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

ជំពូកទី១ សញ្ញាណទូទៅនៃនីតិវិធីរដ្ឋប្បវេណី៖ នៅក្នុងជំពូកនេះ នឹងបង្ហាញឱ្យលោកអ្នកបានយល់ដឹងអំពី ១. គោលបំណងនៃនីតិវិធីរដ្ឋប្បវេណី ២. គោលការណ៍ជាមូលដ្ឋានក្នុងនីតិវិធីរដ្ឋប្បវេណី

ជំពូកទី២ នីតិវិធីមុនសវនាការ ៖ នៅក្នុងជំពូកនេះ នឹងបង្ហាញឱ្យលោកអ្នកយល់ដឹងអំពី ១. ការដាក់ពាក្យបណ្ដឹង ២. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ជំពូកទី៣ នីតិវិធីក្នុងពេលសវនាការ៖ នៅក្នុងជំពូកនេះ នឹងបង្ហញឱ្យលោកអ្នកយល់ដឹងអំពី ១. នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ២. ការប្រកាសសាលក្រម

សេចក្ដីសន្និដ្ឋាន ៖ យើងខ្ញុំធ្វើការលើកឡើងនូវសេចក្ដីសន្និដ្ឋានជារួម នៅក្នុងប្រធានបទនេះ។

# ជំពូកទី១
# សញ្ញាណទូទៅនៃនីតិវិធីរដ្ឋប្បវេណី

## ១.១ គោលបំណងនៃប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី

ប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីមានគោលបំណងការពារសិទ្ធិស្របច្បាប់របស់បុគ្គលឯកជន តាមរយៈការដោះស្រាយវិវាទដោយបង្ខំ ។ បណ្ដឹងរដ្ឋប្បវេណីមានគោលបំណងឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន។[1] បណ្ដឹងរដ្ឋប្បវេណី ដោះស្រាយវិវាទរវាងភាគីដោយបង្ខំ ភាគីដោយផ្ទាល់ ឱ្យគោរពតាមសេចក្ដីសម្រេចរបស់តុលាការ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយរដ្ឋបង្កើតប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីនេះឡើង មិនមែនក្នុងគោលបំណងធ្វើការដោះស្រាយវិវាទនោះឯងទេ តែគឺដើម្បីធ្វើការទទួលស្គាល់ តាមរយៈតុលាការ ថា បុគ្គលម្នាក់មានសិទ្ធិស្របច្បាប់ និង ដើម្បីការពារសិទ្ធិរបស់បុគ្គលនោះ ដោយបញ្ចប់នូវវិវាទ។ ហេតុដូច្នេះហើយ វាមិនមែនមានន័យថា ការដោះស្រាយវិវាទ អាចនាំឱ្យកើតជាលទ្ធផលអ្វី ដល់ភាគីនោះទេ។ ម៉្យាងទៀត នីតិវិធីរដ្ឋប្បវេណីអាចសម្រេចគោលដៅបាន លុះត្រាតែមានការដោះស្រាយមួយដ៏ត្រឹមត្រូវ ហើយសិទ្ធិរបស់បុគ្គលដែលជាម្ចាស់សិទ្ធិនោះ ត្រូវបានទទួលស្គាល់ដោយផ្អែកទៅលើច្បាប់ ។ ការការពារសិទ្ធិតាមរយៈនីតិវិធីរដ្ឋប្បវេណីបែបនេះ មិនមែនជាការដាក់ទានពីរដ្ឋទៅឱ្យប្រជាពលរដ្ឋនោះទេ ។ ផ្ទុយទៅវិញ គេត្រូវយល់ថា បុគ្គលឯកជនគ្រប់រូប រួមទាំងប្រជាជនកម្ពុជាផង មានសិទ្ធិដាក់ពាក្យបណ្ដឹង ទៅតុលាការ ដើម្បីស្វែងរកការការពារសិទ្ធិរបស់ខ្លួន ល្មិកណាដែលសិទ្ធិនោះត្រូវបានគេបំពាន នៅក្នុងវិវាទរដ្ឋប្បវេណី ។ បើទោះបីជាសិទ្ធិមូលដ្ឋាន និង សិទ្ធិ ផ្សេងៗទៀត ត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ និង ច្បាប់ក៏ដោយ តែបើគេពុំអាចស្វែងរកការការពារ និង ការសង្គ្រោះនានា តាមរយៈ ការដាក់ពាក្យបណ្ដឹងទៅតុលាការ នៅពេលណាដែលសិទ្ធិនោះត្រូវបានគេបំពានទេនោះ ការទទួលស្គាល់សិទ្ធិនោះនឹងពុំមានអត្ថន័យអ្វីឡើយ ។ អាស្រ័យហេតុនេះហើយ គេអាចនិយាយបាន ថា សិទ្ធិពឹងពាក់តុលាការ គឺជា "សិទ្ធិមូលដ្ឋាន ដើម្បីធានានូវសិទ្ធិមូលដ្ឋាន និង សិទ្ធិផ្សេងៗទៀត" ។[2]

[1] មាត្រា ២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[2] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៤ និង ៥

## ១.២ គោលការណ៍មូលដ្ឋានសំខាន់ៗនៅក្នុងនីតិវិធីរដ្ឋប្បវេណី

### ១.២.១ គោលការណ៍មូលដ្ឋាននៃនីតិវិធីរដ្ឋប្បវេណី ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ

#### ១.២.១.១ ឯករាជ្យភាពនៃអំណាចតុលាការ និង ការធានាក្នុងមុខងាររបស់ចៅក្រម

អំណាចតុលាការ គឺជាអំណាចឯករាជ្យ។[3] ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ។[4] ដោយសារថាការដោះស្រាយបណ្តឹងរដ្ឋប្បវេណីគឺជាមុខងារមួយរបស់អង្គការតុលាការ ដែលអំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមតាំងរឿងក្តីរដ្ឋបាលផង។[5] ចៅក្រមដែលជាអ្នកដើរតួនាទីយ៉ាងសំខាន់នៅក្នុងតុលាការ ត្រូវអនុវត្តនូវសិទ្ធិអំណាចរបស់ខ្លួន ដោយឯករាជ្យពីការអន្តរាគមន៍នានាពីសំណាក់អាជ្ញាធររដ្ឋ។ លើសពីនេះទៅទៀត ចៅក្រមត្រូវទទួលការធានានៅក្នុងមុខងាររបស់ខ្លួន គឺមិនអាចត្រូវគេដកពីមុខងារបានទេ លើកលែងតែក្នុងករណីដែលបានប្រព្រឹត្តបទព្រហ្មទណ្ឌ ហើយឧត្តមប្រឹក្សានៃអង្គចៅក្រមសម្រេចដាក់វិន័យ។[6] ឯករាជ្យភាពនៃអង្គការតុលាការ និង ការធានានៅក្នុងមុខងាររបស់ចៅក្រមនេះ គឺជាផ្នែកមួយនៃគោលការណ៍មូលដ្ឋាននានានៃនីតិវិធីរដ្ឋប្បវេណី ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ។[7]

#### ១.២.១.២ គោលការណ៍នៃការជម្រះក្តីតាមច្បាប់

ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និង ច្បាប់ជាធរមាន ។[8] នេះមានន័យថា ការជម្រះក្តីត្រូវធ្វើឡើង តាមច្បាប់ដែល អនុម័តដោយរដ្ឋសភា ដែលជាតំណាងរបស់ប្រជាពលរដ្ឋកម្ពុជា ដែលជាម្ចាស់នៃប្រទេសកម្ពុជា ហើយការជម្រះក្តីមិនត្រូវធ្វើតាមទំនើងចិត្តរបស់ចៅក្រមឡើយ ។ ហេតុនេះហើយ អាចបកស្រាយបានថា នីតិវិធីនៃការជម្រះក្តី ក៏ត្រូវធ្វើតាមច្បាប់ដែរ។ ដោយសារថា គោលការណ៍នៃការជម្រះក្តីតាមច្បាប់ ត្រូវយកទៅអនុវត្តនៅក្នុងនីតិវិធីរដ្ឋប្បវេណី គោលការណ៍នេះក៏ត្រូវបានចាត់ទុកថាជាគោលការណ៍មូលដ្ឋានមួយនៃ នីតិវិធីរដ្ឋប្បវេណី ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញដែរ ។ ហេតុនេះហើយ ទើបក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបាន អនុម័តឡើងទៅតាមការតម្រូវរបស់រដ្ឋធម្មនុញ្ញ ។[9]

### ១.២.២ ការធានានូវសិទ្ធិទាមទារសវនាការ

ដោយសារថា ភាគីនៃបណ្តឹងរដ្ឋប្បវេណីត្រូវអនុវត្តទៅតាមសេចក្តីសម្រេចរបស់តុលាការ ហេតុនេះហើយ ប្រសិនបើសេចក្តីសម្រេចនោះមិនមានភាពត្រឹមត្រូវទេ វាអាចនឹងបំពានលើសិទ្ធិរបស់បុគ្គលឯកជន ដោយ

---

[3] មាត្រា ១២៨ ថ្មី កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣

[4] មាត្រា ១៣២ ថ្មី កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣

[5] មាត្រា ១២៨ ថ្មី កថាខណ្ឌទី៣ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣

[6] មាត្រា ១៣៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣

[7] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៥ និង ៦

[8] មាត្រា ១២៩ ថ្មី នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣

[9] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៦

មិនសមហេតុផល ។ ហេតុដូច្នេះហើយ ទើបក្រមនីតិវិធីរដ្ឋប្បវេណីផ្តល់ការធានាដល់សិទ្ធិនីតិវិធីយ៉ាងច្រើនរបស់ភាគីនៃបណ្តឹងរដ្ឋប្បវេណី ដើម្បីឱ្យពួកគេអាចចូលរួមនៅក្នុងដំណើរការរឿងក្តី និង អាចការពារផលប្រយោជន៍របស់ខ្លួនបាន ។ សិទ្ធិដែលមានសារៈសំខាន់ជាមូលដ្ឋាន នៅក្នុងចំណោមសិទ្ធិនីតិវិធីនានាទាំងនោះ អាចហៅជាសរុបបានថា "សិទ្ធិមូលដ្ឋាននៃនីតិវិធី" ។

ក្នុងចំណោមសិទ្ធិមូលដ្ឋាននៃនីតិវិធី ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី សិទ្ធិនីតិវិធីដែលសំខាន់ជាងគេបំផុត គឺសិទ្ធិទាមទារឱ្យសាកសួរ។ សិទ្ធិទាមទារឱ្យសាកសួរ គឺជាសិទ្ធិទាមទារឱ្យមានការធានានូវឱកាស ក្នុងការបញ្ចេញមតិយោបល់របស់ខ្លួន ដែលពាក់ព័ន្ធទៅនឹងបញ្ហាដែលត្រូវសម្រេចសេចក្តីដោយតុលាការនៅក្នុងបណ្តឹងរដ្ឋប្បវេណី និង ក្នុងការឆ្លើយតបទៅនឹងមតិយោបល់របស់ភាគីម្ខាងទៀត។[10] រដ្ឋត្រូវបង្កើតឱ្យមាននូវនីតិវិធីរដ្ឋប្បវេណី ដែលធានានូវឱកាសបែបនេះចំពោះភាគី ។ ជាគោលការណ៍ ឱកាសក្នុងការបញ្ចេញមតិយោបល់របស់ខ្លួន និង ឱកាសក្នុងការឆ្លើយតបទៅនឹងមតិយោបល់របស់ភាគីម្ខាងទៀត ត្រូវតែផ្តល់ឱ្យភាគី នៅមុនការសម្រេចសេចក្តី។ ប៉ុន្តែ ក្នុងករណីពិសេសបន្ទាន់ ការសម្រេចសេចក្តីត្រូវធ្វើឡើងជាមុន ហើយក្រោយមកទើបអនុញ្ញាតឱ្យស្តាប់មតិយោបល់របស់ភាគី ដែលបានទទួលរងនូវការខូចប្រយោជន៍ដោយសារការសម្រេចសេចក្តីបែបនេះបាន។[11]

### ១.២.៣ គោលការណ៍ចំពោះមុខ

ក្នុងករណីណាក៏ដោយ តុលាការត្រូវគោរពគោលការណ៍ចំពោះមុខ។[12] ដើម្បីធានានូវសិទ្ធិទាមទារឱ្យសាកសួរឱ្យមានប្រសិទ្ធិភាព ការជម្រះក្តីត្រូវតែធ្វើឡើងដោយកោះហៅភាគី ទាំងសងខាងឱ្យមកបង្ហាញខ្លួននៅកាលបរិច្ឆេទតែមួយ ហើយត្រូវឱ្យភាគីប្រឈមមុខដាក់គ្នាដោយផ្ទាល់។ ប្រសិនបើអនុញ្ញាតឱ្យតុលាការអាចកោះហៅភាគីតែម្ខាង ហើយស្តាប់ការអះអាងរបស់ភាគីនោះ ដោយពុំមាន វត្តមានរបស់ភាគីម្ខាងទៀត នោះអាចនឹងប៉ះពាល់ទៅដល់ទំនុកចិត្តរបស់ភាគី ទៅលើយុត្តិធម៌នៃការវិនិច្ឆ័យ ។ ហេតុនេះហើយបានជាមានបញ្ញត្តិចែងថា ជាគោលការណ៍ តុលាការត្រូវវិនិច្ឆ័យ ដោយគោរពតាមគោលការណ៍ ចំពោះមុខ ពោលគឺត្រូវកោះហៅភាគីទាំងសងខាង ឱ្យភាគីទាំងសងខាងថ្លែងពីអំណះអំណាងរបស់ខ្លួន និង ជជែកតតាំងគ្នាទៅវិញទៅមក។ ចំពោះគោលការណ៍ចំពោះមុខនេះ ក៏មានករណីលើកលែងមួយចំនួនដែរ។[13]

---

[10] មាត្រា ៣ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[11] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៦

[12] មាត្រា ៣ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[13] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៧

### ១.២.៤ ការទទួលខុសត្រូវរបស់តុលាការ និង ភាគី

ក្នុងនាមជាអ្នកគ្រប់គ្រងនីតិវិធីរដ្ឋប្បវេណី តុលាការត្រូវប្រឹងប្រែងធានាឱ្យបានថា រឿងក្ដីរដ្ឋប្បវេណីត្រូវបានប្រព្រឹត្តឡើងដោយមានភាពយុត្តិធម៌ និងឆាប់រហ័ស។ នេះគឺជាកាតព្វកិច្ចជាមូលដ្ឋានដ៏ចម្បងបំផុត របស់តុលាការ។ ដោយឡែក ចំពោះភាគីវិញ ក្នុងខណៈដែលពួកគេត្រូវបានអនុញ្ញាតឱ្យអនុវត្តបណ្ដឹងតាមឆន្ទៈរបស់ខ្លួន ដើម្បីឈ្នះក្ដី តែពួកគេត្រូវបានហាមឃាត់មិនឱ្យអនុវត្តបណ្ដឹងដោយមិនស្មោះត្រង់ និង ដោយទុច្ចរិត ចំពោះភាគីម្ខាងទៀតឡើយ។[14] សកម្មភាពបណ្ដឹងដែលត្រូវបានចាត់ទុកថាមិនមានភាពស្មោះត្រង់ ត្រូវកំណត់ទៅតាមករណីជាក់ស្ដែងនីមួយៗ។ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មានចែងនូវបញ្ញត្តិពាក់ព័ន្ធទៅនឹងអានុភាពមិនអំណោយផលមួយចំនួន ដែលកើតចេញពីការមិនគោរពកាតព្វកិច្ចអនុវត្តសកម្មភាព ដោយស្មោះត្រង់ និង សុចរិត ។[15]

### ១.២.៥ ភាសាដែលប្រើក្នុងតុលាការ សិទ្ធិរបស់ភាគីក្នុងការស្នើសុំឱ្យមានអ្នកបកប្រែ

នៅក្នុងតុលាការ ត្រូវប្រើភាសាខ្មែរ ដែលជាភាសាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជា ហើយភាគីដែលមិនអាចយល់ភាសាខ្មែរ អាចស្នើសុំអ្នកបកប្រែដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់បាន ។ លើសពីនេះទៅទៀត នៅក្នុងករណីដែលភាគីមិនមានលទ្ធភាពជួលអ្នកបកប្រែដែលមានលក្ខណៈសម្បត្តិទេ ដោយមូលហេតុថាគាត់ពុំស្គាល់អ្នកបកប្រែដែលមានលក្ខណៈសម្បត្តិ ជាអាទិ៍ តុលាការត្រូវ ផ្ដល់អ្នកបកប្រែដែលមានលក្ខណៈសម្បត្តិឱ្យភាគីនោះ។[16] នៅពេលដែលភាគីណាមួយមិនអាចយល់ភាសាខ្មែរបាន ភាគីនោះពុំអាចថ្លែងពីអំណះអំណាងរបស់ខ្លួន និង ពុំអាចតតាំងចំពោះការអះអាងរបស់ភាគីម្ខាងទៀតបានឡើយ។ ក្នុងន័យនេះ បញ្ញត្តិដែលចែងថា ភាគីនោះអាចជួលអ្នកបកប្រែដោយខ្លួនឯង ឬ បើពុំអាចទៅរួចទេ តុលាការត្រូវផ្ដល់អ្នកបកប្រែឱ្យភាគីនោះ អាចចាត់ទុកជាផ្នែកមួយនៃសិទ្ធិរបស់ភាគីក្នុងការទាមទារឱ្យសាកសួរ ។[17]

### ១.២.៦ ការចូលរួមរបស់តំណាងអយ្យការ

ក្នុងករណីដែលយល់ឃើញថា ចាំបាច់ត្រូវការពារផលប្រយោជន៍សារធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការថា ពាក្យបណ្ដឹងត្រូវបានទទួល។ ទោះបីជាគ្មានការជូនដំណឹងដែលបានកំណត់នៅក្នុងចំណុចខាងលើនេះពីតុលាការក៏ដោយ ក៏តំណាងអយ្យការ អាចចូលរួមក្នុងនីតិវិធីនៃបណ្ដឹងរដ្ឋប្បវេណី និងបញ្ចេញយោបល់បានដែរ ប្រសិនបើខ្លួនយល់ឃើញថា ចាំបាច់ត្រូវការពារប្រយោជន៍សាធារណៈ។[18]

[14] មាត្រា ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[15] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៧

[16] មាត្រា ៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[17] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៧

[18] មាត្រា ៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ទោះជាយ៉ាងណាក៏ដោយ ការចូលរួមរបស់តំណាងអយ្យការ ត្រូវបានកម្រិតត្រឹមតែរឿង ក្ដីណាដែលមានភាពចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈតែប៉ុណ្ណោះ។ គួរកត់សំគាល់ថា នៅក្នុងករណី ដែលភាគីជាអនីតិជន គឺអ្នកតំណាងដែលច្បាប់បានកំណត់ ដូចជាអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាល ជាអាទិ៍ ដែលត្រូវដើរតួនាទីជាអ្នកការពារសិទ្ធិក្នុងនីតិវិធីរបស់ភាគី មិនមែនតំណាងអយ្យការឡើយ ។[19]

### ១.២.៧ គោលការណ៍ផ្សេងៗទៀតនៃការជម្រះក្ដី

បន្ថែមពីលើគោលការណ៍នានាដែលបានរៀបរាប់ខាងលើ មានគោលការណ៍ផ្សេងៗទៀតជាច្រើន ពាក់ព័ន្ធទៅនឹងការជម្រះក្ដី ដូចជា គោលការណ៍នៃការទាញហេតុផល គោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី និង គោលការណ៍នៃការសម្រេចសេចក្ដីដោយផ្អែកលើភស្តុតាង ជាអាទិ៍។[20]

[19] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៨

[20] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៨

# ជំពូកទី២
# នីតិវិធីមុនពេលសវនាការ

## ២.១ ការដាក់ពាក្យបណ្ដឹង

### ២.១.១ អត្ថន័យនៃពាក្យបណ្ដឹង

បណ្ដឹង គឺជាសកម្មភាពទាមទាររបស់ដើមចោទចំពោះចុងចម្លើយ ដើម្បីឱ្យតុលាការចេញសាលក្រម ដោយផ្អែកលើការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តណាមួយតាមច្បាប់កំណត់។ តុលាការត្រូវចាំរហូតដល់បានទទួលពាក្យបណ្ដឹងទើបអាចចាប់ផ្ដើមធ្វើការជំនុំជម្រះបណ្ដឹងនោះបាន។[21]

នីតិវិធីបណ្ដឹង ត្រូវបានចាប់ផ្ដើមក្រោយពេលដែលគូភាគីមានវិវាទជាមួយគ្នាហើយមិនអាចដោះស្រាយវិវាទនោះដោយខ្លួនឯង និង ដោយស្ម័គ្រចិត្តបានទេនាំឱ្យបុគ្គលដែលគិតថាត្រូវបានរំលោភបំពានអាចដាក់ពាក្យបណ្ដឹងទៅតុលាការរដ្ឋប្បវេណី ព្រោះប្រហែលគ្មានជម្រើសណាផ្សេងក្រៅពីការប្រើប្រាស់ប្រព័ន្ធតុលាការដើម្បីទទួលបាននូវដំណោះស្រាយដោយបង្ខំមួយនោះឡើយ។ ដូច្នេះនីតិវិធីបណ្ដឹងរដ្ឋប្បវេណីត្រូវបានចាប់ផ្ដើមពីពេលដាក់ពាក្យបណ្ដឹងទៅកាន់តុលាការដែលមានសមត្ថកិច្ច ហើយពាក្យបណ្ដឹងដែលចាត់ទុកថាបានដាក់ គឺជាពាក្យបណ្ដឹងក្រឡាបញ្ជីបានបោះត្រាចូលថាបានទទួលតាមទម្រង់បែបបទរដ្ឋបាលរបស់តុលាការនោះ។ ប៉ុន្តែពាក្យបណ្ដឹងដែលអាចចាត់ទុកថាបានធ្វើឡើងត្រឹមត្រូវស្របតាមច្បាប់កំណត់ គឺជាពាក្យបណ្ដឹងដែលមានកម្មវត្ថុវិវាទតាមផ្លូវច្បាប់ជាក់ស្ដែង និងអាចដោះស្រាយបានដោយសាលក្រម ព្រោះជាគោលការណ៍បណ្ដឹងរដ្ឋប្បវេណីមានគោលបំណងឱ្យតុលាការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណីដោយផ្អែកលើច្បាប់។[22] ដូច្នេះដើម្បីឱ្យតុលាការអាចដោះស្រាយតាមគោលបំណងនេះបាន លុះត្រាតែការប្ដឹងទាមទារនោះមានកម្មវត្ថុជាវិវាទទាក់ទងនឹងសិទ្ធិរបស់បុគ្គលឯកជន។[23]

### ២.១.២ របៀបដាក់ពាក្យបណ្ដឹង

ការប្ដឹង ត្រូវធ្វើដោយដាក់ពាក្យបណ្ដឹង ជាលាយលក្ខណ៍អក្សរ ទៅតុលាការ។[24] ពាក្យបណ្ដឹងដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរនៅក្នុងបណ្ដឹងត្រូវសរសេរនូវឈ្មោះ អាស្រ័យដ្ឋានរបស់គូភាគី និងឈ្មោះអាស្រ័យដ្ឋានរបស់អ្នកតំណាង ដែលច្បាប់បានកំណត់អំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ។[25]

---

[21] បទបង្ហាញស្ដីអំពី នីតិវិធីរដ្ឋប្បវេណី ទំព័រទី ៣ ដោយលោក ហេង សុខណា ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

[22] មាត្រា ៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[23] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៧៤ កថាខណ្ឌទី២ វាក្យខណ្ឌទី១

[24] មាត្រា ៧៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[25] មាត្រា ៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

### ២.១.៣ ប្រភេទនៃបណ្ដឹង

បណ្ដឹងអាចបែងចែកជាច្រើនប្រភេទ ទៅតាមបទដ្ឋាននីមួយៗ ក៏ប៉ុន្តែ វិធីបែងចែកដែលជាមូលដ្ឋាន គឺការបែងចែកដោយយកប្រភេទ និង បែបយ៉ាងនៃការទាមទារតាមផ្លូវបណ្ដឹង ដែលជាខ្លឹមសារនៃបណ្ដឹង មកធ្វើជាបទដ្ឋាន មានន័យថាអាចបែងចែកជា ៣ ប្រភេទ ដែលមានដូចជា៖

- បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក
- បណ្ដឹងទាមទារឱ្យបញ្ជាក់ និង
- បណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ រំលត់ទំនាក់ទំនងគតិយុត្ត។[26]

#### ២.១.៣.១ បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក

បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក គឺជាបណ្ដឹងមួយដែលទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយផ្ដល់តាវកាលិកកំណត់មួយ ដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិទាមទារឱ្យផ្ដល់តាវកាលិកតាមច្បាប់សារធាតុដែលបានកំណត់ នៅក្នុងការទាមទារតាមផ្លូវបណ្ដឹង។ បណ្ដឹងទាមទារឱ្យផ្ដល់តាវលិក ត្រូវបានបែងចែងចេញជា២ប្រភេទទៀត គឺបណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិកនាពេលបច្ចុប្បន្ន និង បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិកនាពេលអនាគត។[27]

បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិកនាពេលបច្ចុប្បន្ន គឺជាបណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិកដែលដើមចោទបានដាក់ឡើង ដោយមានការអះអាងអំពីសិទ្ធិទាមទារឱ្យផ្ដល់តាវកាលិកមួយ ដែលពេលកំណត់ត្រូវអនុវត្តនោះបានមកដល់។ ឧទាហរណ៍ ៖ លោក **សុខា** បានអះអាងអំពីអត្ថិភាពនៃសិទ្ធិលើបំណុលដោយផ្អែកលើកិច្ចសន្យាខ្ចីប្រាក់ ចំពោះ លោក **រចនា** ទៅកាន់តុលាការ។ ដោយកាលបរិច្ឆេទនៃការសងប្រាក់បានមកដល់ ក៏ប៉ុន្តែ លោក **រចនា** ពុំអនុវត្តនូវកាតព្វកិច្ចតាមខ្លឹមសារនៃកិច្ចសន្យា។ ដូច្នេះ លោក **សុខា** អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់កម្ចីមកឱ្យខ្លួនតាមខ្លឹមសារនៃកិច្ចសន្យា។

បណ្ដឹងទាមទារការផ្ដល់តាវកាលិកនាពេលអនាគត អាចធ្វើបាន លុះត្រាតែមានភាពចាំបាច់តម្រូវឱ្យធ្វើការទាមទារនោះជាមុន។[28] បណ្ដឹងទាមទារប្រភេទនេះអាចធ្វើបាន តែក្នុងករណីចាំបាច់ ដែលតម្រូវឱ្យធ្វើការទាមទារជាមុន គឺជាករណីដែលអាចព្យាករណ៍ជាមុនបានថាទោះបីជាដល់ពេលកំណត់នៃការផ្ដល់តាវកាលិកក៏ដោយ ក៏កូនបំណុលពិតជាមិនផ្ដល់តាវកាលិកឱ្យដល់ម្ចាស់បំណុលដែរ។[29] សរុបជារួម ភាពចាំបាច់នៅក្នុងន័យ

[26] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ឆ្នាំ២០០៨ ទំព័រទី ៨៤

[27] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ឆ្នាំ២០០៨ ទំព័រទី ៨៥

[28] មាត្រា៧៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[29] មាត្រា៧៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

នេះ គឺជាករណីទាំងឡាយដែលម្ចាស់បំណុលអាចព្យាករណ៍ជាមុនបានថា កូនបំណុលពិតជាមិនព្រមផ្តល់តាវកាលិក ដែលជាហេតុនាំឱ្យខូចខាតផលប្រយោជន៍ម្ចាស់បំណុលពិតប្រាកដមែន។ ឧទាហរណ៍៖ លោក **រចនា** បានធ្វើការខ្ចីប្រាក់ចំនួន ៥០,០០០ដុល្លារ ពី លោក **សុខា** ដោយអះអាងថាខ្លួននឹងយកប្រាក់នេះដើម្បីបើកក្រុមហ៊ុននាំចូលទូរស័ព្ទមួយប្រទេសពីប្រទេសអាមេរិក។ ក្រោយមក លោក **សុខា** មានការបារម្ភយ៉ាងខ្លាំង ដោយគិតថា លោក **រចនា** ពិតជាពុំមានលទ្ធភាពក្នុងការទូទាត់នូវបំណុលតាមការកំណត់ឡើយ ដោយមូលហេតុក្រុមហ៊ុននាំចូលទូរស័ព្ទរបស់ លោក **រចនា** កំពុងប្រឈមមុខនឹងវិបត្តិក្ស័យធន។ ដូច្នេះ លោក **សុខា** អាចធ្វើការដាក់ពាក្យបណ្តឹងទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយធ្វើការបង់ប្រាក់កម្ចី ដែលមិនទាន់ដល់ពេលកំណត់សងនោះទេ មកឱ្យខ្លួនបាន ដោយផ្អែកទៅលើស្ថានភាពចាំបាច់ ដែលជាផលប្រយោជន៍ពិសេសនៃបណ្តឹង។

### ២.១.៣.២ បណ្តឹងទាមទារឱ្យបញ្ជាក់

បណ្តឹងទាមទារឱ្យបញ្ជាក់ គឺបណ្តឹងទាមទារឱ្យចេញសាលក្រមបញ្ជាក់ អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដោយផ្អែកលើការអះអាងរបស់ដើមចោទ នូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តមួយកំណត់ ដែលជាការទាមទារតាមផ្លូវបណ្តឹង។ ក្នុងចំណោមនោះ បណ្តឹងដែលអះអាងនូវអត្ថិភាពនៃសិទ្ធិជាអាទិ៍ហៅថា បណ្តឹងទាមទារឱ្យបញ្ជាក់ដោយសកម្ម ហើយបណ្តឹងដែលអះអាងនូវនត្ថិភាពនៃសិទ្ធិនោះ ហៅថាបណ្តឹងទាមទារឱ្យបញ្ជាក់អកម្ម។[30]

ជាគោលការណ៍ កម្មវត្ថុនៃបណ្តឹងទាមទារឱ្យបញ្ជាក់ ត្រូវជាការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តជាក់ស្តែង។ ការទាមទារនៃបណ្តឹងទាមទារឱ្យបញ្ជាក់ជាបឋម ត្រូវធ្វើការអះអាងអំពី អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ហើយជាគោលការណ៍ មិនអនុញ្ញាតឱ្យធ្វើការទាមទារឱ្យបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាព នៃអង្គហេតុទេ។ ក៏ប៉ុន្តែអាចមានករណីពិសេស គឺអាចមានការអនុញ្ញាតឱ្យធ្វើបណ្តឹងទាមទារឱ្យបញ្ជាក់នូវ ភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃឯកសារដែលបញ្ជាក់អំពីទំនាក់ទំនងគតិយុត្ត (សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា ១៣៤, ក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ២៥៦ កថាខណ្ឌទី ១)។

ភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃឯកសារ មានន័យថា តើលិខិតនោះ ត្រូវបានបង្កើតឡើងដោយផ្អែកលើឆន្ទៈរបស់ជន ដែលបានធ្វើលិខិតនោះពិតមែន ឬទេ (ភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវក្នុងការធ្វើឯកសារ) មិនមែនមានន័យថា ខ្លឹមសារដែលមានចុះក្នុងឯកសារនោះត្រូវនឹងអង្គហេតុជាក់ស្តែង ឬទេឡើយ ។ ភាពត្រឹមត្រូវនៃលិខិតនោះ គឺជាអង្គហេតុ ក៏ប៉ុន្តែ អាចអនុញ្ញាតពិសេសឱ្យធ្វើបណ្តឹងទាមទារឱ្យបញ្ជាក់ អំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃឯកសារដែលបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តនោះ គឺដោយសារតែ ប្រសិនបើភាពត្រឹមត្រូវ ឬ មិនត្រឹម

[30] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៤៦

ត្រូវនៃការបង្កើតលិខិតកិច្ចសន្យា ជាអាទិ៍ ត្រូវបានចូលជាស្ថាពរ តាមរយៈ សាលក្រមរវាងភាគី នឹងអស់វិវាទ ដូច្នេះហើយ មានករណីច្រើនដែលវិវាទអំពីទំនាក់ទំនងគតិយុត្តនោះ នឹងត្រូវបានដោះស្រាយ ឬ មានផលប្រយោជន៍ច្រើនក្នុងការដោះស្រាយវិវាទនោះ ។

ម្យ៉ាងទៀត ការទាមទារនៃបណ្តឹងទាមទារឱ្យបញ្ជាក់ ត្រូវជាការអះអាងនូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត "នាពេលបច្ចុប្បន្ន"។ ហើយជាគោលការណ៍ គេមិនទទួលស្គាល់ឱ្យធ្វើបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តអតីតកាល ឬ អនាគតកាលឡើយ ។ ក៏ប៉ុន្តែ ក្នុងករណីដែលការបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តអតីតកាល ឬ អនាគតកាល ទោះមានការចាំបាច់ ហើយសមស្រប ដើម្បីដោះស្រាយវិវាទតាមផ្លូវច្បាប់ដែលមានបច្ចុប្បន្ននេះ គេអាច អនុញ្ញាតពិសេស ឱ្យធ្វើបណ្តឹងទាមទារឱ្យបញ្ជាក់បែបនេះបាន ។[31]

### ២.១.៣.៣ បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត គឺជាបណ្តឹងទាមទារឱ្យតុលាការចេញសាលក្រមប្រកាសបង្កើតជាថ្មីនូវទំនាក់ទំនងគតិយុត្ត ( ការកើតមានឡើង ការប្តូរ ឬ ការរំលត់) ដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិបង្កើត ឬ អំពីមូលហេតុនៃការបង្កើតទំនាក់ទំនងគតិយុត្តកំណត់មួយដែលជាការទាមទារតាមផ្លូវបណ្តឹង។ បណ្តឹងប្រភេទនេះមានដូចជាបណ្តឹងសុំលែងលះគ្នា។ ប្រសិនបើការព្រមព្រៀងលែងលះគ្នារវាងភាគីដែលមានទំនាក់ទំនងអាពាហ៍ពិពាហ៍ មិនអាចសម្រេចបានទេ ហើយក្នុងករណីដែលភាគី ខាងប្តី ឬ ខាងប្រពន្ធ ចង់លែងលះគ្នា ភាគីនោះត្រូវដាក់ពាក្យបណ្តឹងសុំលែងលះគ្នា។ ក្នុងករណីនៃការលែងលះគ្នាតាមរយៈបណ្តឹងសុំលែងលះគ្នា ទាល់តែមានសាលក្រមលែងលះគ្នា ទើបមានអានុភាពបង្កើតនូវទំនាក់ ទំនងគតិយុត្ត ដែលរំលាយនូវទំនាក់ទំនងអាពាហ៍ពិពាហ៍ ដែលមានពីមុនមករវាងដើមចោទ និង ចុងចម្លើយ ។ ទោះជាមានមូលហេតុលែងលះគ្នាដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ហើយភាគីម្ខាងបានបង្ហាញឆន្ទៈលែងលះគ្នាក៏ដោយ មិនមានអានុភាពលែងលះគ្នាបានទេ។ ដើម្បីឱ្យអានុភាពនៃការលែងលះគ្នាដែលជាការរំលាយនូវចំណងអាពាហ៍ពិពាហ៍នោះកើតមានឡើង ទាល់តែតុលាការចេញសាលក្រមលែងលះគ្នា ។ ដូច្នេះហើយ ជាគោលការណ៍ច្បាប់ទទួលស្គាល់នូវការបង្កើត ទំនាក់ទំនងគតិយុត្តថ្មី ដោយផ្អែកលើឆន្ទៈរបស់ភាគីណាម្ខាង ក៏ប៉ុន្តែ មានករណីមួយចំនួនដែល ដើម្បីឱ្យអានុភាពនៃការបង្កើតទំនាក់ទំនងគតិយុត្តនោះមានកើតមានឡើងការបង្ហាញឆន្ទៈរបស់ភាគីមិនមែនជាការគ្រប់គ្រាន់ទេ គឺចាំបាច់មានបណ្តឹង ហើយឱ្យតុលាការចេញសាលក្រម។ បណ្តឹងដែល

[31] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៤៦ និង ៤៧

ទាមទារឱ្យចេញសាលក្រម ដែលមានអានុភាពបែបនេះ គេហៅថា បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត។[32]

## ២.១.៤ ការចាត់ចែងពាក្យបណ្តឹង

### ២.១.៤.១ ការទទួលពាក្យបណ្តឹង

បច្ចុប្បន្នស្ថាប័នតុលាការមាននូវលេខាធិការដ្ឋាន ដែលជាអង្គការសម្រាប់ជំនួយដល់ការងាររដ្ឋបាល របស់ស្ថាប័នតុលាការហើយការងាររដ្ឋបាលទាំងអស់នោះ ក៏មានចំណុចដែលពាក់ព័ន្ធនឹងការទទួលពាក្យបណ្តឹងនេះដែរ។

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ស្ថិតនៅក្រោមរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ ដែលមានអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ ជាសេនាធិការឱ្យក្រសួងយុត្តិធម៌លើការងារនេះ។[33]

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង គឺជាសេនាធិការឱ្យសាលាដំបូង និងអយ្យការសាលាដំបូងលើការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ ស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងបំពេញកិច្ចការមួយចំនួន។[34]

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងមានការិយាល័យចំណុះចំនួន ០៤ (បួន) ដូចខាងក្រោម៖

១. ការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិក

២. ការិយាល័យកិច្ចការហិរញ្ញវត្ថុ

៣. ការិយាល័យកិច្ចការតុលាការ

៤. ការិយាល័យកិច្ចការអយ្យការ។[35]

ដែលក្នុងនោះដែរ ការិយាល័យកិច្ចការតុលាការទទួលបន្ទុក ទទួល និងចាត់ចែងបន្តលើសំណុំរឿងទាំងឡាយក្នុងសមត្ថកិច្ចសាលាដំបូង ពីការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិក និង សម្របសម្រួលកិច្ចការចរាចរឯកសារសំណុំរឿង និងប្រមូលព័ត៌មានទាក់ទងនឹងចំណាត់ការបណ្តឹង និងដំណើរការនីតិវិធីសំណុំរឿងក្តីរបស់សាលាដំបូង។[36]

ជាក់ស្តែងតាមការអនុវត្តប្រចាំថ្ងៃ នៅពេលដែលមានការដាក់ពាក្យបណ្តឹងនៅតុលាការ អ្នកមានភារៈទទួលពាក្យបណ្តឹងគឺមន្ត្រីរដ្ឋបាលផ្នែកទទួលបន្ទុកពាក្យបណ្តឹងរដ្ឋប្បវេណីទទួលបន្ទុកមាន ភារកិច្ច និង តួនាទីដូចតទៅ ៖

---

[32] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៤៩

[33] មាត្រា ៤ កថាខណ្ឌទី ១ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ឆ្នាំ ២០១៦

[34] មាត្រា ៤ កថាខណ្ឌទី ២ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ឆ្នាំ ២០១៦

[35] មាត្រា ៦ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ឆ្នាំ ២០១៦

[36] មាត្រា ៦ ចំណុចលេខ ៣ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ឆ្នាំ ២០១៦

១)ក.ចុះកាលបរិច្ឆេទ និង វាយត្រា ទទួលដើម្បីបញ្ជាក់ច្បាស់អំពីពេលវេលានៃការដាក់ពាក្យបណ្តឹងពីព្រោះដើម្បីបញ្ជាក់ឱ្យបានច្បាស់ថាបណ្តឹងនោះត្រូវបានដាក់ពេលណារួមទាំងចុះលេខរៀងនៅក្នុងសៀវភៅទទួលពាក្យបណ្តឹង និង ឯកសារពាក់ព័ន្ធមកដាក់បញ្ចូលក្នុងក្របសំណុំរឿង។

ខ.បន្ទាប់មក អ្នកទទួលពាក្យបណ្តឹង ដែលសំដៅដល់មន្ត្រីរដ្ឋបាលនោះ ធ្វើការបញ្ជូនសំណុំរឿងក្តីទៅឱ្យប្រធានតុលាការ។

គ.ប្រធានតុលាការ ធ្វើការចារឈ្មោះចៅក្រមទទួលបន្ទុករឿងក្តីតាមលំដាប់បន្ទាប់ដែលបានកំណត់តាមការបែងចែករឿងក្តីតាមការកំណត់ប្រចាំឆ្នាំ នៅលើសាមីនៃពាក្យបណ្តឹងនោះ ហើយមន្ត្រីរដ្ឋបាលនោះត្រូវយកសាមី នៃពាក្យបណ្តឹងនោះទៅឱ្យក្រឡាបញ្ជីរដ្ឋបាលនៃបន្ទប់ចៅក្រមទទួលបន្ទុកនោះ។[37] ក្នុងករណីចៅក្រមមានធុរៈកិច្ច ឬ អវត្តមានរយៈពេលយូរ លំដាប់ត្រូវបានប្តូរទៅតាមការកំណត់ទុកជាមុនក្នុងដីកាសម្រេចប្រចាំឆ្នាំនោះ។ ក្នុងករណីពិសេសបំផុត ទើបអាចមានការប្តូរលំដាប់នេះ ដោយដីកាសម្រេចរបស់ប្រធានតុលាការ ដែលអាចធ្វើបាននៅក្នុង ចន្លោះនៃឆ្នាំនោះបាន។[38]

ឃ.ក្រឡាបញ្ជីរដ្ឋបាលនោះត្រូវទទួលសាមីនៃពាក្យបណ្តឹងនោះហើយត្រូវយកសាមី នៃពាក្យណ្តឹងនោះទៅឱ្យចៅក្រមទទួលបន្ទុកនោះ ហើយចៅក្រមនោះត្រូវចារឈ្មោះក្រឡាបញ្ជីណាជាអ្នកកាន់ពាក្យបណ្តឹងនោះ(រឿងក្តី) លើសាមីនៃពាក្យបណ្តឹងនោះ។

ង.ក្រឡាបញ្ជី រដ្ឋបាលនោះត្រូវយកសាមីពាក្យបណ្តឹងចុះក្នុងសៀវភៅទទួលពាក្យបណ្តឹងរបស់ខ្លួន។

ដូច្នេះការចុះបណ្តឹងគេអាចដឹងបានថា ពាក្យបណ្តឹងនោះ នឹងត្រូវបញ្ជូនទៅទីកន្លែងណាហើយការចុះលេខលើបណ្តឹងក៏ជាការងាយស្រួលក្នុងការបែងចែងរឿងក្តីផងដែរ។ ឧទាហរណ៍ ៖ រឿងក្តីដំបូង លេខ០១ ត្រូវបញ្ជូនទៅចៅក្រមដែលមានលំដាប់ទី១ហើយរឿងក្តីបន្ទាប់ដែលមាន លេខ០២ ត្រូវបញ្ជូនទៅឱ្យចៅក្រមដែលមានលំដាប់លេខ២។ នេះជាការផ្តល់រឿងក្តីទៅតាមលេខរៀងហើយវាអាចធ្វើឱ្យការបែងចែកប្រភេទនេះជាការងារមួយប្រកបដោយ តម្លារភាពផងដែរ។

### ២.១.៤.២ ការពិនិត្យពាក្យបណ្តឹង

នៅពេលដែលរឿងក្តីត្រូវបានបញ្ជូនមកចៅក្រមណាម្នាក់ ឬ ក្រុមប្រឹក្សាជំនុំជម្រះ រួចហើយតុលាការត្រូវពិនិត្យលើពាក្យបណ្តឹង។[39] ចៅក្រមដែលទទួលនូវការបែងចែករឿងក្តី ត្រូវពិនិត្យមើលថា តើក្នុងពាក្យបណ្តឹងនោះមានសរសេរនូវចំណុចដែលចាំបាច់ត្រូវសរសេរក្នុងពាក្យបណ្តឹង ព្រមទាំងថាតើដើមចោទបានបង់ពន្ធសម្រាប់

---

[37] មាត្រា ២៦ កថាខណ្ឌទី ១ និង ទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[38] មាត្រា ២៦ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[39] មាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ការដាក់ពាក្យបណ្តឹង ដែរឬទេ ។ ការពិនិត្យនេះ គឺជាការពិនិត្យស្តីពីភាពស្រប ឬ មិនស្របនឹងល័ក្ខខ័ណ្ឌទម្រង់តែប៉ុណ្ណោះហើយមិនអនុញ្ញាតឱ្យពិនិត្យមើលថា តើស្របនឹងល័ក្ខខ័ណ្ឌផលប្រយោជន៍នៃបណ្តឹង ឬ ល័ក្ខខ័ណ្ឌបណ្តឹងផ្សេងទៀតឬទេ ឬក៏ការទាមទារតាមផ្លូវបណ្តឹងនោះមានមូលហេតុត្រឹមត្រូវដែរឬទេ ជាអាទិ៍ ឡើយ។[40]

តាមលទ្ធផលនៃការពិនិត្យ ប្រសិនបើខ្វះចំណុចដែលចាំបាច់ត្រូវសរសេរក្នុងពាក្យបណ្តឹង ឬ ពន្ធដាក់ពាក្យសុំមិនត្រូវបានបង់ ឬ មានកង្វះ ជាអាទិ៍ តុលាការត្រូវចេញដីកាសម្រេចបង្គាប់ឱ្យធ្វើការកែតម្រូវនូវចំណុចដែលខ្វះនោះ ដោយកំណត់នូវអំឡុងពេលសមរម្យដើម្បីកែតម្រូវ។[41] ប្រសិនបើដើមចោទមិនបានធ្វើការកែតម្រូវក្នុងអំឡុងពេលដែលបានកំណត់នោះទេ តុលាការត្រូវលើកចោលពាក្យបណ្តឹង ដោយដីកាសម្រេច។[42] ប្រសិនបើមានការមិនពេញចិត្តនឹងដីកាសម្រេចនេះ ដើមចោទអាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍បាន។[43]

ប្រសិនបើដើមចោទបានធ្វើការកែតម្រូវតាមការបង្គាប់ឱ្យធ្វើការកែតម្រូវ តុលាការត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅឱ្យចុងចម្លើយ ហើយចាប់ផ្តើមការជំនុំជម្រះ។[44]

### ២.១.៤.៣ ការបញ្ជូនពាក្យបណ្តឹង

ក្រោយការពិនិត្យពាក្យបណ្តឹង ប្រសិនបើតុលាការទទួលស្គាល់ថា ពាក្យបណ្តឹងនោះត្រឹមត្រូវតាមទម្រង់ ហើយទទួលពាក្យបណ្តឹងនោះ ក្រឡាបញ្ជី ត្រូវធ្វើការបញ្ជូនពាក្យបណ្តឹងនោះ ទៅឱ្យចុងចម្លើយជាចាំបាច់។[45] ដើម្បីធ្វើការបញ្ជូនពាក្យបណ្តឹង ត្រូវទាមទារឱ្យដើមចោទត្រៀមនូវឯកសារចម្លងនៃពាក្យបណ្តឹងទៅតាមចំនួនដែលត្រូវការ តាមចំនួននៃចុងចម្លើយ ហើយបញ្ជូនឯកសារចម្លងនៃពាក្យបណ្តឹងនោះទៅឱ្យចុងចម្លើយ ( តុលាការត្រូវរក្សាទុកនូវឯកសារដើមនៃពាក្យបណ្តឹងនោះ)។ ក្នុងករណីដែលមិនអាចធ្វើការបញ្ជូនបាន ដោយសារតែអាសយដ្ឋានរបស់ចុងចម្លើយដែលមានសរសេរក្នុងពាក្យ បណ្តឹងនោះមិនត្រឹមត្រូវ ជាដើម តុលាការត្រូវបង្គាប់ឱ្យធ្វើការកែតម្រូវដោយកំណត់អំឡុងពេលដើម្បីកែតម្រូវ ដូចក្នុងករណីដែលមានកង្វះក្នុងការសរសេរពាក្យបណ្តឹងដែរ។ ក្នុងករណីដែលដើមចោទមិនបានបង់សោហ៊ុយចាំបាច់ជាមុនសម្រាប់ធ្វើការបញ្ជូនពាក្យបណ្តឹង ក៏ត្រូវ ចាត់ចែងដូចគ្នាដែរ ។[46] ម្យ៉ាងទៀត ទោះបីជាដើមចោទបាន ខំប្រឹងប្រែងស្រាវជ្រាវរកអាសយដ្ឋាន លំនៅឋាន ឬ ទីកន្លែងផ្សេងទៀតដើម្បីធ្វើការបញ្ជូនពាក្យបណ្តឹង ក៏ដោយ តែរកមិនឃើញទេ ដើមចោទអាចដាក់ពាក្យសុំឱ្យធ្វើការបញ្ជូនតាមការផ្សាយ

---

[40] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៥៩

[41] មាត្រា៧៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[42] មាត្រា៧៨ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[43] មាត្រា២៥៩ កថាខណ្ឌទី ១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[44] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៥៩

[45] មាត្រា៧៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[46] មាត្រា ៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ជាសាធារណៈ បាន។[47] ទោះជាដើមចោទបានដាក់ពាក្យបណ្ដឹងទៅតុលាការក៏ដោយ ទំនាក់ទំនងគតិយុត្តនឹងកើតមានឡើងត្រឹមតែរវាងតុលាការ និងដើមចោទតែប៉ុណ្ណោះរហូតដល់ពេលដែល ពាក្យបណ្ដឹងនោះត្រូវបានបញ្ជូនទៅចុងចម្លើយ។ តាមរយៈការបញ្ជូនពាក្យបណ្ដឹងទៅឱ្យចុងចម្លើយ ចុងចម្លើយក៏នឹងក្លាយទៅជាប្រធាននៃនីតិវិធីនៃបណ្ដឹងនោះ ហើយទំនាក់ទំនងគតិយុត្តរវាងភាគីទាំងបី គឺ តុលាការ ដើមចោទ និង ចុងចម្លើយ នឹងកើតមានឡើងពីពេលនោះ ។ ក្នុងន័យនេះ ការដាក់បណ្ដឹង ត្រូវបានសម្រេច ដោយការបញ្ជូនពាក្យបណ្ដឹងនោះទៅឱ្យចុងចម្លើយ ។[48]

### ២.១.៤.៤ ការកំណត់កាលបរិច្ឆេទដំបូងនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល និង ការកោះហៅភាគី

ពេលដែលបណ្ដឹងត្រូវបានដាក់ តុលាការត្រូវធ្វើការកំណត់នូវកាលបរិច្ឆេទនៃនីតិវិធីត្រៀតសម្រាប់ការទាញហេតុផល (កាលបរិច្ឆេទលើកដំបូងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) កុំឱ្យមានការយឺតយ៉ាវ ហើយត្រូវកោះហៅភាគីទាំងសងខាងនៅកាលបរិច្ឆេទនេះ ត្រូវកំណត់អំឡុងពេល ៣០ថ្ងៃ បន្ទាប់ពីពាក្យបណ្ដឹងត្រូវបានដាក់ ។[49] តាមការអនុវត្តជាក់ស្ដែង ក្រោយពីបានពិនិត្យ ហើយទទួលពាក្យបណ្ដឹង តុលាការត្រូវកំណត់នូវកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផលលើកដំបូង ហើយត្រូវធ្វើការបញ្ជូនពាក្យបណ្ដឹង ព្រមជាមួយនឹងដីកាកោះហៅចុងចម្លើយឱ្យមកតុលាការតាមកាលបរិច្ឆេទកំណត់នេះ។ ចំពោះដើមចោទវិញ ត្រូវបញ្ជូនដីកាកោះហៅនៅកាលបរិច្ឆេទនេះ។ ម្យ៉ាងទៀត ប្រសិនបើដើមចោទពុំបានបង់សោហ៊ុយចាំបាច់សម្រាប់ការកោះហៅតាមកាលបរិច្ឆេទនេះ ( ដូចជាសោហ៊ុយដើម្បីធ្វើការបញ្ជូនដីកាកោះហៅ ជាដើម ) ជាមុន ហើយមិនធ្វើតាមការបង្គាប់ឱ្យបង់ជាមុននេះតុលាការអាចលើកចោលបណ្ដឹងនោះ ដោយដីកាសម្រេច (ក៏ប៉ុន្តែ លុះត្រាតែគ្មានការតវ៉ាពីចុងចម្លើយ។[50] ក្នុងករណីដែលធ្វើការបញ្ជូនពាក្យបណ្ដឹង ព្រមគ្នានឹងដីកាកោះហៅចុងចម្លើយស្ដីពីកាលបរិច្ឆេទលើកដំបូង ប្រសិនបើពុំបានបង់សោហ៊ុយបញ្ជូនជាមុនទេ តុលាការមិនអាចធ្វើការបញ្ជូនពាក្យបណ្ដឹងបានទេ ដូច្នេះហើយតុលាការនឹងលើកចោលពាក្យបណ្ដឹង)។[51]

---

47 មាត្រា ២៥៥ កថាខណ្ឌទី ១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

48 សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៦០

49 មាត្រា ៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

50 មាត្រា ៨២ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

51 សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៦០

## ២.២ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ២.២.១ គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីនៃការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីលើកកំពស់ និង សម្រួលដល់ការជម្រះក្តីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។[52]

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំនូវសេចក្តីអះអាងរបស់ភាគី បំភ្លឺចំណុចវិវាទនៃរឿងក្តីដែលគូភាគីមិនយល់ស្របគ្នា និង រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់។[53] តាមរយៈគោលបំណងនេះ យើងអាចនិយាយបានថានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការមានកិច្ចការបីសំខាន់ៗដែលត្រូវធ្វើពោលគឺៈ

- ការរៀបចំការអះអាងរបស់ភាគី ។
- ការបំភ្លឺនូវចំណុចវិវាទ ។
- និងការរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទ ។

ក្នុងការរៀបចំការអះអាងរបស់ភាគី តុលាការត្រូវពិគ្រោះជាមួយភាគីទាំងសងខាង ត្រូវរៀបចំសេចក្តីអះអាងរបស់ភាគី និង ត្រូវបំភ្លឺនូវចំណុចវិវាទ តាមវិធីសាស្ត្រដូចតទៅៈ (១) ស្នើឱ្យភាគីដកការអះអាងអំពីអង្គហេតុដែលមិនមានប្រយោជន៍ចំពោះការសម្រេចអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹង និង ផាត់ចោលនូវអង្គហេតុដែលពុំមានវិវាទ (២) ជាងនេះទៅទៀត ចំពោះភស្តុតាងដែលត្រូវពិនិត្យទាក់ទងនឹងចំណុចវិវាទ តុលាការត្រូវធានាឱ្យបាននូវការពិនិត្យដោយសមូហវិធី ដោយត្រូវយកចិត្តទុកដាក់តែលើភស្តុតាងដែលសំខាន់ និង មានតម្លៃតែប៉ុណ្ណោះ។[54]

ជាទូទៅតុលាការត្រូវឱ្យការពិនិត្យភស្តុតាងអាចប្រព្រឹត្តទៅជាបន្ទាន់ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដំបូង បន្ទាប់ពីបានបញ្ចប់ការរៀបចំចំណុចវិវាទ និងភស្តុតាងហើយ។[55] ក៏ប៉ុន្តែនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការអាចចេញដីកាសម្រេចដែលទាក់ទង នឹងការស្នើសុំឱ្យពិនិត្យភស្តុតាង ឬ ដីកាសម្រេចផ្សេងទៀតដែលអាចសម្រេចបាន ក្រៅពីកាលបរិច្ឆេទនៃការទាញហេតុផល

[52] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៧៣

[53] មាត្រា ១០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[54] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៧៤

[55] មាត្រា ១២៧ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ដោយផ្ទាល់មាត់ និងអាចពិនិត្យភស្តុតាងជាឯកសារ ដោយមានកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តី និងភស្តុតាង។[56]

### ២.២.២ ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ដើម្បីឱ្យដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលប្រព្រឹត្តទៅបានល្អ ក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់នូវសកម្មភាពមួយចំនួនដែលចាំបាច់ត្រូវបំពេញដូចជា៖ ការសាកល្បងផ្សះផ្សា ការរៀបចំការអះអាងរបស់ភាគី ការរៀបចំចំណុចវិវាទ និងការរៀបចំភស្តុតាង ព្រមទាំងការធ្វើកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

#### ២.២.២.១ ការសាកល្បងផ្សះផ្សា

ការផ្សះផ្សា គឺជាការដោះស្រាយវិវាទមួយដែលមានភាពទន់ភ្លន់ ដោយសារតែវាបានផ្តល់ឱកាសដល់ភាគីក្នុងការចចារគ្នា ដើម្បីបញ្ចប់វិវាទដោយពុំចាំបាច់ធ្វើការចេញសាលក្រមដោយតុលាការនោះទេ ។ នៅក្នុងនីតិវិធីនៃការជំនុំជម្រះរឿងក្តីរដ្ឋប្បវេណី តុលាការអាចសាកល្បងផ្សះផ្សាបាន ទោះបីជាបណ្តឹង ស្ថិតក្នុងដំណាក់កាលណាក៏ដោយ។[57] ដូចគ្នាផងដែរនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសាកល្បងផ្សះផ្សាជាដំបូងសិន លើកលែងតែយល់ឃើញថាមិនសមរម្យ។[58] ដោយសារថានីតិវិធីរដ្ឋប្បវេណី មានគោលបំណងធ្វើការកំណត់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ និង កាតព្វកិច្ចតាមច្បាប់សារធាតុ ដែលអាចចាត់ចែងបាន ដោយផ្អែកលើការព្រមព្រៀងរវាងភាគី ដូច្នេះ ទោះបីជានៅពេលដែលនីតិវិធីបណ្តឹងត្រូវបានចាប់ផ្តើមហើយក៏ដោយ ប្រសិនបើភាគីបានកំណត់ថាសិទ្ធិ ឬ កាតព្វកិច្ចនោះ មានអត្ថិភាព ឬ គ្មាន តាមរយៈការសះជាហើយភាគីសម្រេចចិត្តបញ្ឈប់វិវាទនោះ គេអាចនិយាយបានថា វាគឺជាលទ្ធផលដែលគួរឱ្យចង់បាន។ ហេតុនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលជាសកម្មភាពដំបូងបំផុតនៃការជម្រះក្តី តុលាការត្រូវណែនាំឱ្យភាគីទាំងសងខាង សះជានឹងគ្នា។ ប៉ុន្តែផ្ទុយមកវិញ ក្នុងករណីដែលតុលាការយល់ឃើញថា ការព្យាយាមសាកល្បងផ្សះផ្សា មិនសមរម្យទេ ដូចជា ក្នុងករណីដែលសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុបណ្តឹង គឺជាប្រភេទនៃសិទ្ធិ ឬ កាតព្វកិច្ចដែលមិនអាចចាត់ចែងបានដោយគ្រាន់តែផ្អែកលើការព្រមព្រៀងរបស់ភាគីប៉ុណ្ណោះទេ ឬ ក្នុងករណីដែល អាកប្បកិរិយារបស់ភាគី បង្ហាញយ៉ាងច្បាស់ថា ពួកគេគ្មានឆន្ទៈធ្វើការផ្សះផ្សាទេនោះ តុលាការមិនចាំបាច់ណែនាំឱ្យភាគីសះជានឹងគ្នាឡើយ។[59]

---

[56] មាត្រា ១០៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[57] មាត្រា ៩៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[58] មាត្រា១០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[59] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៧៧

ម្យ៉ាងទៀត ប្រសិនបើ តាមរយៈការវិនិច្ឆ័យអំពីស្ថានភាពនៃបណ្តឹង តុលាការយល់ឃើញថា វិវាទនោះអាចដោះស្រាយដោយការផ្សះផ្សាបាន តុលាការអាចសាកល្បងផ្សះផ្សា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅពេលក្រោយមក ឬ នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់តែម្តង ក៏បាន។ នៅពេលណែនាំឱ្យភាគីសះជាគ្នា តុលាការអាចប្រើវិធីមួយដោយឱ្យភាគីម្ខាងចេញពីបន្ទប់ ហើយតុលាការស្តាប់ការអះអាងរបស់ភាគីម្ខាងទៀត និង ធ្វើដូច្នេះម្តងទៀតចំពោះភាគីម្ខាងទៀត (គេហៅថា "ការសួរឆ្លាស់គ្នា")។ ក៏ប៉ុន្តែ បើប្រើវិធីនេះ ភាគីម្ខាងមិនអាចដឹងថាតើតុលាការ និង ភាគីម្ខាងទៀត បានពិគ្រោះគ្នាពីរឿងអ្វីខ្លះនោះទេ ហើយការណ៍នេះ នឹងធ្វើឱ្យនីតិវិធីនៃការផ្សះផ្សា មានភាពមិនច្បាស់លាស់។ ហេតុដូច្នេះ វិធីសាស្ត្រនេះ អាចប្រើបានតែនៅក្នុងករណីដែលមានការព្រមព្រៀងច្បាស់លាស់រវាងភាគី ក្នុងការធ្វើបែបនេះ តែប៉ុណ្ណោះ។[60]

ក្នុងន័យនេះ ទោះបីជាក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ញត្តបើកផ្លូវឱ្យតុលាការអាចធ្វើការផ្សះផ្សាបានគ្រប់នីតិវិធីក៏ដោយ ក៏ប៉ុន្តែប្រសិនបើតុលាការយល់ឃើញថាការផ្សះផ្សានឹងមិនមានលទ្ធផលនោះទេ ដោយផ្អែកទៅលើកត្តាផ្សេងៗនោះ តុលាការមិនចាំបាច់ធ្វើការផ្សះផ្សានោះទេ ពោលគឺតុលាការត្រូវចាប់ផ្តើមធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតែម្តង។ ប្រសិនបើការផ្សះផ្សារបស់តុលាការទទួលបានលទ្ធផលនោះតុលាការត្រូវបង្គាប់ឱ្យក្រឡាបញ្ជី ធ្វើកំណត់ហេតុសះជាដើម្បីបញ្ចប់បណ្តឹង ដែលកំណត់ហេតុនេះមានអានុភាពដូចសាលក្រមផងដែរ។[61]

### ២.២.២.២ ការរៀបចំការអះអាងរបស់គូភាគី

ក្នុងករណីដែលតុលាការធ្វើការសាកល្បងផ្សះផ្សាមិនបានសម្រេចទេ តុលាកាត្រូវចាប់ផ្តើមការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់។ ដោយសារតែនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានគោលបំណងធ្វើការរៀបចំនូវការអះអាងរបស់ភាគី ធ្វើការកំណត់នូវចំណុចវិវាទ និងធ្វើការរៀបចំនូវភស្តុតាង ដែលពួកគេមានបំណងនឹងដាក់នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់។ ហេតុនេះហើយ ត្រង់ចំណុចនេះ ការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ មានលក្ខណៈប្រហាក់ប្រហែលទៅនឹងការហាត់សមធ្វើនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ដែរ។ ការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវចាប់ផ្តើមដំបូងដោយសេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹងរបស់ដើមចោទ និង អំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ (នៅក្នុងករណីជាក់ស្តែង ដើម្បីសាកល្បងធ្វើការផ្សះផ្សា ចំបាច់ត្រូវដឹងជាមុនអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ។ ដូច្នេះ មុននឹងសាកល្បងធ្វើការផ្សះផ្សា តុលាការអាចបង្គាប់ឱ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹងបាន។ ក្នុងករណីបែបនេះតុលាការមិនចាំបាច់ឱ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍ម្តងទៀតទេនៅក្រោយពេលសាកល្បងធ្វើការផ្សះផ្សា)។ ដោយសារថា សាលក្រមដែលដើមចោទទាមទារ

[60] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៧៦ និង ៧៧

[61] មាត្រា ៩៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

មាន សរសេរនៅក្នុងខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការ ក្នុងពាក្យបណ្តឹង ហេតុនេះហើយ ពាក្យសុំនេះ ត្រូវបានធ្វើឡើងក្នុងរូបភាពជាសេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹង។ ដោយសេចក្តីថ្លែងការណ៍នេះ កម្មវត្ថុចម្បងសម្រាប់ការត្រៀមរៀបចំនៅពេលបន្តបន្ទាប់ទៀត ត្រូវបានកំណត់។ មានន័យថា នីតិវិធីជាបន្តបន្ទាប់ទៅទៀត ត្រូវរៀបចំឡើងដោយយោងទៅលើករណីដែលថា តើតុលាការគួរចេញសាលក្រមដែលដើមចោទបានទាមទារ ឬ មិនគួរ។[62]

នៅពេលដែលដើមចោទបានធ្វើសេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹងហើយ លើកលែងតែករណីដែលចុងចម្លើយទទួលស្គាល់ការទាមទារ ជាធម្មតាចុងចម្លើយតែងតែដាក់ពាក្យសុំឱ្យតុលាការចេញសាលក្រមច្រានចោលនូវការទាមទាររបស់ដើមចោទ ដោយអះអាងថា ការទាមទារនោះពុំមានមូលដ្ឋានត្រឹមត្រូវ ឬដាក់ពាក្យសុំឱ្យតុលាការចេញសាលក្រមលើកពាក្យបណ្តឹងចោល ដោយអះអាងថា ការបំពេញល័ក្ខខណ្ឌក្នុងបណ្តឹង មិនបានគ្រប់គ្រាន់ (ប្រសិនបើបានដាក់ឯកសារចម្លើយ ពាក្យសុំនេះក៏នឹងត្រូវធ្វើឡើង ក្នុងរូបភាពជាសេចក្តីថ្លែងការណ៍អំពីឯកសារចម្លើយនោះដែរ)។[63]

### ២.២.២.៣ ការកំណត់ចំណុចវិវាទ

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ពេលដែលភាគីបានដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនពេលនោះ តុលាការត្រូវអនុវត្តសិទ្ធិឱ្យបំភ្លឺ និង រៀបចំមធ្យោបាយតទល់ ឬ ការពារខ្លួននោះ ជាពិសេស ត្រូវរៀបចំការអះអាងរបស់ភាគីទាំងសងខាង ដើម្បីកំណត់នូវចំណុចវិវាទពិតប្រាកដនៃរឿងក្តី ហើយតុលាការត្រូវរៀបចំនូវភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទនោះ ដែលត្រូវធ្វើការពិនិត្យនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។[64]

ជាទូទៅ ចំណុចទាំងឡាយណាដែលភាគីទាំងសងខាងប្រកែកគ្នា (ជាធម្មតា គឺអង្គហេតុ) គេហៅថាចំណុចវិវាទ។ ក្នុងករណីដែលភាគីម្ខាង បានអះអាងអំពីអត្ថិភាពនៃអង្គហេតុណាមួយ ក្រមនីតិវិធីរដ្ឋប្បវេណីបែងចែកអាកប្បកិរិយារបស់ភាគីម្ខាងទៀត ជាបួនប្រភេទ។ ទី១ ភាគីម្ខាងទៀតនោះ អាចធ្វើសេចក្តីថ្លែងការណ៍បដិសេធនូវអត្ថិភាពនៃអង្គហេតុនោះ ដែលការធ្វើបែបនេះ គេហៅថា ការបដិសេធ (ការមិនទទួលស្គាល់)។ ទី២ ភាគីនោះ អាចធ្វើសេចក្តីថ្លែងការណ៍ទទួលស្គាល់នូវអត្ថិភាពនៃអង្គហេតុនេះ ដែលគេហៅថា ការសារភាព។ ទី៣ ភាគីនោះ អាចធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនមិនបានដឹងអំពីអត្ថិភាពនៃអង្គហេតុនោះទេ ដែលការធ្វើបែបនេះ គេហៅថា សេចក្តីថ្លែងការណ៍អំពីការមិនបានដឹង។ ទី៤ ចុងក្រោយគេ គឺករណីដែលភាគីនោះមិនបានឆ្លើយថាអ្វីទាំងអស់។ ក្នុងចំណោមករណីទាំងនេះអង្គហេតុ គឺជាចំណុចវិវាទ នៅក្នុងករណីទី១ តែនៅក្នុងករណីទី២ អង្គ

[62] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៧៧ និង ៧៨

[63] សេចសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៧៨

[64] សេចសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៨២

ហេតុ មិនមែនជាចំណុចវិវាទទេ។ បញ្ហាកើតមានឡើងចំពោះករណីពីរចុងក្រោយ។[65] នៅក្នុងករណីនៃការធ្វើសេចក្ដីថ្លែងការណ៍ថាខ្លួនមិនដឹងអំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង ភាគីនោះ ត្រូវសន្មតថាបានតវ៉ាអំពីអង្គហេតុនោះ។[66] ហើយ ចំពោះករណីដែលភាគីមិនឆ្លើយអ្វីទាំងអស់វិញ ត្រូវចាត់ទុកថាភាគីបានសារភាពអំពីអង្គហេតុនោះ លើកលែងតែក្នុងករណីដែលតុលាការយល់ឃើញថា ភាគី នោះបានតវ៉ាចំពោះអង្គហេតុនោះ ដោយគិតពិចារណាអំពីអាកប្បកិរិយាទាំងស្រុងរបស់ភាគីនោះ។[67] ហេតុនេះហើយ អង្គហេតុដែលភាគីឆ្លើយថាមិនបានដឹងនឹងក្លាយទៅជាចំណុចវិវាទ។ ផ្ទុយទៅវិញ ប្រសិនបើពុំមានការឆ្លើយតបទេ ត្រូវចាត់ទុកថាជាការសារភាព ហើយអង្គហេតុនោះ នឹងមិនមែនជាចំណុចវិវាទឡើយ។ តាមគោលការណ៍នៃការទាញហេតុផល អង្គហេតុដែលភាគីបានសារភាព (រួមទាំងអង្គហេតុដែលបានសន្មតថាបានសារភាព) មិនចាំបាច់ធ្វើការបញ្ជាក់ ដោយភស្តុតាងឡើយ។[68]

អាស្រ័យហេតុនេះ តុលាការ ធ្វើការកំណត់នូវចំណុចវិវាទនៃរឿងក្ដីនេះ តាមរយៈការបង្គាប់ឱ្យភាគីធ្វើការបំភ្លឺអំពីអង្គហេតុផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងអង្គហេតុដែលជាមូលហេតុផ្ទាល់នៃការបង្កើតសិទ្ធិ ដែលដើមចោទអះអាង និង អំពីរឿងរ៉ាវលម្អិតនៃរឿងក្ដី និង តាមរយៈការបង្គាប់ឱ្យភាគីធ្វើការបន្ថែម កែប្រែ ឬដកចេញនូវការអះអាងរបស់ខ្លួន។ មុខងារនេះរបស់តុលាការ គេហៅថា "ការរៀបចំការអះអាង" ឬ "ការរៀបចំចំណុចវិវាទ"។ តាមរយៈមុខងារនេះ ចំណុចវិវាទពិតប្រាកដត្រូវបានកំណត់ និង ត្រូវបានទទួលស្គាល់រួមគ្នា ដោយតុលាការ និងភាគីទាំងសងខាង។[69]

ជាឧទាហរណ៍៖រឿងក្ដីខ្ចីបរិភោគ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ លោក **ក** បានខ្ចីប្រាក់ពីលោក **ខ** ចំនួន ១០,០០០ $ ហើយលោក **ខ** បានប្រគល់ប្រាក់ទៅឱ្យលោក **ក** ថ្ងៃកំណត់សងនៅថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ ២០២១ ។ លុះដល់ថ្ងៃកំណត់សងបានមកដល់ លោក **ក** មិនបានសងប្រាក់ទៅលោក **ខ** តាមការកំណត់នោះទេ ។

❖ សេចក្ដីថ្លែងការណ៍របស់ដើមចោទ៖

លោក **ក** បានបានធ្វើសេចក្ដីថ្លែងការណ៍ដូចតទៅ៖

- ដើមចោទ និងចុងចម្លើយបានបង្កើតកិច្ចសន្យាខ្ចីបរិភោគនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ។

[65] សេចសេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៨២

[66] មាត្រា ៩៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[67] មាត្រា ៩៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[68] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៨២ និង ៨៣

[69] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៨៣ ។

- ដើមចោទបានប្រគល់ប្រាក់តាមកិច្ចសន្យា ។
- ការកំណត់សងបានមកដល់ តែចុងចម្លើយមិនបានសងប្រាក់តាមការកំណត់ ។

❖ សេចក្តីថ្លែងការណ៍តបរបស់ចុងចម្លើយ៖

- បដិសេធចំពោះការទាមទារ ដោយលើកអង្គហេតុតវ៉ាថា ៖ ចុងចម្លើយបានសងប្រាក់ទៅឱ្យដើមចោទរួចហើយនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ នៅផ្ទះរបស់លោក **ខ** នោះតែម្តង ។

ក្នុងករណីខាងលើនេះយើងអាចកំណត់បាននូវចំណុចវិវាទថា តើលោក **ក** ពិតជាបានសងប្រាក់កម្ចីចំនួន ១០,០០០$ នៃកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ទៅឱ្យលោក **ខ** នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ មែនដែរឬទេ ?

### ២.២.២.៤ ការរៀបចំនូវភស្តុតាង

តុលាការអាចស្តាប់ពាក្យសុំ និង ការអះអាងរបស់ភាគីទាំងសងខាង ហើយអាចចេញដីកាសម្រេចទៅលើការស្នើសុំឱ្យពិនិត្យភស្តុតាង (ឧទាហរណ៍ៈ ដីកាសម្រេចទទួលយក ឬ មិនទទួលយកនូវភស្តុតាងដែលត្រូវបានស្នើសុំឱ្យពិនិត្យ ដីកាសម្រេចបង្គាប់ឱ្យធ្វើកោសលវិច័យ ដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ) ជាអាទិ៍។[70] ម្យ៉ាងទៀត តុលាការក៏អាចធ្វើការពិនិត្យទៅលើភស្តុតាងជាឯកសារ ត្រឹមកម្រិតដែលចាំបាច់ដើម្បីរៀបចំចំណុចវិវាទ និង ភស្តុតាង បានដែរ។[71] ជាមូលដ្ឋាន ការពិនិត្យភស្តុតាង ត្រូវធ្វើឡើងនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដែលត្រូវបើកជាសាធារណៈទេ ក៏ប៉ុន្តែ ដើម្បីកំណត់នូវចំណុចវិវាទពិតប្រាកដ តាមរយៈការរៀបចំការអះអាងរបស់ភាគី តុលាការចាំបាច់ត្រូវធ្វើការពិនិត្យលើឯកសារដែលភាគីបានដាក់ ហើយការពិនិត្យភស្តុតាងជាឯកសារនេះ ត្រូវធ្វើឡើងដោយចៅក្រមអានឯកសារនោះ ហេតុដូច្នេះហើយ អត្ថន័យនៃការពិនិត្យភស្តុតាងជាឯកសារនេះ នៅក្នុងសាលសវនាការជាសាធារណៈមិនសំខាន់ដូចការសាកសួរសាក្សីនោះទេ។ ហេតុនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណី អនុញ្ញាតឱ្យតុលាការអាចពិនិត្យភស្តុតាងជាឯកសារ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ត្រឹមកម្រិតដែលចាំបាច់សម្រាប់រៀបចំចំណុចវិវាទ។ ឧទាហរណ៍ ក្នុងករណីដែលចុងចម្លើយតវ៉ា ចំពោះអង្គហេតុនៃការបង្កើតកិច្ចសន្យាលក់ទិញ ហើយព្រមជាមួយគ្នានោះ ចុងចម្លើយអះអាងថាទោះបីជាការបង្កើតកិច្ចសន្យាលក់ទិញនោះ ត្រូវបានទទួលស្គាល់ក៏ដោយ ក៏ខ្លួនលុបចោលកិច្ចសន្យានោះ ដោយហេតុថា ការបង្ហាញឆន្ទៈបង្កើតកិច្ចសន្យានោះ ត្រូវបានធ្វើឡើងដោយការឆបោក ប្រសិនបើការបង្កើតកិច្ចសន្យាលក់ទិញនោះ ត្រូវបានទទួលស្គាល់ ដោយពិនិត្យលិខិតកិច្ចសន្យានោះដែលដើមចោទដាក់ទៅតុលាការ នោះ

---

[70] មាត្រា ១២៦ មាត្រា ១៤៣ កថាខណ្ឌទី១ និងមាត្រា ១៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[71] មាត្រា ១០៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

តុលាការអាចប្រើវិធីនេះដើម្បីរៀបចំចំណុចវិវាទបាន។ ក៏ប៉ុន្តែ ចំពោះការពិនិត្យភស្តុតាង ដូចជាការសាកសួរសាក្សី និង កោសលវិច័យជាអាទិ៍ មិនអាចធ្វើឡើងបាននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ។[72]

### ២.២.៣ ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

#### ២.២.៣.១ ការបញ្ជាក់នូវអង្គហេតុដែលត្រូវបំភ្លឺ

ពេលដែលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់នូវការរៀបចំចំណុចវិវាទ និង ភស្តុតាងរួចហើយ តុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគីទាំងសងខាង អំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់តាមរយៈការពិនិត្យភស្តុតាងនៅពេលក្រោយ ។[73] បាននំយថាតុលាការ និងភាគីសងខាង ត្រូវធ្វើការបញ្ជាក់ថាតើ អង្គហេតុណាខ្លះដែលជាចំណុចវិវាទហើយ ដែលត្រូវក្លាយជាកម្មវត្ថុនៃការពិនិត្យ ភស្តុតាង ហើយតុលាការ និង ភាគីទាំងសងខាងត្រូវមានការទទួលស្គាល់រួមគ្នាចំពោះបញ្ហានេះ ដើម្បីអាចធ្វើការពិនិត្យភស្តុតាងដោយសមូហវិធី នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន ។[74]

#### ២.២.៣.២ ការកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីមកចូលរួម។[75]

#### ២.២.៣.៣ អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ក្រោយពីបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួនថ្មីបានទៀតទេ លើកលែងតែក្នុងករណីដែលមធ្យោបាយនោះ ទាក់ទងនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន ឬ ករណីដែលការដាក់មធ្យោបាយថ្មីនោះមិនធ្វើឱ្យមានការយឺតយ៉ាវដល់នីតិវិធីនៃបណ្តឹង ឬករណីដែលភាគីបានធ្វើសេចក្តីបញ្ជាក់ដំបូងថា ខ្លួនមិនអាចដាក់មធ្យោបាយនោះ មុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយគ្មានកំហុសធ្ងន់បានឡើយ ។[76]

---

[72] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៨៤ និង ៨៥

[73] មាត្រា១០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[74] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៨៦

[75] មាត្រា១១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[76] មាត្រា១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

# ជំពូកទី៣
# នីតិវិធីក្នុងពេលសវនាការ

## ៣.១ នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់

### ៣.១.១ អត្ថន័យនៃការទាញហេតុផលដោយផ្ទាល់មាត់

ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាទម្រង់មួយនៃការជម្រះក្តី ដែលក្នុងនោះ សកម្មភាពរបស់តុលាការ និង សកម្មភាពរបស់ភាគី ចំពោះការជម្រះក្តីនោះ ត្រូវធ្វើឡើងតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ ការស្តាប់សេចក្តីថ្លែងការណ៍នោះ នៅសាលសវនាការដែលបើកចំហជាសាធារណៈ នៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមានបាន។[77]

### ៣.១.២ ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់

ជាគោលការណ៍ ការសម្រេចសេចក្តីទៅលើបណ្តឹងរដ្ឋប្បវេណីចាំបាច់ត្រូវតែធ្វើតាមរយៈនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។ ប៉ុន្តែ ក៏មានបណ្តឹងមួយចំនួនសម្រេចសេចក្តីដោយមិនចាំបាច់ធ្វើតាមរយៈនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នោះទេ។ ដូចជា ក្នុងករណីដែលបណ្តឹងមានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះនោះមិនអាចកែតម្រូវបាន តុលាការអាចលើកបណ្តឹងនោះចោលដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់។[78] ក្នុងករណីដែលបានរៀបរាប់ខាងលើនេះ គឺជាការចេញសាលក្រមដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែក្នុងករណីដែលចាំបាច់ត្រូវធ្វើការជម្រះក្តីដោយឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ មានតែអ្វីៗដែលត្រូវបានបង្ហាញក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ឬលទ្ធផលនៃការពិនិត្យភស្តុតាងដែលបានធ្វើឡើងនៅពេលទាញហេតុផលដោយផ្ទាល់មាត់ប៉ុណ្ណោះ ដែលតុលាការអាចយកមកធ្វើជាមូលដ្ឋាននៃការចេញសាលក្រមបាន។[79] ប៉ុន្តែចំពោះសេចក្តីសម្រេចដែលតុលាការចេញក្រោមទម្រង់ជាដីកាសម្រេចមានដូចជា ការបញ្ជូនរឿងក្តី និងការដកហូតសមត្ថកិច្ចជំនុំជម្រះ ឬបណ្តឹងជិតចិត្តចៅក្រម ឬក៏រឿងក្តីដែលត្រូវសម្រេចដោយដីកាសម្រេច មានដូចជា នីតិវិធីដាស់តឿន និងនីតិវិធីរក្សាការពារជាអាទិ៍ ទុកឱ្យតុលាការជាអ្នកសម្រេចដោយឆន្ទានុសិទ្ធិថា ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ។[80] ហេតុដែលដីកាសម្រេចអាចធ្វើការឆ្លងការទាញហេតុផលដោយផ្ទាល់មាត់ក៏បាន ឬអត់ក៏បាន ដោយសារការសម្រេចដោយដីកាសម្រេច គឺជាបញ្ហាបន្ទាប់បន្សំដែលមិនប៉ះពាល់ធ្ងន់ធ្ងរ

[77] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៨៧ និង ៨៨។

[78] មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[79] មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[80] មាត្រា ១១៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ឬជាបញ្ហាដើម្បីជំនុំជម្រះឱ្យបានឆាប់រហ័ស។ នៅក្នុងករណីនេះ ទោះបីតុលាការបើកការទាញហេតុផលដោយផ្ទាល់មាត់ក៏ដោយ ត្រូវចាត់ទុកថានោះគឺជាការទាញហេតុផលដោយផ្ទាល់មាត់តាមការស្ម័គ្រចិត្ត ហើយចំពោះឯកសារផ្សេង ដែលត្រូវបានដាក់ជាលាយលក្ខណ៍អក្សរ ក្រៅពីអ្វីដែលត្រូវបានបង្ហាញនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចយកមកធ្វើជាមូលដ្ឋានក្នុងការសម្រេចសេចក្ដីបាន។ ប្រសិនបើមិនបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការនឹងធ្វើការជម្រះសេចក្ដីដោយឯកសារ។ នៅក្នុងករណីនេះ ប្រសិនបើចាំបាច់ តុលាការអាចកោះហៅភាគីមកសួរដោយផ្ទាល់បាន។ នីតិវិធីនេះ គេហៅថា "ការសួរ" ។[81]

### ៣.១.៣ ដំណើរការក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់

#### ៣.១.៣.១ សេចក្ដីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល

នៅក្នុងដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាដំបូងភាគីត្រូវធ្វើសេចក្ដីថ្លែងការណ៍ អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។[82] ដោយហេតុថា សកម្មភាពទាំងឡាយដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ធ្វើការទាញហេតុផល ត្រូវបានលើកឡើងរួមគ្នា នៅក្នុងដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីយកមកធ្វើជាមូលដ្ឋាននៃការចេញសាលក្រម ដោយចាត់ទុកថា សកម្មភាពទាំងនោះវាសមមូលទៅនឹងសកម្មភាពដែលធ្វើនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងតុលាការ។[83] ដោយការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមទាញហេតុផលដែលខ្លឹមសាររបស់វា មានលក្ខណៈប្រហាក់ប្រហែលទៅនឹងការហាត់សមធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែរ ប៉ុន្តែវាមិនអាចជំនួសឱ្យការទាញហេតុផលដោយផ្ទាល់មាត់បានទេ។ ជាគោលការណ៍ ការជម្រះក្ដីលើបណ្ដឹង ត្រូវធ្វើឡើងដោយការទាញហេតុផលដោយផ្ទាល់មាត់។[84]ម្យ៉ាងវិញទៀត ការធ្វើសេចក្ដីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ភាគីត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីអង្គហេតុដែលត្រូវបញ្ជាក់ តាមរយៈការពិនិត្យភស្តុតាងដែលនឹងត្រូវធ្វើក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាពិសេសអង្គហេតុដែលជាចំណុចវិវាទ។[85] គួរកត់សម្គាល់ថាទោះបីជាតុលាការ និងភាគីបានដឹងហើយថា សកម្មភាពណាខ្លះដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផលក៏ដោយ ក៏សកម្មភាពទាំងនោះមិនអាចនឹងយកមកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ ដោយហេតុថា តុលាការមិនបានធ្វើជាសាធារណៈនៅក្នុងនីតិវិធីត្រៀម

---

[81] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគីទី១ ទំព័រទី ៧១ និង ៧២

[82] មាត្រា ១១៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[83] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគីទី១ ទំព័រទី ៨៨

[84] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគីទី១ ទំព័រទី ៨៧

[85] មាត្រា ១១៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

សម្រាប់ការទាញហេតុផលទេ ហើយក្នុងនោះក៏មានករណីចៅក្រមដែលនឹងចេញសាលក្រម មិនមែនជាចៅក្រមដែលបានធ្វើនីតិវិធីត្រៀមសម្រាប់ទាញហេតុផលដែរ។ បន្ថែមពីនេះ ចំពោះសកម្មភាពដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនចាំបាច់ធ្វើឡើងវិញនោះទេ ដោយគ្រាន់តែធ្វើសេចក្តីថ្លែងការណ៍សរុបជាការគ្រប់គ្រាន់ហើយ។[86]

**៣.១.៣.២ ការពិនិត្យភស្តុតាង**

ការពិនិត្យភស្តុតាង គឺជានីតិវិធីដើម្បីទទួលបាននូវធនធានភស្តុតាង ដូចជាចម្លើយជាកសិណសាក្សី មតិយោបល់នៃកោសលវិច័យ សេចក្តីថ្លែងការណ៍របស់សាមីភាគី ខ្លឹមសារដែលសរសេរក្នុងឯកសារ លទ្ធផលនៃការពិនិត្យជាអាទិ៍ មកពីវិធីភស្តុតាង ដូចជាសាក្សី អ្នកធ្វើកោសលវិច័យ សាមីភាគី ឯកសារ ឬ វត្ថុដែលត្រូវបានពិនិត្យជាអាទិ៍។[87]

ជាគោលការណ៍ ការពិនិត្យភស្តុតាងត្រូវធ្វើតាមពាក្យសុំរបស់ភាគី ប៉ុន្តែប្រសិនបើតុលាការមិនអាចធ្វើការវិនិច្ឆ័យថាត្រូវទទួលស្គាល់ ឬមិនទទួលស្គាល់នូវភាពពិតនៃការអះអាងអំពីអង្គហេតុ ដោយភស្តុតាងដែលភាគីបានស្នើសុំឱ្យពិនិត្យ ឬប្រសិនបើយល់ឃើញថាមានការចាំបាច់ផ្សេងទៀត តុលាការអាចធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិបាន។[88]

**៣.១.៣.២.១ ការសាកសួរសាក្សី**

សាក្សី គឺជាតតិយជនដែលតុលាការបង្គាប់ឱ្យធ្វើសេចក្តីរាយការណ៍ជូនតុលាការ ស្តីពីអង្គហេតុពីអតីតកាលដែលខ្លួនបានជួបប្រទះដោយខ្លួនឯង នៅក្រៅបណ្តឹង។ ជាគោលការណ៍ តុលាការការអាចសាកសួរជនណាក៏បាន។ សេចក្តីថ្លែងការណ៍របស់សាក្សី គេហៅថា ចម្លើយជា កសិណសាក្សី ហើយការពិនិត្យភស្តុតាងដើម្បីយកចម្លើយជាកសិណសាក្សីនោះ ធ្វើជាធនធានភស្តុតាង គឺជាការសាកសួរសាក្សី។ តុលាការអាចបង្គាប់ឱ្យនាំសាក្សីដែលមិនព្រមចូលមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ ដោយដីកាសម្រេចបាន។ លើសពីនេះទៅទៀត ប្រសិនបើសាក្សីមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១,០០០,០០០ (មួយលាន) រៀល បានដោយដីកាសម្រេច ។[89] ហេតុនេះគ្រប់បុគ្គលដែលត្រូវបានតុលាការកោះហៅក្នុងឋានៈជាសាក្សី គឺត្រូវចូលទៅផ្តល់ចម្លើយជូនតុលាការ ប៉ុន្តែតុលាការអាចសាកសួរសាក្សីនៅក្រៅតុលាការបានប្រសិនបើមានមូលហេតុពិសេសមួយចំនួន។[90] ជាគោលការណ៍ សាក្សីត្រូវធ្វើសម្បថមុនពេលផ្តល់

[86] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគីទី១ ទំព័រទី ៨៨

[87] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគីទី១ ទំព័រទី ១០៧

[88] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគីទី១ ទំព័រទី ១០៧

[89] មាត្រា ១៣២ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[90] មាត្រា ១៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ចម្លើយ លើកលែងតែសាក្សីជាជនដែលមានអាយុក្រោម ១៦ឆ្នាំ ឬជនមិនយល់ពីអត្ថន័យនៃសម្បថ។[91] មួយវិញទៀត សាក្សីក៏អាចធ្វើការបដិសេធមិនផ្តល់ចម្លើយបានផងដែរ ប្រសិនបើការផ្តល់ចម្លើយជាកសិណសាក្សីទាក់ទងនឹងហេតុដែលធ្វើឱ្យសហព័ទ្ធរបស់សាក្សី ឬ ញាតិផ្សេងទៀតរបស់សាក្សីអាចទទួលរងការចោទប្រកាន់អំពីបទអាជ្ញា ឬទទួលការផ្តន្ទាទោស ឬធ្វើឱ្យប៉ះពាល់ដល់កិត្តិយស ឬបណ្តាលឱ្យមានការបែកបាក់ធ្ងន់ធ្ងរដល់ទំនាក់ទំនងគ្រួសារ ជាអាទិ៍។[92] ការសាកសួរសាក្សី គឺជាការស្នើសុំ ហើយកំណត់ឱ្យបានច្បាស់ថាតើសួរសាក្សីណាមួយ ដោយអ្នកស្នើសុំត្រូវភ្ជាប់មកជាមួយនូវឯកសារដែលកំណត់អំពីចំណុចត្រូវសាកសួរ។ ទោះបីជាយ៉ាងណាក៏ដោយ ការសាកសួរសាក្សីនេះ គឺត្រូវបានកម្រិតទៅលើសំណួរមួយចំនួនដែលមិនអនុញ្ញាតឱ្យសួរ ដូចជា សំណួរដែលប្រមាថមើលងាយ ឬធ្វើឱ្យច្របូកច្របល់ដល់សាក្សី សំណួរនាំមុខ សំណួរច្រំដែល សំណួរដែលគ្មានទំនាក់ទំនងនឹងចំណុចវិវាទ សំណួរដែលទាមទារឱ្យថ្លែងយោបល់របស់សាក្សីផ្ទាល់ខ្លួន និងសំណួរដែលទាមទារឱ្យថ្លែងយោបល់អំពីអង្គហេតុដែលសាក្សីពុំបានជួបប្រទះផ្ទាល់ ហើយចំពោះសំណួរ បើអាចធ្វើបានត្រូវដាច់ដោយឡែក និងច្បាស់លាស់។[93]

### ៣.១.៣.២.២ ការសាកសួរសាមីភាគី

ការសាកសួរភាគី គឺជាការពិនិត្យភស្តុតាងដែលធ្វើឡើងដោយតុលាការ ដើម្បីទទួលបាននូវធនធានភស្តុតាង ដើម្បីឱ្យភាគីធ្វើសេចក្តីថ្លែងការណ៍អំពីអង្គហេតុដែលខ្លួនបានជួបផ្ទាល់តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់តុលាការ។ ការសាកសួរភាគី គឺជានីតិវិធីដែលមានគោលបំណងទទួលយកនូវធនធានភស្តុតាងដោយយកសាមីភាគីជាកម្មវត្ថុនៃការពិនិត្យ ជាគោលការណ៍ភាគីដែលលើកឡើងអំពីអង្គហេតុដែលមានវិវាទត្រូវទទួលបន្ទុកបង្ហាញភស្តុតាង លើកលែងតែជនដែលច្បាប់សន្មតថាមានកំហុស។[94] ជាក់ស្តែងដូចជា អ្នកដឹកជញ្ជូនត្រូវរកភស្តុតាងបង្ហាញថា ខ្លួនគ្មានកំហុសក្នុងការធ្វើឱ្យខូចខាតចំពោះការដឹកជញ្ជូនទេ។ វិធានដែលប្រើចំពោះការសាកសួរសាក្សី ភាគីអនុវត្តដូចគ្នានឹងបញ្ញត្តិស្តីពីការសាកសួរសាក្សីផងដែរ។[95] លើសពីនេះទៅទៀត ក្នុងករណីដែលធ្វើការសាកសួរសាមីភាគី បើភាគីនោះពុំចូលខ្លួន ឬបដិសេធនូវការធ្វើសម្បថ ឬផ្តល់ចម្លើយដោយគ្មានមូលហេតុត្រឹមត្រូវនោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀត ជាការពិតបាន។ ហើយប្រសិនបើ ភាគីដែលបានស្បថបន្លំសេចក្តីថ្លែងការណ៍ តុលាការអាចធ្វើការពិន័យជាប្រាក់

[91] មាត្រា ១៣៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[92] មាត្រា ១៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[93] មាត្រា ១៣៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[94] ប្រសាសន៍របស់ឯកឧត្តម ហ៊ី សោភា នាពេលបង្រៀននីតិវិធីរដ្ឋប្បវេណី នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

[95] មាត្រា ១៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ចំនួនមិនលើសពី ២,០០០,០០០ (ពីរលាន) រៀល បានដោយដីកាសម្រេច។[96] បញ្ញត្តិអំពីការសាកសួរសាមីនៅក្នុងក្រមនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ ហើយធ្វើជាអ្នកតំណាងរបស់ភាគីនៅក្នុងបណ្តឹ ពីព្រោះថា អ្នកតំណាងនេះធ្វើសកម្មភាពទាំងស្រុងជំនួសអសមត្ថជននៅក្នុងដំណើរការនៃនីតិវិធីបណ្តឹង។[97]

### ៣.១.៣.២.៣ កោសលវិច័យ

កោសលវិច័យ គឺជាការពិនិត្យភស្តុតាងដែលតុលាការកំណត់ឱ្យតតិយជន (អ្នកជំនាញខាងកោសលវិច័យ) ដែលមានចំណេះវិជ្ជា និង បទពិសោធន៍ពិសេស ឱ្យធ្វើរបាយការណ៍អំពីវិធានតាមបទពិសោធន៍ដែលខ្លួនបានដឹងតាមចំណេះវិជ្ជារបស់ខ្លួន ឬ ធ្វើរបាយការណ៍អំពីការវិនិច្ឆ័យ ឬ យោបល់ដែលបានមកពីការអនុវត្តវិធានតាមបទពិសោធន៍ជំនាញ ចំពោះអង្គហេតុជាក់ស្តែងដែលជាបញ្ហានៅក្នុងបណ្តឹងនោះ។[98]

### ៣.១.៣.២.៣ ភស្តុតាងជាឯកសារ

ទូទៅ វត្ថុអរូបិយ (មិនត្រឹមតែជាក្រដាសទេ រួមទាំងវត្ថុធ្វើពីឈើជាដើម) ដែលបង្ហាញនូវទស្សនៈកំណត់មួយរបស់ បុគ្គលណាមួយកំណត់ ដោយអក្សរ ឬដោយសញ្ញាផ្សេង (ឧទាហរណ៍ អក្សរសម្រាប់អ្នកពិការភ្នែក) គេហៅថា ឯកសារ។ ការពិនិត្យភស្តុតាងជា ឯកសារ គឺជាការពិនិត្យភស្តុតាងដោយអានឯកសារ ហើយយកខ្លឹមសារដែលសរសេរនៅក្នុងនោះ មកធ្វើជាធនធានភស្តុតាង។[99] ជាគោលការណ៍ ការពិនិត្យភស្តុតាងជាឯកសារ គឺអាចធ្វើឱ្យផ្តល់នូវ ឯកសារដែលភាគីមាន ឬដោយដាក់ពាក្យសុំទៅតុលាការឱ្យបង្គាប់ដល់ម្ចាស់ឯកសារផ្តល់ឯកសារនោះមក ហើយបុគ្គលជាម្ចាស់ឯកសារ ត្រូវប្រគល់ឯកសារជូនទៅតុលាការ លើកលែងតែមានករណីពិសេស បើម្ចាស់ឯកសារមិនព្រមប្រគល់ជូនតុលាការ ឬធ្វើឱ្យវិនាសបាត់បង់ឯកសារដែលខ្លួនមាន គឺតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងរបស់ភាគីម្ខាងទៀតដែលពាក់ព័ន្ធនឹងខ្លឹមសារនោះជាការពិតបាន។[100]

### ៣.១.៣.២.៤ ការត្រួតពិនិត្យ

ការត្រួតពិនិត្យ គឺជាការពិនិត្យភស្តុតាងដោយការត្រួតពិនិត្យនូវភិនភាគ ឬបាតុភូតនៃវត្ថុដោយផ្ទាល់ដោយចៅក្រមតាមរយៈវិញ្ញាណទាំងប្រាំ (ចក្ខុវិញ្ញាណ, សោតវិញ្ញាណ, កាយវិញ្ញាណ, ឃានវិញ្ញាណ, ជិវ្ហាវិញ្ញាណ) ហើយវត្ថុ ឬមនុស្ស ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យនោះ គេហៅថា វត្ថុដែលត្រូវត្រួតពិនិត្យ។[101]

---

[96] មាត្រា ១៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[97] មាត្រា ១៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[98] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគីទី១ ទំព័រទី ១០៩

[99] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ១១០

[100] មាត្រា ១៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[101] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគីទី១ ទំព័រទី ១១២

### ៣.១.៣.៣ ការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន

ការអះអាងបន្ថែមអំពីអង្គហេតុ និងដាក់ភស្តុតាងថ្មី ភាគីអាចធ្វើទៅបានបន្ទាប់ពីបានធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ពោលគឺនៅក្នុងដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែមិនត្រូវឱ្យផ្ទុយនឹងបទបញ្ញត្តិនៃមាត្រា ១០៨ ឡើយ។[102] ចំពោះមធ្យោបាយការអះអាង និងដាក់ភស្តុតាងថ្មី ដែលអាចដាក់បាន គឺមានតែមធ្យោបាយមួយចំនួនប៉ុណ្ណោះ ដែលក្នុងនោះមានដូចជា ការអះអាង និងដាក់ភស្តុតាងថ្មី ដែលពាក់ព័ន្ធទៅនឹងបញ្ហាដែលតុលាការត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន ការអះអាង និងដាក់ភស្តុតាងថ្មី ដែលមិនបង្កឱ្យមានការយឺតយ៉ាវខ្លាំងទៅដល់នីតិវិធីការអះអាង និងដាក់ភស្តុតាងថ្មី ដែលភាគីបាន ធ្វើសេចក្តីបញ្ជាក់ពីដំបូងថា ការមិនអាចដាក់មធ្យោបាយនោះនៅមុនការបញ្ចប់នីតិវិធីត្រៀមសម្រាប់ ការទាញហេតុផលបាន មិនបណ្តាលមកពីកំហុសធ្ងន់ធ្ងរឡើយ។ នៅក្នុងករណីដែលភាគីធ្វើការ អះអាង និងដាក់ភស្តុតាងថ្មី ភាគីត្រូវដាក់មធ្យោបាយទាំងនោះ នៅក្នុងរយៈពេលមួយដែលសមរម្យ នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់។[103] ប៉ុន្តែប្រសិនបើ ភាគីធ្វើការអះអាង និងដាក់ភស្តុតាងថ្មី មិនបានដាក់នៅក្នុងរយៈពេលមួយសមរម្យទេនោះ ហើយធ្វើមានការយឺតយ៉ាវដល់ការបញ្ចប់ នីតិវិធីដោយកំហុសធ្ងន់ធ្ងរ និងជាចេតនារបស់ភាគី តុលាការអាចចេញដីកាសម្រេចលើកចោល មធ្យោបាយតទល់ ដែលជាការអះអាង និងដាក់ភស្តុតាងថ្មី តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់តុលាការ។[104]

យើងគួរកត់សម្គាល់ផងដែរថា មធ្យោបាយតទល់ស្តីអំពីការអះអាង និងដាក់ភស្តុតាងថ្មី មិនត្រូវបានកំណត់នៅក្នុងដំណាក់កាលណាមួយជាក់លាក់នោះទេ នៅក្នុងដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ ពោលគឺ មធ្យោបាយទាំងនោះអាចនឹងត្រូវមានការអូសបន្លាយពេលទៅកាលបរិច្ឆេទណាមួយផ្សេងទៀត។ ប៉ុន្តែគេមិនចាត់ទុក ការលើកមធ្យោបាយទាំងនោះជាដំណាក់កាលផ្សេងក្រៅអំពីនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់នោះទេ គឺត្រូវចាត់ទុកថា បានធ្វើនៅក្នុងដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ទាំងមូលតែម្តង។ ហើយកិច្ចទាំងនេះយើងអាចហៅបានថាភាពតែមួយ នៃការទាញហេតុផលដោយផ្ទាល់មាត់ ។

ក្នុងករណីដែលមានការដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មី តុលាការត្រូវរៀបចំនូវចំណុចវិវាទ និងភស្តុតាង នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ តែត្រឹមទំហំនៃមធ្យោបាយនោះតែប៉ុណ្ណោះ។ ហេតុដូច្នេះហើយ នៅពេលចំណុចវិវាទ និង ភស្តុតាងដែលត្រូវពិនិត្យត្រូវបានកំណត់នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញ

[102] មាត្រា ១១៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[103] មាត្រា ៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[104] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគីទី១ ទំព័រទី ៨៩

ហេតុផល និង នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់តែម្តង នោះតុលាការត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការពិនិត្យភស្តុតាង កោះហៅគូភាគីឱ្យចូលរួមនៅក្នុងការពិនិត្យភស្តុតាង។[105]

#### ៣.១.៣.៤ ការបំបែក និង ការបញ្ចូលសំណុំរឿង

នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចបង្គាប់ឱ្យបំបែក ឬ បញ្ចូលរឿងក្តីដោយដីការសម្រេច ហើយក៏អាចលុបចោលសេចក្តីសម្រេចនេះបានដែរ។[106] ម្យ៉ាងទៀត ប្រសិនបើតុលាការបានបង្គាប់ឱ្យបញ្ចូលរឿងក្តីដែលមានភាគីខុសគ្នា នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅពេលដែលភាគីដែលមិនមានឱកាសបានសាកសួរសាក្សី ដោយមូលហេតុថាសាក្សីនោះត្រូវបានសាកសួររួចហើយនៅមុនពេលបញ្ចូលរឿងក្តី នោះភាគីអាចដាក់ពាក្យសុំឱ្យសាកសួរសាក្សីនោះ ហើយតុលាការត្រូវសាកសួរសាក្សីតាមពាក្យសុំ។[107]

#### ៣.១.៣.៥ ការបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

បន្ទាប់ពីបានបញ្ចប់ការពិនិត្យភស្តុតាងហើយ តុលាការ ដែលអាចនឹងមានជំនឿទុកចិត្តទៅលើទំនាក់ទំនងអង្គហេតុនៃរឿងក្តីតាមរយៈការពិនិត្យភស្តុតាងនេះ ឬ ដោយផ្អែកតាមគោលការណ៍នៃទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវមានតួនាទីចេញសាលក្រមទៅលើភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវ ចំពោះការទាមទាររបស់ដើមចោទ។ នៅពេលនោះ តុលាការត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ចេញសាលក្រមចុងក្រោយ។[108]

## ៣.២ ការប្រកាសសាលក្រម

### ៣.២.១ អត្ថន័យនៃសាលក្រមចុងក្រោយ

ដោយព្រោះបណ្តឹងត្រូវបានចាប់ផ្តើម ដោយការទាមទាររបស់ដើមចោទ តាមរយៈពាក្យបណ្តឹងសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារកំណត់ណាមួយ ជាគោលការណ៍ បណ្តឹងត្រូវបញ្ចប់ដោយសាលក្រមរបស់តុលាការដែលជាការឆ្លើយតបចំពោះការទាមទារដើមចោទនោះ។[109]

នៅពេលដែលការវិនិច្ឆ័យចប់ ជាមួយការបញ្ចប់នូវការទាញហេតុផល និង ការពិនិត្យភស្តុតាង តុលាការត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ កំណត់កាលបរិច្ឆេទសម្រាប់ការប្រកាសសាលក្រម និង ត្រូវប្រកាសសាលក្រម។ ពេលដែលសាលក្រមនោះចូលជាស្ថាពរ គោលដៅនៃបណ្តឹងក៏ត្រូវបានសម្រេច ហើយ

---

[105] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគីទី១ ទំព័រទី ៨៩

[106] មាត្រា ៩៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[107] មាត្រា ៩៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[108] មាត្រា ១៨០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[109] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ១២៨

បណ្តឹងនោះត្រូវបញ្ចប់។ ក៏ប៉ុន្តែ សាលក្រមដែលមានអានុភាពបញ្ចប់បណ្តឹង ចាំបាច់ត្រូវជាសាលក្រមបញ្ចប់រឿងក្តីទាំងមូល ឬ មួយភាគ។[110]

### ៣.២.២ ប្រភេទនៃសាលក្រមចុងក្រោយ

សាលក្រមដែលបញ្ចប់រឿងក្តីទាំងមូល ឬ មួយភាគនោះគេហៅថា សាលក្រមចុងក្រោយ។ សាលក្រមចុងក្រោយ អាចបែងចែកជាប្រភេទដូចតទៅៈ

សាលក្រមចុងក្រោយប្រភេទទីមួយ គឺជាសាលក្រមលើកបណ្តឹងចោល ដោយមិនធ្វើការវិនិច្ឆ័យទៅលើភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទារ ដោយមកពីមូលហេតុខ្វះល័ក្ខខណ្ឌបណ្តឹង។ នៅក្នុងករណីនេះដោយព្រោះបណ្តឹងចប់ភ្លាមបន្ទាប់ពីការវិនិច្ឆ័យទៅលើអត្ថិភាព ឬ នត្ថិភាពនៃល័ក្ខខណ្ឌបណ្តឹង សាលក្រមបែបនេះ គេហៅថា "សាលក្រមនីតិវិធី"។

សាលក្រមប្រភេទទីពីរ គឺជាសាលក្រមទទួលស្គាល់ការទាមទាររបស់ដើមចោទ ចំពោះបណ្តឹងដែលគ្មានភាពខ្វះខាតនៃល័ក្ខខណ្ឌបណ្តឹង។ សាលក្រមប្រភេទនេះហៅថា "សាលក្រមទទួលស្គាល់ការទាមទារ"។

សាលក្រមទីបី គឺជាសាលក្រមសម្រេចមិនទទួលស្គាល់ការទាមទាររបស់ដើមចោទ ចំពោះបណ្តឹងដែលគ្មានភាពខ្វះខាតនៃល័ក្ខខណ្ឌបណ្តឹង។ សាលក្រមបែបនេះហៅថា "សាលក្រមច្រានចោលការទាមទារ"។

សាលក្រមទទួលស្គាល់ការទាមទារ និង សាលក្រមច្រានចោលការទាមទារ គេហៅរួមថា "សាលក្រមលើអង្គសេចក្តី"។ សាលក្រមទាំងពីរនេះ គឺជាសាលក្រមបង្ហាញអំពីការសម្រេចសេចក្តីរបស់តុលាការស្តីភាពភាពត្រឹមត្រូវនៃការទាមទារ ដែលជាកម្មវត្ថុដើមនៃបណ្តឹង ហើយដោយបែបនោះ សាលក្រមទាំងនោះខុសគ្នាពីសាលក្រមលើបណ្តឹង ដែលមានតែការវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពនៃល័ក្ខខណ្ឌបណ្តឹងប៉ុណ្ណោះ។ ហេតុដូច្នេះគេហៅថា សាលក្រមលើអង្គសេចក្តី ក្នុងន័យថាជាសាលក្រមដែលសម្រេចអំពីអង្គសេចក្តីនៃរឿងក្តី។[111]

### ៣.២.៣ ការបង្កើតសាលក្រម

#### ៣.២.៣.១ ការបង្កើតខ្លឹមសារនៃសាលក្រម

ជាគោលការណ៍ សាលក្រមត្រូវធ្វើឡើងដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ ។ ហេតុនេះហើយខ្លឹមសារនៃសាលក្រមត្រូវបានបង្កើតឡើងដោយយកធនធាននៃបណ្តឹង ដែលត្រូវបានដាក់ក្នុងការទាញហេតុផលដោយផ្ទាល់មាត់ នៅមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។ ពេលណាខ្លឹមសារនៃសាលក្រមនោះត្រូវបានបង្កើតឡើងហើយ ខ្លឹមសារទាំងនោះត្រូវសរសេរបង្ហាញក្នុងលិខិតសាលក្រម តាមទម្រង់

[110] មាត្រា១៨០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[111] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ១២៨

ដែលមានចែងក្នុងមាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ចំណុចដូចខាងក្រោម ត្រូវសរសេរក្នុងលិខិតសាលក្រម។ ការពន្យល់ខាងក្រោម មានទំនាក់ទំនងយ៉ាងសំខាន់ទៅនឹងសាលក្រមចុងក្រោយ។

១. តុលាការ

២. ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

៣. ភាគី (ភាគី និង អ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងករណីដែលមានអ្នកតំណាងដែលច្បាប់បានកំណត់)

៤. អង្គហេតុ និង ចំណុចវិវាទ

៥. សំអាងហេតុ

៦. សេចក្តីសម្រេចបញ្ចប់។[112]

### ៣.២.៣.២ ការបង្កើតលិខិតសាលក្រម

#### ក. អង្គហេតុ និងចំណុចវិវាទ

ជាបឋម ត្រូវសរសេរអំពីការទាមទាររបស់ដើមចោទ បន្ទាប់មក ត្រូវសង្ខេបរឿងក្តីនោះ ដោយបញ្ជាក់ថាតើរឿងក្តីនោះជាបណ្តឹងដែលទាក់ទងនឹងការទាមទារអ្វី។ បន្ទាប់មកទៀត សរសេរបញ្ជាក់អំពីអង្គហេតុដែលគ្មានវិវាទ និង រៀបរាប់អំពីចំណុចវិវាទដែលជាបញ្ហារវាងភាគីដោយផ្អែកលើលទ្ធផលនៃការរៀបចំនូវការអះអាងរបស់ភាគី ក្នុងដំណាក់កាលនៃការវិនិច្ឆ័យ។[113]

#### ខ. សំអាងហេតុ

ត្រូវចុះអំពីការវិនិច្ឆ័យរបស់តុលាការចំពោះចំណុចវិវាទ។ ឧទាហរណ៍ ក្នុងរឿងក្តីដែល A បានទាមទារឱ្យ B សងប្រាក់កម្ចី ១០ លានរៀល តែ B បានអះអាងតវ៉ាថា ខ្លួនបានសងរួចហើយ តុលាការត្រូវសរសេរចូលថាតើតុលាការទទួលស្គាល់អង្គហេតុសងប្រាក់ ដោយភស្តុតាងអ្វីខ្លះ ឬ ត្រូវសរសេរអំពីលទ្ធផលនៃការអនុវត្ត ឬ ការបកស្រាយក្រមរដ្ឋប្បវេណី ចំពោះចំណុចវិវាទតាមផ្លូវច្បាប់ ស្តីពីការសងនោះ ជាដើម។ ដូច្នេះហើយនៅ " សំអាងហេតុ " ត្រូវសរសេរបញ្ជាក់អំពីមូលហេតុ (សំអាងហេតុ) សម្រាប់ការវិនិច្ឆ័យចំពោះចំណុចវិវាទនេះ។[114]

#### គ. សេចក្តីសម្រេចបញ្ចប់

សេចក្តីសម្រេចបញ្ចប់ចុះអំពីការសរុបសេចក្តីចំពោះការវិនិច្ឆ័យរបស់តុលាការ មានន័យថា ជាការសរុបនូវការឆ្លើយតប ចំពោះការទាមទារនូវសាលក្រមដែលមានខ្លឹមសារកំណត់មួយ ដែលដើមចោទបានសរសេរក្នុងវគ្គ " ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ " នៃពាក្យបណ្តឹង។ ក្នុងករណីឧទាហរណ៍

[112] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ១៣១

[113] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ១៣២

[114] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ១៣២

ខាងលើ ប្រសិនបើតុលាការ ទទួលស្គាល់នូវការទាមទាររបស់ដើមចោទ ក្នុងវគ្គ " សេចក្តីសម្រេចបញ្ចប់ " តុលាការត្រូវសរសេរថា " ចុងចម្លើយត្រូវបង់ប្រាក់ ១០ លានរៀល ទៅដើមចោទ។ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់របស់ចុងចម្លើយ "។ ផ្ទុយទៅវិញ ប្រសិនបើតុលាការច្រានចោលនូវការទាមទាររបស់ដើមចោទវិញ តុលាការត្រូវសរសេរថា " ច្រានចោលនូវការទាមទាររបស់ដើមចោទ ។ ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ដើមចោទ " ។ ប្រសិនបើតុលាការភ្ជាប់នូវការប្រកាសឱ្យអនុវត្តបណ្តោះអាសន្ន ជាមួយនឹងសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិក តាមពាក្យសុំរបស់ភាគី ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន តុលាការត្រូវសរសេរនៅក្រោមសេចក្តីសម្រេចអំពីប្រាក់ប្រដាប់ក្តីនេះថា " ប្រសិនបើដើមចោទបានដាក់ប្រាតិភោគចំនួន ១០ ម៉ឺនរៀល សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបាន "។[115]

**ឃ. ចំណុចដទៃទៀត**

ត្រូវសរសេរចូលអំពីតុលាការ អំពីថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និង អំពីភាគី ។ ត្រូវកត់ចូលនូវឈ្មោះតុលាការដែលបានចេញសាលក្រម ឧទាហរណ៍ ដូចជា សាលាដំបូងរាជធានីភ្នំពេញ ជាដើម។ ការត្រូវចុះថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ គឺដើម្បីឱ្យបានច្បាស់លាស់អំពីមូលដ្ឋាននៃពេលវេលាសម្រាប់កំណត់នូវអាជ្ញាអស់ជំនុំនៃសាលក្រម។ ចៅក្រមដែលចេញសាលក្រម ត្រូវចុះហត្ថលេខា នៅក្នុងលិខិតសាលក្រមនោះ ។[116]

### ៣.២.៤ របៀបនៃការប្រកាសសាលក្រម

ក្រោយពីបានធ្វើលិខិតសាលក្រម តុលាការត្រូវប្រកាសសាលក្រមនោះ។ ជាគោលការណ៍ តុលាការត្រូវប្រកាស ក្នុងអំឡុងពេលមួយខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។[117]

ការប្រកាសសាលក្រមត្រូវធ្វើឡើងតាមកាលបរិច្ឆេទ នៅក្នុងសាលសវនាការដែលបើកជាសាធារណៈ ដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ជាអ្នកអានសេចក្តីសម្រេចបញ្ចប់ដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម ។ ក៏ប៉ុន្តែ ក្នុងករណីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះមានធុរៈ ចៅក្រមប្រឹក្សាអាចអានជំនួសបាន។

ការប្រកាសសាលក្រមអាចធ្វើបាន ទោះបីជាគ្មានវត្តមានរបស់ភាគីនៅក្នុងសាលសវនាការក៏ដោយ។

ប្រសិនបើយល់ឃើញថាសមរម្យ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអានសំអាងហេតុនៃសាលក្រម ឬអាចពន្យល់ខ្លឹមសារនៃសំអាងហេតុនេះដោយផ្ទាល់មាត់បាន។[118]

---

[115] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ១៣២

[116] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ១៣២ និង ១៣៣

[117] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ១៣៣

[118] មាត្រា ១៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

សាលក្រមនឹងមានអានុភាពដោយការប្រកាស។[119] ការប្រកាសសាលក្រមត្រូវធ្វើក្នុងអំឡុងពេល ១ (មួយ) ខែ គិតពីចាប់ពីថ្ងៃដែលបានបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះរឿងក្តីដែលមានភាពស្មុគស្មាញខ្លាំង ឬ មានកាលៈទេសៈពិសេសផ្សេងទៀត។[120] លើសពីការប្រកាសសាលក្រមនោះ គឺលិខិតសាលក្រមត្រូវបញ្ជូនទៅឱ្យគូភាគី ក្នុងអំឡុងពេល ២(ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រមនោះ។[121]

[119] មាត្រា១៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[120] មាត្រា១៨៧ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[121] មាត្រា១៩០ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយមកខាងលើ យើងអាចធ្វើការសន្និដ្ឋានបានថាការដំណើរការនីតិវិធីនៃការដោះស្រាយរឿងក្តីរដ្ឋប្បវេណី គឺជានីតិវិធីមួយដែលមានសារៈសំខាន់បំផុត និងជានីតិវិធីមួយដែលចៅក្រមត្រូវយល់ដឹងឱ្យបានស៊ីជម្រៅ ដោយសារតែនីតិវិធីនេះជានីតិវិធីមួយដែលមាននៅក្រមនីតិវិធីរដ្ឋប្បវេណី ដែលជាបទដ្ឋានគតិយុត្តសម្រាប់ចៅក្រម ក៏ដូចជាភាគីដែលត្រូវតែអនុវត្តតាម។ អ្វីដែលចៅក្រមត្រូវធ្វើជាចាំបាច់នៅក្នុងនីតិវិធីជំនុំជម្រះទី១នោះ គឺ ចៅក្រមត្រូវកំណត់ឱ្យបាននូវចំណុចវិវាទនៃរឿងក្តីតាមរយៈការរៀបចំការអះអាងរបស់គូភាគីនៃរឿងក្តី ព្រមទាំងរៀបចំនូវភស្តុតាងទាំងឡាយដែលទាក់ទងទៅនឹងចំណុចវិវាទនោះ ក្នុងគោលបំណងមួយដើម្បីឱ្យការដំណើរការនៃការទាញហេតុផលមានភាពឆាប់រហ័ស ងាយស្រួល និងមិនស្មុគស្មាញ ហើយនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់វិញ ចៅក្រមត្រូវពិនិត្យភស្តុតាងដែលបានរៀបចំរួចមកហើយនោះដើម្បីដោះស្រាយនូវចំណុចវិវាទដែលបានកំណត់នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

នៅក្នុងករណីដែលតុលាការដឹកនាំនីតិវិធីមិនបានល្អ ពោលគឺតុលាការមិនអាចកំណត់បាននូវចំណុចវិវាទក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានទេ វានឹងនាំឱ្យដំណើរការនៃការទាញហេតុផលដោយផ្ទាល់មាត់មានភាពស្មុគស្មាញ គ្មានគោលដៅក្នុងការដោះស្រាយ នាំឱ្យការដោះស្រាយវិវាទមានភាពយឺតយ៉ាវដោយសារតែការមិនយល់ស្របគ្នា ហើយតុលាការត្រូវបង្វិលនីតិវិធីពីការទាញហេតុផលដោយផ្ទាល់មាត់ទៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលវិញ។ ផ្ទុយទៅវិញប្រសិនបើតុលាការបានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានល្អ ពោលគឺតុលាការកំណត់បាននូវចំណុចវិវាទនៃរឿងក្តីបាន ហើយតុលាការបានរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនោះបានល្អ នោះការដំណើរការនៃការទាញហេតុផលដោយផ្ទាល់មាត់ នឹងមានភាពឆាប់រហ័សដំណើរការមានភាពងាយស្រួល ការដោះស្រាយរឿងក្តីមានគោលដៅ និងអាចផ្តល់យុត្តិធម៌ជូនគូភាគីបាន ។

ដូច្នេះ គ្រប់ដំណាក់កាលនៃនីតិវិធី សុទ្ធតែមានសារៈសំខាន់ ដែលទាមទារឱ្យចៅក្រម ក៏ដូចជាភាគីយល់ឱ្យច្បាស់អំពីនីតិវិធីនីមួយៗចាប់តាំងពីការដាក់ពាក្យបណ្តឹង រហូតដល់ការចេញសាលក្រមចុងក្រោយ ទើបការដោះស្រាយរឿងក្តីរដ្ឋប្បវេណីតាមរយៈប្រព័ន្ធតុលាការប្រកបទៅដោយរលូន។

# អនុសាសន៍

យើងបានសង្កេតឃើញថា នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ នៅក្នុងប្រទេសកម្ពុជាយើង នៅមិនទាន់បានយល់ដឹងផ្នែកច្បាប់ ក៏ដូចជានីតិវិធីច្បាប់ឱ្យបានទូលំទូលាយនៅឡើយទេ។ ថ្វីត្បិតតែច្បាប់បាន បង្កើតឡើងក៏ពិតមែន តែបើប្រជាពលរដ្ឋនៅមិនទាន់បានជ្រួតជ្រាបអំពីច្បាប់ នោះច្បាប់ក៏នៅមិនទាន់អាចធានា បាននូវសន្តិសុខក្នុងសង្គម ដែលជាហេតុធ្វើឱ្យកើតមានជម្លោះនៅក្នុងរឿងក្តីរដ្ឋប្បវេណីកើតមានច្រើនជាបន្តបន្ទាប់ ទាំងរឿងបណ្តឹងអង្គសេចក្តី រឿងក្តីរក្សាការពារ ក៏ដូចជារឿងក្តីអនុវត្តដោយបង្ខំ ជាដើម។

ដោយហេតុថា សារណានេះត្រូវបានស្រាវជ្រាវ និង ចងក្រងឡើងក្នុងរង្វង់ចំណុចនីតិវិធីបណ្តឹងតែ ប៉ុណ្ណោះ ដើម្បីបង្ហាញអំពីដំណើរការ នៃលំហូរនីតិវិធីជំនុំជម្រះលើកទី១ ដំណើរការទៅប្រកបដោយប្រសិទ្ធិភាព គុណភាព ឆាប់រហ័ស និងយុត្តិធម៌ ដោយតុលាការត្រូវធ្វើការសម្រេចសេចក្តីដោយគ្មានភាពយឺតយ៉ាវ ដែលមិន ធ្វើឱ្យមានការបាត់បង់នូវផលប្រយោជន៍របស់ភាគីនៃរឿងក្តី ពោលគឺ ដូចជាក្នុងដំណាក់កាលនៃ ការដាក់ពាក្យ បណ្តឹង នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ការទាញហេតុផលដោយផ្ទាល់មាត់ ជាដើម។ ហេតុដូច្នេះហើយ តុលាការ ក៏ដូចជាភាគីមានកាតព្វកិច្ច និងការទទួលខុសត្រូវមួយចំនួនដូចជា៖

- តុលាការ និង ភាគី ត្រូវគោរពតាមបទបញ្ញត្តិច្បាប់ដែលមានចែងជាធរមានឱ្យបានខ្ជាប់ខ្ជួន ដើម្បីធានានូវ ការគោរពសិទ្ធិ និង ផលប្រយោជន៍របស់ភាគី។
- តុលាការត្រូវមានចំណាត់ការទៅលើរឿងក្តីឱ្យបានឆាប់រហ័ស និង យុត្តិធម៌ ដើម្បីកុំឱ្យមានការកកស្ទះ សំណុំរឿងផងដែរ។
- នៅក្នុងកិច្ចនីតិវិធីជម្រះក្តីលើកទី១ នៅពេលដែលភាគីធ្វើសកម្មភាពនៅក្នុងកាលបរិច្ឆេទ នៃនីតិវិធី នីមួយៗ តុលាការត្រូវផ្តល់នូវសិទ្ធិស្មើគ្នាចំពោះភាគី ដូចជា ការផ្តល់សិទ្ធិឱ្យភាគីបានធ្វើការអះអាង, តវ៉ា ថ្លែងការណ៍, តទល់ និង ការបង្ហាញភស្តុតាងឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យតុលាការទទួលបាននូវគោល គំនិតពីសកម្មភាពដែលបានធ្វើឡើងនោះ សម្រាប់យកមកធ្វើជាមូលដ្ឋានក្នុងការពិចារណា និង វិនិច្ឆ័យ សម្រេចសេចក្តី ហើយនិងកុំឱ្យភាគីមានអារម្មណ៍ថា តុលាការបានរឹតត្បិតសិទ្ធិភាគីណាម្ខាងមិនឱ្យធ្វើ សកម្មភាព។
- ការជម្រះក្តីត្រូវធានាឱ្យបានថា ត្រូវធ្វើឡើងដោយគោរពតាម គោលការណ៍ចំពោះមុខ ដើម្បីធានាឱ្យបាន នូវ តម្លាភាព ក៏ដូចជាទំនុកចិត្តជាសាធារណៈ។
- សាលក្រមចុងក្រោយ ដែលធ្វើការសម្រេចសេចក្តីអំពីវិវាទរបស់ភាគីនោះ ត្រូវធានាឱ្យថាបានធ្វើតាម ដំណើរការនៃនីតិវិធីទៅតាមលំដាប់លំដោយតាមបទបញ្ញត្តិច្បាប់ដែលមានចែងជាធរមាន។

# ឯកសារយោង

- **ច្បាប់ និង បទបញ្ញត្តិផ្សេងៗ**


១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ។

២. ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០០៦ ។

៣. ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ ។

៤. អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ឆ្នាំ ២០១៦


- **សៀវភៅ និង ឯកសារផ្សេងៗ**


៥. ជំនាញការជប៉ុន, ២០០៥ *សេចក្តីពន្យល់ អំពីចំណុចសំខាន់ៗនៃក្រមនីតិរដ្ឋប្បវេណីកម្ពុជា*, ភ្នំពេញ។

៦. ក្រសួងយុត្តិធម៌, ២០០៧ *សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋវេណី*, ភ្នំពេញ។

៧. ក្រុមការងារជប៉ុន, ២០០៨ *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ ស្តីពីនីតិវិធីបណ្តឹង*, ភ្នំពេញ។

៨. លោកមេធាវី អ៊ីវ ប៉ូលី, ២០១០ *នីតិវិធីរដ្ឋប្បវេណី (មេរៀនសង្ខេប)* ភ្នំពេញ ។

៩. លោកមេធាវី ប៉ោ ហ៊ុយ, *នីតិវិធីជំនុំជម្រះលើកទី១ (មេរៀនសង្ខេប)* ភ្នំពេញ ។

១០. លោក ហេង សុខណា(ចៅក្រមសាលាឧទ្ធរណ៍បាត់ដំបង), *នីតិវិធីរដ្ឋប្បវេណី (បទបង្ហាញ ស្តីពីអំពីលំហូរនីតិវិធីរដ្ឋប្បវេណី)* ។

១១. ប្រសាសន៍របស់ឯកឧត្តម ហ៊ី សោភា នាពេលបង្រៀននីតិវិធីរដ្ឋប្បវេណី នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

១២. គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ២០១៥, *មេរៀនក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១*, ភ្នំពេញ ។

១៣. គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ២០១៥, *មេរៀនក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២*, ភ្នំពេញ ។

១៤. គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ២០១៥, *មេរៀនក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ៣*, ភ្នំពេញ ។

➢ **គេហទំព័រ**

១៥. http://www.moj.gov.kh/kh/actual-civil-judgments

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

ឯកសារគំរូ លើកិច្ចសន្យាខ្ចីបរិភោគ

# ឯកសារគំរូ

# លើ

# កិច្ចសន្យាខ្ចីបរិភោគ

Mock Record on Contract of Loan for Consumption

ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៧
December 7, 2007

រៀបចំដោយៈ ក្រុមការងារបង្កើតឯកសារគំរូ
Prepared by Mock Record Development Working Group

| បញ្ជីសារពើភ័ណ្ឌ | | |
|---|---|---|
| ឈ្មោះឯកសារ | ទំព័រ | កំណត់ |
| កំណត់ហេតុនៃនីតិវិធីត្រៀមសំរាប់ការទាញហេតុផលលើកទី១ | ១ | |
| កំណត់ហេតុនៃនីតិវិធីត្រៀមសំរាប់ការទាញហេតុផលលើកទី២ | ៣ | |
| កំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់លើកទី១ | ៥ | |
| កំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់លើកទី២ | ៦ | |
| កំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់លើកទី៣ | ៧ | ប្រកាសសាលក្រម |
| លិខិតសាលក្រម | ៨ | រំលងចោល |
| ពាក្យបណ្ដឹង | ៩ | |
| ឯកសារចម្លើយ | ១២ | |
| ឯកសារត្រៀមលើកទី១ របស់ដើមចោទ | ១៤ | |
| ឯកសារត្រៀមចុងក្រោយរបស់ដើមចោទ | ១៦ | |
| ឯកសារត្រៀមចុងក្រោយរបស់ចុងចម្លើយ | ១៧ | |
| បញ្ជីភស្តុតាង | ១៨ | ខាងភាគីដើមចោទ |
| បញ្ជីភស្តុតាង | ១៩ | ខាងភាគីចុងចម្លើយ |
| បញ្ជីសាក្សី ជាអាទិ៍ | ២០ | ខាងភាគីដើមចោទ |
| បញ្ជីសាក្សី ជាអាទិ៍ | ២១ | ខាងភាគីចុងចម្លើយ |
| ការពន្យល់អំពីភស្តុតាង | ២២ | ដើមចោទ |
| ការពន្យល់អំពីភស្តុតាង | ២៣ | ចុងចម្លើយ |
| ភស្តុតាងជាឯកសារ X 1 | ២៤ | លិខិតកិច្ចសន្យាខ្ចីបរិភោគរវាងដើមចោទនិងចុងចម្លើយ |
| ភស្តុតាងជាឯកសារ X 2 | ២៥ | របាយការណ៍ធនាគារ |
| ភស្តុតាងជាឯកសារ X 3 | ២៦ | លិខិតកិច្ចសន្យាលក់ទិញរថយន្ត |
| ភស្តុតាងជាឯកសារ Y1 | ២៧ | របាយការណ៍ធនាគារ |
| ភស្តុតាងជាឯកសារ Y2 | ២៨ | លិខិតកិច្ចសន្យាខ្ចីបរិភោគរវាងចុងចម្លើយនិងសៅតារា |
| កំណត់ហេតុនៃការសាកសួរសាក្សី | ២៩ | គ្រឿង បុប្ផា |
| កំណត់ហេតុនៃការសាកសួរដើមចោទ | ៣៨ | សុខ បូរា ( ចុងចម្លើយ) |
| កំណត់ហេតុនៃការសាកសួរសាមីភាគី | ៥០ | ខៀវអាត ( ដើមចោទ) |
| ពាក្យស្នើសុំដាក់ភស្តុតាង | ៦០ | ដើមចោទ ( សាកសួរសាក្សី) |
| ពាក្យស្នើសុំដាក់ភស្តុតាង | ៦១ | ចុងចម្លើយ ( សាកសួរសាក្សី) |
| លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ | ៦៣ | ដើមចោទ |
| លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ | ៦៤ | ចុងចម្លើយ |
| របាយការណ៍នៃការបញ្ជូន | ៦៥ | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| សន្ទានការី | ចៅក្រម | កាលបរិច្ឆេទ | 9/2 10:00 | ត្រៀមទាញហេតុផល | | | | |
| | ប៉ែនបូរាវី | | 23/2 10:00 | ត្រៀមទាញហេតុផល | | | | |
| | | | 23/3 10:00 | សាកសួរសាក្សី | | | | |
| | ក្រឡា បញ្ជី | | 30/3 10:00 | បញ្ចប់ទាញហេតុផល | | | | |
| | | | 4/4 10:00 | ប្រកាសសាលក្រម | | | | |
| | ស៊ុនសេយ៉ុង | | | | | | | |
| | | | | | | | | |

**កំណត់ហេតុនៃការជំនុំជម្រះលើកទីមួយ នៅក្នុងរឿងក្ដីរដ្ឋប្បវេណី**

តុលាការក្រុងភ្នំពេញ ផ្នែករដ្ឋប្បវេណី ទី២

| | | | | |
|---|---|---|---|---|
| លទ្ធផល | លេខរឿងក្ដី | ១១៧ | ចំណងជើងនៃរឿងក្ដី | **កំចីជាប្រាក់** |
| កាលបរិច្ឆេទ<br>ថ្ងៃ ខែ ឆ្នាំ | | | | |

| | និមិត្តសញ្ញា | ភាគី | និមិត្តសញ្ញា | អ្នកតំណាងដោយអាណត្តិ | ទូរស័ព្ទ ទូរសារ |
|---|---|---|---|---|---|
| ☐ ទទួលស្គាល់<br>☐ ទទួលស្គាល់មួយផ្នែក<br>☐ ច្រានចោល<br>☐ សះជា<br>☐ ទទួលស្គាល់<br>☐ ដកពាក្យបណ្ដឹង<br>☐ | X | ខៀវ អាត | | មាស ពេជ្រ | |
| | | | | | |
| | | | | | |
| | | | | | |
| *រក្សាទុក :*<br>ពីថ្ងៃ ខែ ឆ្នាំ<br>ដល់ថ្ងៃ ខែ ឆ្នាំ | | | | | |
| | | | | | |
| *របាយការណ៍*<br>☐ ទទួល<br>☐ បញ្ចប់រឿងក្ដី<br>*វត្ថុរក្សាទុក*<br>☐ ទទួល<br>☐ បញ្ជូនត្រឡប់វិញ<br>*ការចុះបញ្ជីដែលត្រូវបានជូនដំណឹងជាមុន*<br>☐ អាណត្តិ<br>☐ លប់ចោល<br>☐ បណ្ដឹងរឿងក្ដី<br>☐ បញ្ជីរឿងក្ដី | Y | សុក បូរា | | វីរៈ បុត្រ | |
| | | | | | |
| | | | | | |
| | | | | | |

និមិត្តសញ្ញាសម្រាប់ភាគី : X ដើមបណ្ដឹង Y ចុងចម្លើយ P អ្នកចូលរួម Q អ្នកទទួលបញ្ជីទី R អ្នកចូលរួមជួយអន្តរាគមន៍ក្នុងចំណោមបញ្ជី ក្បាល

ធ្វើការកំណត់ថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ ២០០៧ វេលាម៉ោង ១០ព្រឹក ជាកាលបរិច្ឆេទត្រៀមសំរាប់ការទាញហេតុផល នៃរឿងក្តីនេះ។

ថ្ងៃទី ១៣  ខែ មករា ឆ្នាំ ២០០៧

ចៅក្រម

ប៉ែន បូភាវី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល លើកទី១

សញ្ញាណនៃរឿងក្ដី លេខ ១១៧ ចុះថ្ងៃទី១២ មករា ២០០៧

រឿងក្ដីទាមទារប្រាក់កំចី

កាលបរិច្ឆេទ ថ្ងៃទី៩ កុម្ភៈ ២០០៧ វេលាម៉ោង ១០:០០ ព្រឹក

ទីកន្លែង បន្ទប់នីតិវិធីត្រៀម នៃតុលាការក្រុងភ្នំពេញ ផ្នែករដ្ឋប្បវេណី ទី២

ចៅក្រម ប៉ែន បូរាវី

ក្រឡាបញ្ជីតុលាការ ស៊ុន សេយ៉ុង

ភាគីដែលបង្ហាញខ្លួន ជាអាទិ៍ អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ មាសពេជ្រ

អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយ វីរៈ បុត្រ

សេចក្ដីសង្ខេបអំពីសកម្មភាពដែលបានធ្វើឡើងនៅកាលបរិច្ឆេទ

ចៅក្រម

អនុសាសន៍ឱ្យសះជា

បញ្ចប់ការផ្សះផ្សា

អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ

ថ្លែងការណ៍តាមពាក្យបណ្ដឹង

អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយ

ថ្លែងការណ៍តាមឯកសារចម្លើយ

ទទួលស្គាល់ថា ពេលដែលចុងចម្លើយបានសងប្រាក់មួយភាគ គាត់មិនបានទទួលវិក័យបត្រទេ។ ចុងចម្លើយបានទាមទារវិក័យបត្រដែរ តែដើមចោទបានបដិសេធមិនចេញវិក័យបត្រ រហូតដល់ពេលបានសងរួចរាល់។

អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ

ស្ដីពីការអះអាងអំពីការសងមួយភាគ និងការលើកលែងប្រាក់ដែលនៅសល់ ដោយចុងចម្លើយនេះ គាត់នឹង ធ្វើការទទួលស្គាល់ ឬមិនទទួលស្គាល់ ព្រមទាំងឆ្លើយតបវិញឱ្យបានមុនកាលបរិច្ឆេទបន្ទាប់។

ស្ដីពីការអះអាងអំពីការទិញរថយន្តនៅខ្ទង់ខែមិថុនាឆ្នាំ ២០០៦នោះ គាត់នឹងធ្វើការទទួលស្គាល់ ឬមិនទទួលស្គាល់ ព្រមទាំងឆ្លើយតបវិញឱ្យបានមុនកាលបរិច្ឆេទបន្ទាប់។

ភាគីទាំងសងខាង

ពិចារណាអំពីការស្នើសុំឱ្យសាកសួរសាក្សី និងការស្នើសុំដាក់ភស្តុតាងជាឯកសារឱ្យបានមុនកាលបរិច្ឆេទក្រោយ។

ចៅក្រម

សូមឱ្យដើមចោទធ្វើការទទួលស្គាល់ ឬមិនទទួលស្គាល់ ព្រមទាំងឆ្លើយតបដោយឯកសារត្រៀម។ សូមដាក់ឯកសារត្រៀមត្រឹមថ្ងៃទី ១៦ កុម្ភៈ ២០០៧។

សូមភាគីទាំងសងខាងគិតពិចារណាអំពីការស្នើសុំឱ្យសាកសួរសាក្សី និងបញ្ជាក់ភស្តុតាងជាឯកសារត្រឹមកាលបរិច្ឆេទបន្ទាប់ ។

ទំនាក់ទំនងភស្តុតាង ដូចដែលបានចុះក្នុងបញ្ជីភស្តុតាងជាឯកសារ

កាលបរិច្ឆេទបន្ទាប់ ថ្ងៃទី២៣ កុម្ភៈ ២០០៧ វេលាម៉ោង ១០:០០ព្រឹក

កាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផល

ចប់

| | |
|---|---|
| ក្រឡាបញ្ជីតុលាការ | ចៅក្រម |
|  |  |
| ស៊ុន សេយ៉ុង | ប៉ែន បូរាវី |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល លើកទី២

សញ្ញាណនៃរឿងក្តី លេខ ១១៧ ចុះថ្ងៃទី១២ មករា ២០០៧

រឿងក្តីទាមទារប្រាក់កំចី

កាលបរិច្ឆេទ ថ្ងៃទី២៣ កុម្ភៈ ២០០៧ វេលាម៉ោង ១០:០០ ព្រឹក

ទីកន្លែង បន្ទប់នីតិវិធីត្រៀម នៃតុលាការក្រុងភ្នំពេញ ផ្នែករដ្ឋប្បវេណី ទី 2

ចៅក្រម ប៉ែន បូរាវី

ក្រឡាបញ្ជីតុលាការ ស៊ុន សេយ៉ុង

ភាគីដែលបង្ហាញខ្លួន ជាអាទិ៍ អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ មាសពេជ្រ

អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយ វីរៈ បុត្រ

សេចក្តីសង្ខេបអំពីសកម្មភាពដែលបានធ្វើឡើងនៅកាលបរិច្ឆេទ

អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ

ថ្លែងការណ៍តាមឯកសារត្រៀម ទី១

អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយ

ទទួលស្គាល់ថា ពីខែកក្កដា ឆ្នាំ ២០០៦ មក ដើមចោទបានដាស់តឿនឱ្យសងមែន។ ដើមចោទបានបង្ហាញឆន្ទៈលើកលែងចំពោះប្រាក់ដែលនៅសល់ តែជាងមួយខែក្រោយមក ស្រាប់តែដាស់តឿនទាមទារឱ្យសងទៅវិញ។

ចៅក្រម និងភាគីទាំងសងខាង

បានបញ្ជាក់អំពីចំណុចវិវាទ និងអំពីអង្គហេតុដែលត្រូវបញ្ជាក់ដោយភស្តុតាងដូចតទៅ :

1 ចំណុចវិវាទគឺ អត្ថិភាព ឬនត្ថិភាពនៃអង្គហេតុនីមួយៗ ដែលកើតមានឡើងនៅថ្ងៃទី១ មិថុនា ២០០៦ ពេលដែលចុងចម្លើយបានទៅផ្ទះដើមចោទ។

① ការសងមួយភាគ គឺ ៦០០០ដុល្លារ ដោយចុងចម្លើយ

② ការបង្ហាកឆន្ទៈលើកលែងចំពោះប្រាក់ដែលនៅសល់ ដោយដើមចោទ

2 ស្តីពីស្ថានភាពពាក់ព័ន្ធនឹងអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុទី ① និងទី ② បានរៀបចំដូចតទៅ :

(1) ស្ថានភាពវិជ្ជមានចំពោះអង្គហេតុទី ① ដែលចុងចម្លើយបានអះអាងមានដូចតទៅ :

・នៅថ្ងៃទី១ មិថុនា ២០០៦ ចុងចោទបានរកប្រាក់ ៦០០០ដុល្លារ ហើយនៅថ្ងៃដដែលនោះ គាត់បានទៅផ្ទះដើមចោទ

・នៅខ្ទង់ខែមិថុនា ឆ្នាំ ២០០៦នោះ ដើមចោទបានទិញរថយន្តមួយគ្រឿងក្នុងតម្លៃ ៥០០០ដុល្លារ

(2) ស្ថានភាពដែលអាចបដិសេធនូវអង្គហេតុទី ① ដែលដើមចោទបានអះអាងមានដូចតទៅ :

・អត់មានវិក័យបត្រ

(3) ស្ថានភាពដែលអាចបដិសេធនូវអង្គហេតុទី ② ដែលដើមចោទបានអះអាងមានដូចតទៅ :

・ពីខែកក្កដា ឆ្នាំ ២០០៦ មក ដើមចោទបានតឿនជាញយៗឱ្យចុងចម្លើយសង

3 អង្គហេតុដែលត្រូវបញ្ជាក់ដោយសាក្សីមានដូចតទៅ :

(1) ចុងចម្លើយនឹងធ្វើការបញ្ជាក់ភស្តុតាងអំពីការឆ្លើយឆ្លងគ្នារវាងដើមចោទ និងចុងចម្លើយនៅថ្ងៃទី១ មិថុនា ២០០៦ នោះ ព្រមទាំងបញ្ជាក់នូវស្ថានភាពនានាខាងលើនេះ តាមរយៈការសាកសួរសាក្សី គ្រឿងបុប្ផា និងការសាកសួរសាមីភាគីចុងចម្លើយ ។

(2) ដើមចោទនិងធ្វើការបញ្ជាក់ភស្តុតាងអំពីអង្គហេតុ និងស្ថានភាពខាងលើនេះដូចគ្នាដែរ តាមរយៈការសាកសួរសាមីភាគីដើមចោទ ។

ចៅក្រម

បញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ទំនាក់ទំនងភស្តុតាង ដូចដែលបានចុះក្នុងបញ្ជីសាក្សី និងបញ្ជីភស្តុតាងជាឯកសារ

កាលបរិច្ឆេទបន្ទាប់ ថ្ងៃទី២៣ មិនា ២០០៧ វេលាម៉ោង ១០:០០ព្រឹក

កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់

ចប់

ក្រឡាបញ្ជីតុលាការ



ស៊ុន សេយ៉ុង

ចៅក្រម



ប៉ែន បូរាវី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ លើកទី១

សញ្ញាណរឿងក្តី លេខ ១១៧ ចុះថ្ងៃទី១២ មករា ២០០៧

រឿងក្តីទាមទារប្រាក់កំចី

កាលបរិច្ឆេទ ថ្ងៃទី២៣ មីនា ២០០៧ វេលាម៉ោង ១០:០០ ព្រឹក

ទីកន្លែង ធ្វើជាសាធារណៈនៅបន្ទប់ជំនុំជំរះនៃតុលាការក្រុងភ្នំពេញ

ចៅក្រម ប៉ែន បូរាវី

ក្រឡាបញ្ជីតុលាការ ស៊ុន សេយ៉ុង

ភាគីដែលបង្ហាញខ្លួន ជាអាទិ៍ ដើមចោទ ខៀវ អាត

អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ មាសពេជ្រ

ចុងចម្លើយ សុក បូរា

អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយ វីរៈ បុត្រ

សេចក្តីសង្ខេបនៃការទាញហេតុផល

ចៅក្រមនិងភាគីទាំងសងខាង

បានធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការត្រៀមសំរាប់ការទាញហេតុផលដូចតទៅ :

១. ស្តីពីចំណុចវិវាទ និងអង្គហេតុដែលត្រូវបញ្ជាក់ដោយការបញ្ជាក់ភស្តុតាង មានដូចដែលបានសរសេរក្នុងកំណត់ហេតុនៃនីតិវិធីត្រៀមសំរាប់ការទាញហេតុផលលើកទី២ ។

២. ស្តីពីទំនាក់ទំនងភស្តុតាង មានដូចដែលបានសរសេរក្នុងបញ្ជីភស្តុតាងជាឯកសារ និងបញ្ជីសាក្សី ជាអាទិ៍ ។

ទំនាក់ទំនងភស្តុតាង ដូចដែលមាននៅក្នុងឯកសារឧបសម្ព័ន្ធ

ចៅក្រម

ផ្តល់អនុសាសន៍ឱ្យសះជា

បញ្ចប់ការផ្សះផ្សា

កាលបរិច្ឆេទបន្ទាប់ ថ្ងៃទី៣០ មីនា ២០០៧ វេលាម៉ោង ១០:០០ព្រឹក

កាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់

(នឹងបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់)

ចប់

ក្រឡាបញ្ជីតុលាការ ចៅក្រម

ស៊ុន សេយ៉ុង ប៉ែន បូរាវី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់ លើកទី២

សញ្ញាណរឿងក្ដី លេខ ១១៧ ចុះថ្ងៃទី១២ មករា ២០០៧

រឿងក្ដីទាមទារប្រាក់កំចី

កាលបរិច្ឆេទ ថ្ងៃទី៣០ មីនា ២០០៧ វេលាម៉ោង ១០:០០ ព្រឹក

ទីកន្លែង ធ្វើជាសាធារណៈនៅបន្ទប់ជំនុំជំរះនៃតុលាការក្រុងភ្នំពេញ

ចៅក្រម ប៉ែន បូរាវី

ក្រឡាបញ្ជីតុលាការ ស៊ុន សេយ៉ុង

ភាគីដែលបង្ហាញខ្លួន ជាអាទិ៍ អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ មាសពេជ្រ

អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយ វីរៈ បុត្រ

សេចក្ដីសង្ខេបនៃការទាញហេតុផល

អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ

សេចក្ដីថ្លែងការណ៍មានដូចក្នុងឯកសារត្រៀមចុងក្រោយរបស់ដើមចោទ

អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយ

សេចក្ដីថ្លែងការណ៍មានដូចក្នុងឯកសារត្រៀមចុងក្រោយរបស់ចុងចម្លើយ

ចៅក្រម

បញ្ចប់ការទាញហេតុផល

កាលបរិច្ឆេទបន្ទាប់ ថ្ងៃទី៤ មេសា ២០០៧ វេលាម៉ោង ១០:០០ព្រឹក ការប្រកាសាលក្រម

ចប់

ក្រឡាបញ្ជីតុលាការ ចៅក្រម





ស៊ុន សេយ៉ុង ប៉ែន បូរាវី

# កំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់  លើកទី៣

សញ្ញាណរឿងក្តី	លេខ ១១៧  ចុះថ្ងៃទី១២ មករា ២០០៧
រឿងក្តីទាមទារប្រាក់កំចី
កាលបរិច្ឆេទ	ថ្ងៃទី៤ មេសា ២០០៧  វេលាម៉ោង ១០:០០ ព្រឹក
ទីកន្លែង	ធ្វើជាសាធារណៈនៅបន្ទប់ជំនុំជំរះនៃតុលាការក្រុងភ្នំពេញ
ចៅក្រម	ប៉ែន បូរាវី
ក្រឡាបញ្ជីតុលាការ	ស៊ុន សេយ៉ុង
ភាគីដែលបង្ហាញខ្លួន ជាអាទិ៍	អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ	មាសពេជ្រ
អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយ	វីរៈ បុត្រ

សេចក្តីសង្ខេបនៃការទាញហេតុផល

ចៅក្រម

បានប្រកាសសាលក្រមដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម

ចប់

ក្រឡាបញ្ជីតុលាការ



ស៊ុន សេយ៉ុង

ចៅក្រម



ប៉ែន បូរាវី

# សាលក្រម (រំលងចោល)

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្តឹង

គោរពជូនប្រធានតុលាការក្រុងភ្នំពេញ

- ដើមចោទ ខៀវ អាត (ភេទប្រុស អាយុ ៤៦ឆ្នាំ អត្តសញ្ញាណប័ណ្ណលេខ ១១១១)
  អាស័យដ្ឋានផ្ទះលេខ ១២ សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន រាជធានីភ្នំពេញ។
- អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ មាស ពេជ្រ
  អាស័យដ្ឋាន XX, ○○, ភ្នំពេញ (※អាស័យដ្ឋានរបស់អ្នកតំណាងដោយអាណត្តិដើមចោទ)
  (កន្លែងដែលត្រូវធ្វើការបញ្ជូន)

- ចុងចម្លើយ សុក បូរា (ភេទប្រុស អាយុ ៤៦ឆ្នាំ, អត្តសញ្ញាណប័ណ្ណលេខ ២២២២)
  អាស័យដ្ឋានផ្ទះលេខ ៣៤ សង្កាត់ ផ្សារកណ្តាល ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ។

ទឹកប្រាក់ដែលជាកម្មវត្ថុនៃបណ្តឹង ៨.០០០ (ប្រាំបីពាន់)ដូល្លារ

ពន្ធដាក់ពាក្យបណ្តឹង ២៥៤.០០០រៀល

<u>ទី១- សាលក្រមដែលទាមទារដោយដើមចោទ</u>

ដើមចោទទាមទារឱ្យតុលាការចេញសាលក្រម និង ទាមទារនូវការប្រកាសអនុវត្តជាបណ្តោះអាសន្ន

ក. ចុងចម្លើយត្រូវបង់ទៅឱ្យដើមចោទនូវទឹកប្រាក់ចំនួន៩.៦០០ដូល្លារ ព្រមទាំងទឹកប្រាក់ចំនួន ២០%ក្នុងមួយឆ្នាំ នៃប្រាក់ ៨,០០០ដូល្លារក្នុងទឹកប្រាក់៩,៦០០ដូល្លារនេះដែរ ដោយគិតពីថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០៦ រហូតដល់ថ្ងៃដែលបានបង់ចប់សព្វគ្រប់។

ខ. ចុងចម្លើយត្រូវទទួលរ៉ាប់រងនូវប្រាក់ប្រដាប់ក្តី។

<u>ទី២- អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ</u>

ក. ការទាមទារឱ្យសងប្រាក់កំចីចំនួន ៨.០០០ដូល្លារ ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគដែលបានបង្កើតឡើងរវាងដើមចោទ និង ចុងចម្លើយនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៤។

ខ. ការទាមទារការប្រាក់ចំនួន២ឆ្នាំ គឺ១៦០០ដូល្លារ ដែលជាការគណនាតាមអត្រាការប្រាក់ ១០ % ក្នុងមួយឆ្នាំដែលបានសន្យាពេលបង្កើតកិច្ចសន្យា ក. ខាងលើនេះ។

គ. ការទាមទារការប្រាក់នៃការយឺតយ៉ាវ ២០%ក្នុងមួយឆ្នាំ ដោយគណនាពីថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០៦ ដែលជាថ្ងៃបន្ទាប់នៃកាលកំណត់សង ដែលបានសន្យាពេលបង្កើតកិច្ចសន្យា ក. ខាងលើនេះ រហូតដល់ថ្ងៃដែលបានសងចប់សព្វគ្រប់។

ទី៣: អង្គហេតុចំបាច់ដែលជាមូលហេតុនៃការទាមទារ និង អង្គហេតុពាក់ព័ន្ធនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ

ប្រហែលជាខ្ទង់ខែ មេសា ឆ្នាំ ២០០៤ ចុងចម្លើយបានសុំខ្ចីប្រាក់ ៨.០០០ដូល្លារ ពីដើមចោទ ដើម្បីជួសជុលផ្ទះរបស់ខ្លួន។

ដោយសារតែជាមិត្តតាំងពីយូរណាស់មកហើយ ដើមចោទក៏បានយល់ព្រមឱ្យចុងចម្លើយខ្ចី ហើយនៅ ថ្ងៃទី១ ខែមិថុនា ឆ្នាំដដែលនោះ ក៏បានបង្កើតកិច្ចសន្យាឱ្យចុងចម្លើយខ្ចីប្រាក់ ៨.០០០ ដូល្លារ ដោយកំណត់ឱ្យសងនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៦ ហើយនៅថ្ងៃធ្វើកិច្ចសន្យានោះ ដើមចោទបានប្រគល់ប្រាក់ ៨.០០០ដូល្លារ នោះទៅឱ្យចុងចម្លើយ ដោយផ្អែកលើកិច្ចសន្យានោះ។ ចុងចម្លើយបានព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដោយមានចុះហត្ថលេខា អំពីការបង់ការប្រាក់ ១០% ក្នុងមួយឆ្នាំ ចំនួន២ឆ្នាំ ដោយគិតរហូតដល់កាលកំណត់សង។ម្យ៉ាងវិញទៀត ចុងចម្លើយបាន ព្រមព្រៀងអំពីការបង់ការប្រាក់នៃការយឺតយ៉ាវ ២០% ក្នុងមួយឆ្នាំ ក្នុងករណីដែលចុងចម្លើយ មិនបានសងតាមកាលកំណត់នេះ។ ( ភស្តុតាង X1 ) ។

លុះដល់ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៦ ដែលជាកាលកំណត់សងនោះ ចុងចម្លើយបានមកផ្ទះ ដើមចោទ តែគាត់បាននិយាយថា គាត់ត្រូវការប្រាក់ដើម្បីព្យាបាលជម្ងឺឪពុករបស់គាត់ ហើយមិនបាន សងទាំងប្រាក់កំចី ទាំងការប្រាក់។ រហូតដល់សព្វថ្ងៃនេះ ចុងចម្លើយនៅមិនទាន់បានសងនៅឡើយ ទេ។

ភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៧

អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ

មាស ពេជ្រ

ភ្ជាប់មកជាមួយនូវ ៖

១- ភស្តុតាង X1

លិខិតនៃកិច្ចសន្យាខ្ចីបរិភោគ

២- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ  សាសនា  ព្រះមហាក្សត្រ

# ឯកសារចម្លើយ

តុលាការក្រុងភ្នំពេញ
រឿងក្តីលេខ ១១៧ ចុះថ្ងៃទី១២ មករា ២០០៧
រឿងក្តីទាមទារប្រាក់កំចី
ដើមចោទ  ខៀវ អាត
ចុងចម្លើយ  សុក បូរា

ជូនចំពោះលោកប្រធានតុលាការក្រុងភ្នំពេញ
ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ ២០០៧

អាស័យដ្ឋាន : △△,○○, ភ្នំពេញ (※អាស័យដ្ឋានរបស់មេធាវីតំណាងឱ្យចុងចម្លើយ)
(កន្លែងដែលត្រូវធ្វើការបញ្ជូន)
មេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយ

វីរៈ បុត្រ

## ទី១  ចម្លើយចំពោះសាលក្រមដែលទាមទារដោយដើមចោទ

ទាមទារឱ្យចេញសាលក្រមដូចតទៅ :

1  ច្រានចោលនូវការទាមទារទាំងអស់របស់ដើមចោទ
2  ដើមចោទត្រូវទទួលរ៉ាប់រងនូវប្រាក់ប្រដាប់ក្តី

## ទី២  ការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុដែលអះអាងដោយដើមចោទ

1  ទទួលស្គាល់នូវអង្គហេតុខាងក្រោមនេះ។

(1) ដើមចោទនិងចុងចម្លើយបានបង្កើតកិច្ចសន្យាខ្ចីបរិភោគដែលមានចំនួនទឹកប្រាក់៨០០០ដូល្លារ ដោយកំណត់សងនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ ២០០៦

(2) ចុងចម្លើយបានទទួលប្រាក់ ៨០០០ដូល្លារ ដោយផ្អែកលើកិច្ចសន្យានេះ

(3) ដើមចោទនិងចុងចម្លើយបានព្រមព្រៀងជាលាយលក្ខណ៍អក្សរ អំពីការបង់ការប្រាក់ ១០%ក្នុងមួយឆ្នាំ គិតរហូតដល់ពេលកំណត់សង ដោយមានហត្ថលេខារបស់ចុងចម្លើយ

(4) ដើមចោទនិងចុងចម្លើយបានព្រមព្រៀងអំពីអត្រាការប្រាក់នៃការយឺតយ៉ាវ ២០%ក្នុងមួយឆ្នាំ ក្នុងករណីដែលចុងចម្លើយមិនបានសងតាមកាលកំណត់

2 មានវិវាទចំពោះការអះអាងនូវកាតព្វកិច្ចបង់ប្រាក់កំចី ការប្រាក់ និងការប្រាក់នៃការយឺតយ៉ាវរបស់ចុងចម្លើយ ។

## ទី៣ ការអះអាងរបស់ចុងចម្លើយ

1 នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ ២០០៦ ចុងចម្លើយបានដកប្រាក់ចំនួន ៥០០០ដុល្លារពីធនាគារ ហើយថែមទាំងបានខ្ចីប្រាក់ចំនួន ១០០០ដុល្លារពីសៅដារា ដែលត្រូវជាពូរបស់ប្រពន្ធខ្លួន បូកសរុបទៅ មាន ៦០០០ ដុល្លារ ។ បន្ទាប់មក នាពេលល្ងាចនៃថ្ងៃដដែលនោះ ចុងចម្លើយបានទៅផ្ទះដើមចោទ ជាមួយប្រពន្ធខ្លួន ហើយបានសងប្រាក់មួយភាគនៃប្រាក់កំចី ចំនួន ៦០០០ដុល្លារដែលមានខាងលើនេះ ហើយពេលនោះ ដើមចោទក៏បានទទួលជាសំណងនៃប្រាក់កំចីទៅ ។

ម្យ៉ាងទៀត ប្រហែលជាខ្ទង់ខែមិថុនា ឆ្នាំ ២០០៦ កូនប្រុសរបស់ដើមចោទបានជិះរថយន្តម៉ាកការីចាស់មួយដែលមានតម្លៃប្រហែលជាបួនប្រាំពាន់ដុល្លារ ដូច្នេះហើយ តាមការសន្និដ្ឋាន ប្រហែលជាដើមចោទបានយកប្រាក់ដែលចុងចម្លើយបានសងមួយភាគនោះ ទៅទិញរថយន្តនោះហើយ ។

2 ម្យ៉ាងទៀត នៅពេលនោះ ឪពុករបស់ចុងចម្លើយមានជម្ងឺ ហើយត្រូវទៅគេងពេទ្យនៅបរទេសផង ដូច្នេះ ចុងចម្លើយមានការខ្វះប្រាក់ ។ ចុងចម្លើយបានពន្យល់អំពីស្ថានភាពនេះ ចំពោះដើមចោទ នាពេលនោះ ហើយដើមចោទក៏មានចិត្តអាណិតអាសូរដល់ចុងចម្លើយ ហើយក៏បានបង្ហាញឆន្ទៈលើកលែងចោលនូវបំណុលដែលនៅសល់នោះ ។

3 ហេតុនេះហើយ ចុងចម្លើយអស់មានកាតព្វកិច្ចសងទៀតទេ ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឯកសារត្រៀមទី១របស់ដើមចោទ

តុលាការក្រុងភ្នំពេញ
រឿងក្តីលេខ ១១៧ ចុះថ្ងៃទី១២ មករា ២០០៧
រឿងក្តីទាមទារប្រាក់កំចី
ដើមចោទ ខៀវ អាត
ចុងចម្លើយ សុក បូរា

ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០០៧
ជូនចំពោះលោកប្រធានតុលាការក្រុងភ្នំពេញ

មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទ

មាស ពេជ្រ

សុំធ្វើការទទួលស្គាល់ ឬមិនទទួលស្គាល់ ព្រមទាំងឆ្លើយតបចំពោះការអះអាងក្នុងឯកសារចម្លើយរបស់ចុងចម្លើយ ដូចតទៅ។

1 មិនដឹងអំពីការដកប្រាក់ ៥០០០ដុល្លារ ពីធនាគារ និងការខ្ចីប្រាក់ ១០០០ដុល្លារពីសាច់ញាតិ ដោយចុងចម្លើយទេ។

សុំបដិសេធនូវការសងប្រាក់ ៦០០០ដុល្លារ ចំពោះដើមចោទ នៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០០៦ ដោយចុងចម្លើយ។ ការដែលចុងចម្លើយបានមកផ្ទះដើមចោទ ជាមួយនឹងប្រពន្ធខ្លួននៅថ្ងៃនោះ គឺចុងចម្លើយបានសុំខ្ចី ៤០០០ដុល្លារថែមទៀតពីដើមចោទផង ដោយសារតែឪពុកខ្លួនមានជម្ងឺ ដូច្នេះម្តេចសង៦០០០ដុល្លារកើត។ បើសិនជាដើមចោទបានទទួលនូវសំណងនោះ គេនឹងចេញវិក័យបត្រឱ្យហើយ ដូច្នេះបើអត់វិក័យបត្រ មានន័យថា អត់មានការសងមួយភាគនោះទេ។

ម្យ៉ាងទៀត ដើមចោទទទួលស្គាល់ថា ខ្លួនបានទិញរថយន្តម៉ាកកាំរីដែលមានតម្លៃ ៥០០០ដុល្លារនៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៦ ពិតមែន តែខ្លួនបានដកប្រាក់ពីធនាគារខ្លួនទិញទេ។ នៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០៦ ដើមចោទបានដកប្រាក់ ១ម៉ឺនដុល្លារពីគណនីធនាគារខ្លួន ហើយបានយក ៥០០០ដុល្លារពីនោះទៅទិញរថយន្តកាំរីនោះទៅ។ ម្យ៉ាងទៀត ពីថ្ងៃទី១ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៦ នោះ អត់មានការបញ្ចូលប្រាក់ទៅក្នុងគណនីធនាគារនេះទេ។

2 សុំបដិសេធនូវការបង្ហាញឆន្ទៈលើកលែងចោលនូវបំណុលដែលសល់ ដោយដើមចោទ។

ដើមចោទមិនបានលើកលែងចោលនូវបំណុល ជាដើម ចំពោះចុងចម្លើយទេ។ ផ្ទុយទៅវិញ ពីខែកក្កដា ឆ្នាំ ២០០៦ មក ដើមចោទបានដាស់តឿនឱ្យចុងចម្លើយសងប្រាក់កំចីនោះប៉ុន្មានដងដែរ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ  សាសនា  ព្រះមហាក្សត្រ**

# ឯកសារត្រៀមចុងក្រោយរបស់ដើមចោទ

តុលាការក្រុងភ្នំពេញ
រឿងក្តីលេខ ១១៧  ចុះថ្ងៃទី១២ មករា ២០០៧
រឿងក្តីទាមទារប្រាក់កំចី
ដើមចោទ  ខៀវ អាត
ចុងចម្លើយ  សុក បូរា

ថ្ងៃទី២៥ ខែមីនា ឆ្នាំ ២០០៧
ជូនចំពោះលោកប្រធានតុលាការក្រុងភ្នំពេញ

មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទ

មាស ពេជ្រ

**រំលងចោល**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ  សាសនា  ព្រះមហាក្សត្រ

# ឯកសារត្រៀមចុងក្រោយរបស់ចុងចម្លើយ

តុលាការក្រុងភ្នំពេញ
រឿងក្តីលេខ ១១៧   ចុះថ្ងៃទី១២ មករា ២០០៧
រឿងក្តីទាមទារប្រាក់កំចី
ដើមចោទ        ខៀវ អាត
ចុងចម្លើយ       សុក បូរា

ថ្ងៃទី២៥ ខែមីនា ឆ្នាំ ២០០៧
ជូនចំពោះលោកប្រធានតុលាការក្រុងភ្នំពេញ

មេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយ

វីរៈ បុត្រ

**រំលងចោល**

( X ) **បញ្ជីភស្តុតាងជាឯកសារ** ( ដាក់ដោយ ដើមចោទ )

( បញ្ជីនេះគឺជាផ្នែកមួយនៃកំណត់ហេតុដែលត្រូវបានធ្វើឡើងនៅក្នុងកាលបរិច្ឆេទនិមួយៗ )

| លេខ | ការដាក់ភស្តុតាង | | ការវិនិច្ឆ័យទទួលយក ឬមិនទទួលយក | | សេចក្តីថ្លែងការណ៍ | | | កំណត់ |
|---|---|---|---|---|---|---|---|---|
| | កាលបរិច្ឆេទ | ឈ្មោះឯកសារជាអាទិ៍ | កាលបរិច្ឆេទ | ទទួលយក ឬមិនទទួល | កាលបរិច្ឆេទ | មានវិវាទ ឬទេ | ការអះអាងអំពីចំណុចវិវាទ | |
| ១ | ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី ១ | លិខិតនៃកិច្ចសន្យាខ្ចីបរិភោគធ្វើដោយដើមចោទ និង ចុង ចម្លើយ | ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី ១ | (ទទួល)<br>មិនទទួល | ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី ១ | ទទួលស្គាល់ | | |
| ២ | ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី ២ | របាយការណ៍គណនីធនាគារ គណនីធនាគាររបស់ដើមចោទដែលធ្វើដោយធនាគារកម្ពុជា សាខាភ្នំពេញ | ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី ២ | (ទទួល)<br>មិនទទួល | ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី ២ | | | |
| ៣ | ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី ២ | វិក័យបត្រ ធ្វើឡើងរវាងស្រីស្រស់ និង ដើមចោទ | ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី ២ | (ទទួល)<br>មិនទទួល | ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី ១ | | | |
| | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី | | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី | ទទួល<br>មិនទទួល | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី | | | |
| | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី | | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី | ទទួល<br>មិនទទួល | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី | | | |

កំណត់ : សូមគូសសញ្ញា ✓ ក្នុងប្រអប់ ☐ ដែលសមស្រប ។

សញ្ញាណនៃរឿងក្តី: លេខ ១១៧ ចុះថ្ងៃទី១២ មករា ២០០៧

រឿងក្តីទាមទារប្រាក់កំចី

( Y ) **បញ្ជីភស្តុតាងជាឯកសារ** (ដាក់ដោយ ចុងចម្លើយ)

(បញ្ជីនេះគឺជាផ្នែកមួយនៃកំណត់ហេតុដែលត្រូវបានធ្វើឡើងនៅក្នុងកាលបរិច្ឆេទនិមួយៗ)

| លេខ | ការដាក់ភស្តុតាង | | ការវិនិច្ឆ័យទទួលយក ឬមិនទទួលយក | | សេចក្តីថ្លែងការណ៍ | | | កំណត់ |
|---|---|---|---|---|---|---|---|---|
| | កាលបរិច្ឆេទ | ឈ្មោះឯកសារជាអាទិ៍ | កាលបរិច្ឆេទ | ទទួលយក ឬមិនទទួល | កាលបរិច្ឆេទ | មានវិវាទ ឬទេ | ការអះអាងអំពី ចំណុចវិវាទ | |
| ១ | ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី ២ | របាយការណ៍គណនីធនាគារ របស់ចុងចម្លើយ ដែលធ្វើដោយធនាគារកម្ពុជា សាខា ភ្នំពេញ | ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី ២ | ទទួល<br>មិនទទួល | ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី ២ | ទទួលស្គាល់ | | |
| ២ | ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី ២ | លិខិតនៃកិច្ចសន្យាខ្ចីបរិភោគ ធ្វើឡើងដោយចុងចម្លើយនិងសៅដារា | ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី ២ | ទទួល<br>មិនទទួល | ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី ២ | | | |
| | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី | | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី | ទទួល<br>មិនទទួល | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី | | | |
| | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី | | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី | ទទួល<br>មិនទទួល | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី | | | |
| | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី | | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី | ទទួល<br>មិនទទួល | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផល<br>លើកទី | | | |

កំណត់ : សូមគូសសញ្ញា ✓ ក្នុងប្រអប់ ☐ ដែលសមស្រប ។

**បញ្ជីសាក្សី ជាអាទិ៍** (ស្នើសុំដោយដើមចោទ)

( ស្តីពីចំណុចនិមួយៗដែលបានធ្វើនៅកាលបរិច្ឆេទ បញ្ជីនេះគឺជាផ្នែកមួយនៃកំណត់ហេតុដែលត្រូវបានធ្វើឡើងក្នុងកាលបរិច្ឆេទនិមួយៗ )

| ការស្នើសុំសាកសួរសាក្សី | | សេចក្តីសម្រេចចំពោះការសាកសួរសាក្សី | | ការពិនិត្យភស្តុតាង | | | ការអនុញ្ញាតឱ្យធ្វើកំណត់ហេតុ ជាអាទិ៍ | កំណត់ |
|---|---|---|---|---|---|---|---|---|
| កាលបរិច្ឆេទ ជាអាទិ៍ | ការបង្ហាញរបៀបបញ្ជាក់ភស្តុតាង ជាអាទិ៍ | កាលបរិច្ឆេទ ជាអាទិ៍ | សំរេចសាកសួរ ឬមិនសាកសួរ សាក្សី | កាលបរិច្ឆេទដែលកំណត់ | | អនុវត្ត | | |
| | | | | ថ្ងៃ ខែ ឆ្នាំ | ម៉ោង | | | |
| ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី ២ | សាមីដើមចោទ | ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី ២ | (សាកសួរ)<br>មិនសាកសួរ | ២៣ មីនា ២០០៧ មកជាមួយ | ៩ | ☑<br>☐<br>☐ | ☐មិនបាច់សរសេរកំណត់ហេតុ<br>☐ថតខ្សែអាត់ ជាអាទិ៍ ជំនួសកំណត់ហេតុ | |
| ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី | | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី | សាកសួរ<br>មិនសាកសួរ | | | ☐<br>☐<br>☐ | ☐មិនបាច់សរសេរកំណត់ហេតុ<br>☐ថតខ្សែអាត់ ជាអាទិ៍ ជំនួសកំណត់ហេតុ | |
| ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី | | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី | សាកសួរ<br>មិនសាកសួរ | | | ☐<br>☐<br>☐ | ☐មិនបាច់សរសេរកំណត់ហេតុ<br>☐ថតខ្សែអាត់ ជាអាទិ៍ ជំនួសកំណត់ហេតុ | |
| ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី | | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី | សាកសួរ<br>មិនសាកសួរ | | | ☐<br>☐<br>☐ | ☐មិនបាច់សរសេរកំណត់ហេតុ<br>☐ថតខ្សែអាត់ ជាអាទិ៍ ជំនួសកំណត់ហេតុ | |
| ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី | | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី | សាកសួរ<br>មិនសាកសួរ | | | ☐<br>☐<br>☐ | ☐ មិនបាច់សរសេរកំណត់ហេតុ<br>☐ថតខ្សែអាត់ ជាអាទិ៍ ជំនួសកំណត់ហេតុ | |

កំណត់ : សូមគូសសញ្ញា ✓ ក្នុងប្រអប់ ☐ ដែលសមស្រប ។

**បញ្ជីសាក្សី ជាអាទិ៍** (ស្នើសុំដោយចុងចម្លើយ)

( ស្តីពីចំណុចនិមួយៗដែលបានធ្វើនៅកាលបរិច្ឆេទ បញ្ជីនេះគឺជាផ្នែកមួយនៃកំណត់ហេតុដែលត្រូវបានធ្វើឡើងក្នុងកាលបរិច្ឆេទនិមួយៗ )

| ការស្នើសុំសាកសួរសាក្សី | | សេចក្តីសម្រេចចំពោះការសាកសួរសាក្សី | | ការពិនិត្យភស្តុតាង | | | ការអនុញ្ញាតឱ្យធ្វើកំណត់ហេតុជាអាទិ៍ | កំណត់ |
|---|---|---|---|---|---|---|---|---|
| កាលបរិច្ឆេទជាអាទិ៍ | ការបង្ហាញរបៀបបញ្ជាក់ភស្តុតាងជាអាទិ៍ | កាលបរិច្ឆេទជាអាទិ៍ | សំរេចសាកសួរឬមិនសាកសួរសាក្សី | កាលបរិច្ឆេទដែលកំណត់ | | អនុវត្ត | | |
| | | | | ថ្ងៃ ខែ ឆ្នាំ | ម៉ោង | | | |
| ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី ២ | សាក្សី គ្រឿងបុប្ផ | ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី ២ | សាកសួរ<br>មិនសាកសួរ | ២៣ មីនា ២០០៧ មកជាមួយ | ៩ | ☑<br>☐<br>☐ | ☐មិនបាច់សរសេរកំណត់ហេតុ<br>☐ថតខ្សែអាត់ជាអាទិ៍ ជំនួសកំណត់ហេតុ | |
| ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី ២ | សាមីចុងចម្លើយ | ☑ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី ២ | សាកសួរ<br>មិនសាកសួរ | ២៣ មីនា ២០០៧ មកជាមួយ | ៩ | ☑<br>☐<br>☐ | ☐មិនបាច់សរសេរកំណត់ហេតុ<br>☐ថតខ្សែអាត់ជាអាទិ៍ ជំនួសកំណត់ហេតុ | |
| ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី | | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី | សាកសួរ<br>មិនសាកសួរ | | | ☐<br>☐<br>☐ | ☐មិនបាច់សរសេរកំណត់ហេតុ<br>☐ថតខ្សែអាត់ជាអាទិ៍ ជំនួសកំណត់ហេតុ | |
| ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី | | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី | សាកសួរ<br>មិនសាកសួរ | | | ☐<br>☐<br>☐ | ☐មិនបាច់សរសេរកំណត់ហេតុ<br>☐ថតខ្សែអាត់ជាអាទិ៍ ជំនួសកំណត់ហេតុ | |
| ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី | | ☐ត្រៀមទាញហេតុផល<br>☐ទាញហេតុផលលើកទី | សាកសួរ<br>មិនសាកសួរ | | | ☐<br>☐<br>☐ | ☐ មិនបាច់សរសេរកំណត់ហេតុ<br>☐ថតខ្សែអាត់ជាអាទិ៍ ជំនួសកំណត់ហេតុ | |

កំណត់ : សូមគូសសញ្ញា ✓ ក្នុងប្រអប់ ☐ ដែលសមស្រប។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការក្រុងភ្នំពេញ
រឿងក្តីលេខ ១១៧ ចុះថ្ងៃទី១២ មករា ២០០៧
រឿងក្តីទាមទារប្រាក់កំចី
ដើមចោទ ខៀវ អាត
ចុងចម្លើយ សុក បូរា

ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០០៧
ជូនចំពោះលោកប្រធានតុលាការក្រុងភ្នំពេញ

មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទ

មាស ពេជ្រ

# សេចក្តីពន្យល់អំពីភស្តុតាង

X 2 របាយការណ៍គណនីធនាគារ

នេះគឺជារបាយការណ៍គណនីរបស់ដើមចោទ ដែលធ្វើដោយធនាគារកម្ពុជា សាខាភ្នំពេញ។

គោលគំនិតនៃការបញ្ជាក់ភស្តុតាង : ដើមចោទបានដកប្រាក់ ១ម៉ឺនដូល្លារ ពីគណនីធនាគាររបស់ខ្លួន នៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០៦ ហើយម្យ៉ាងទៀត នៅអំឡុងពេលពីថ្ងៃទី១ ដល់ថ្ងៃទី ៣០ ខែមិថុនាដដែលនេះ ពុំមានការបញ្ចូលប្រាក់ទេ

X 3 លិខិតទារប្រាក់ និងវិក័យបត្រទទួល

នេះគឺជាឯកសារដែលត្រូវបានធ្វើឡើងរវាងដើមចោទនិងឈ្មោះស្រីស្រស់។

គោលគំនិតនៃការបញ្ជាក់ភស្តុតាង : ដើមចោទបានទិញរថយន្តម៉ាកតូយ៉ូតា កាំរី តម្លៃ ៥០០០ដូល្លារ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០០៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការក្រុងភ្នំពេញ
រឿងក្តីលេខ ១១៧ ចុះថ្ងៃទី១២ មករា ២០០៧
រឿងក្តីទាមទារប្រាក់កំចី
ដើមចោទ ខៀវ អាត
ចុងចម្លើយ សុក បូរា

ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០០៧
ជូនចំពោះលោកប្រធានតុលាការក្រុងភ្នំពេញ

មេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយ

វីរៈ បុត្រ

# សេចក្តីពន្យល់អំពីភស្តុតាង

Y 1 របាយការណ៍គណនីធនាគារ

នេះគឺជារបាយការណ៍គណនីរបស់ចុងចម្លើយ ដែលធ្វើដោយធនាគារកម្ពុជា សាខាភ្នំពេញ។

គោលគំនិតនៃការបញ្ជាក់ភស្តុតាង : ចុងចម្លើយបានដកប្រាក់ ៥០០០ដូល្លារ ពីគណនីធនាគាររបស់ខ្លួន នៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០០៦

Y 2 លិខិតនៃកិច្ចសន្យាខ្ចីបរិភោគ

នេះគឺជាឯកសារដែលត្រូវបានធ្វើឡើងរវាងចុងចម្លើយ និងឈ្មោះសៅ ដារា។

គោលគំនិតនៃការបញ្ជាក់ភស្តុតាង : ចុងចម្លើយបានខ្ចីប្រាក់ ១០០០ដូល្លារ ពីសៅដារា នៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០០៦

# កិច្ចសន្យាខ្ចីបរិភោគ

លិខិតនៃកិច្ចសន្យាខ្ចីបរិភោគ លេខ 0A-99999A
កិច្ចសន្យាខ្ចីបរិភោគនេះត្រូវបានធ្វើឡើងរវាងម្ចាស់បំណុល និងកូនបំណុលខាងក្រោមនេះ :

ម្ចាស់បំណុល : ខៀវ អាត អត្តសញ្ញាណបណ្ណ លេខ 1 1 1 1
ទូរសព្ទលេខ : 012-999-111
អាសយដ្ឋាន : No. 12 ផ្លូវលេខ 00 សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ

កូនបំណុល : សុខ បូរា អត្តសញ្ញាណបណ្ណ លេខ 2 2 2 2
ទូរសព្ទលេខ : 012-999-222
អាសយដ្ឋាន : No. 34 ផ្លូវលេខ 00 សង្កាត់ផ្សារកណ្ដាល ខ័ណ្ឌដូនពេញ ភ្នំពេញ

ភាគីទាំងពីរខាងលើនេះ បានព្រមព្រៀងដូចតទៅ :

1. កូនបំណុលបានខ្ចីប្រាក់ចំនួន ៨០០០ដូល្លារ ពីម្ចាស់បំណុល នៅថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៤ ហើយនាថ្ងៃដដែលនេះ ក៏បានទទួលប្រាក់ ៨០០០ដូល្លារនេះ ពីម្ចាស់បំណុល ។
2. រយៈពេលខ្ចី ២៤ខែ (គិតពីថ្ងៃដែលបានប្រគល់ប្រាក់)
3. ការប្រាក់ក្នុងរយៈពេលខ្ចី ១០% ក្នុងមួយឆ្នាំ
4. កូនបំណុលត្រូវសង ៨០០០ដូល្លារ និងការប្រាក់ទៅឱ្យម្ចាស់បំណុល ២៤ខែក្រោយ គឺនៅថ្ងៃទី១ ខែ មិថុនា ឆ្នាំ ២០០៦ ។
5. ក្នុងករណីដែលកូនបំណុលមិនអាចសងប្រាក់ទាំងអស់ តាមកាលកំណត់ខាងលើនេះទេ កូនបំណុលត្រូវបង់ការប្រាក់នៃការយឺតយ៉ាវ ។
   ការប្រាក់នៃការយឺតយ៉ាងគឺ ២០%ក្នុងមួយឆ្នាំ ដែលស្មើនឹងទ្វេដងនៃការប្រាក់ ហើយត្រូវគណនាដោយផ្អែកលើទឹកប្រាក់ដែលសងយឺតយ៉ាវ និងរយៈពេលនៃការសងយឺតយ៉ាវ ។

| | |
|---|---|
| ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៤ | ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៤ |
| មេដៃស្ដាំរបស់ម្ចាស់បំណុល | មេដៃស្ដាំរបស់កូនបំណុល |
| A (ហត្ថលេខា) | B (ហត្ថលេខា) |

# ធនាគារកម្ពុជា

លេខគណនី : 000–999999999 ខៀវ អាត

រូបិយវត្ថុ : ដុល្លារអាមេរិក

របាយការណ៍គណនី (ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ ២០០៦ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៦)

| ថ្ងៃខែប្រតិបត្តិការ | ថ្ងៃខែចាត់ចែង | ខ្លឹមសារប្រតិបត្តិការ | ទឹកប្រាក់ដកចេញ | ទឹកប្រាក់ដាក់ចូល | សមតុល្យ |
|---|---|---|---|---|---|
| | | សមតុល្យពីមុន | | | 15, 500 |
| ១៥ មិថុនា ២០០៦ | ១៥ មិថុនា ២០០៦ | ទឹកប្រាក់ដកចេញ | 10, 000 | | 5, 500 |
| | | សរុប | | | 5, 500 |

ធនាគារកម្ពុជា

ធ្វើដោយសាខាភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

No. 0 0 0 1 1 1

# វិក័យបត្រ

អ្នកលក់

ឈ្មោះ ស្រី ស្រស់ ភេទ អាយុ
មុខរបរ លក់រថយន្តចាស់ៗ
អាសយដ្ឋាន

| | | |
|---|---|---|
| ប្រភេទរថយន្ត | ម៉ូដែល | តូយ៉ូតា កាំរី ឆ្នាំ ១៩៩៥ |
| | លេខតួរថយន្ត | GGGGG555555 |
| | លេខម៉ាស៊ីន | 555555555 |
| | ពណ៌ | ស |
| | លេខរថយន្ត | 1A－1 1 1 1 |

អ្នកទិញ
ឈ្មោះ ខៀវ អាត ភេទ អាយុ
មុខរបរ
អាសយដ្ឋាន

តម្លៃ 5,0 0 0 ដុល្លារអាមេរិក

សូមបញ្ជាក់ថា ខ្ញុំបានទទួលទឹកប្រាក់ខាងលើនេះរួចហើយ ។

ក្រោយពីទិញហើយ មិនអាចដូរវិញបានឡើយ ។

ភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០០៦

| | | |
|---|---|---|
| អ្នកលក់ | សាក្សី | អ្នកទិញ |
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |

# ធនាគារកម្ពុជា

លេខគណនី : 000—123456789 សុខ បូរា

រូបិយវត្ថុ : ដុល្លារអាមេរិក

របាយការណ៍គណនី (ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ ២០០៦ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៦)

| ថ្ងៃខែប្រតិបត្តិការ | ថ្ងៃខែចាត់ចែង | ខ្លឹមសារប្រតិបត្តិការ | ទឹកប្រាក់ដកចេញ | ទឹកប្រាក់ដាក់ចូល | សមតុល្យ |
|---|---|---|---|---|---|
| | | សមតុល្យពីមុន | | | 5, 200 |
| ១ មិថុនា ២០០៦ | ១ មិថុនា ២០០៦ | ទឹកប្រាក់ដកចេញ | 5, 000 | | 200 |
| | | សរុប | 5, 000 | | 200 |

ធនាគារកម្ពុជា

ធ្វើដោយសាខាភ្នំពេញ

# កិច្ចសន្យាខ្ចីបរិភោគ

លិខិតនៃកិច្ចសន្យាខ្ចីបរិភោគ លេខ 0A-99999 B
កិច្ចសន្យាខ្ចីបរិភោគនេះត្រូវបានធ្វើឡើងរវាងម្ចាស់បំណុល និងកូនបំណុលខាងក្រោមនេះ :

ម្ចាស់បំណុល : សៅ ដារា អត្តសញ្ញាណបណ្ណ លេខ 3 3 3 3
ទូរសព្ទលេខ : 012-999-333
អាសយដ្ឋាន : ភូមិ ៣ ឃុំ ....... ស្រុក ...... ខេត្ត X

កូនបំណុល : សុក បូរា អត្តសញ្ញាណបណ្ណ លេខ 2 2 2 2
ទូរសព្ទលេខ : 012-999-222
អាសយដ្ឋាន : No. 34 ផ្លូវលេខ 00 សង្កាត់ផ្សារកណ្តាល ខ័ណ្ឌដូនពេញ ភ្នំពេញ

ភាគីទាំងពីរខាងលើនេះ បានព្រមព្រៀងដូចតទៅ :

1. កូនបំណុលបានខ្ចីប្រាក់ចំនួន ១០០០ដុល្លារ ពីម្ចាស់បំណុល នៅថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៦ ហើយនាថ្ងៃដដែលនេះ ក៏បានទទួលប្រាក់ ១០០០ដុល្លារនេះ ពីម្ចាស់បំណុល ។
2. រយៈពេលខ្ចី ២៤ខែ (គិតពីថ្ងៃដែលបានប្រគល់ប្រាក់)
3. ការប្រាក់ក្នុងរយៈពេលខ្ចី ៥% ក្នុងមួយឆ្នាំ
4. កូនបំណុលត្រូវសង ១០០០ដុល្លារ និងការប្រាក់ទៅឱ្យម្ចាស់បំណុល ២៤ខែក្រោយ គឺនៅថ្ងៃទី១ ខែ មិថុនា ឆ្នាំ ២០០៨ ។
5. ក្នុងករណីដែលកូនបំណុលមិនអាចសងប្រាក់ទាំងអស់ តាមកាលកំណត់ខាងលើនេះទេ កូនបំណុលត្រូវបង់ការប្រាក់នៃការយឺតយ៉ាវ ។
   ការប្រាក់នៃការយឺតយ៉ាងគឺ ១០%ក្នុងមួយឆ្នាំ ដែលស្មើនឹងទ្វេដងនៃការប្រាក់ ហើយត្រូវគណនាដោយផ្អែកលើទឹកប្រាក់ដែលសងយឺតយ៉ាវ និងរយៈពេលនៃការសងយឺតយ៉ាវ ។

| | |
|---|---|
| ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៦ | ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៦ |
| មេដៃស្តាំរបស់ម្ចាស់បំណុល | មេដៃស្តាំរបស់កូនបំណុល |
| សៅ ដារា (ហត្ថលេខា) | សុក បូរា (ហត្ថលេខា) |

ទម្រង់លេខ៥ ( កំណត់ហេតុអំពីការសាកសួរសាក្សី ជាអាទិ៍)

| | |
|---|---|
| កំណត់ហេតុអំពីការសាកសួរ ☑ សាក្សី ☐ សាមីភាគី ☐ អ្នកធ្វើកោសលវិច័យ ☐<br>( កំណត់ហេតុនេះ ត្រូវជាផ្នែកមួយនៃកំណត់ហេតុដែលត្រូវធ្វើឡើង ក្នុងការទាញហេតុផលដោយផ្ទាល់មាត់ លើកទី ១ ) | |
| សញ្ញាណនៃរឿងក្តី | លេខ ១១៧ ចុះថ្ងៃទី ១២ មករា ២០០៧<br>រឿងក្តីទាមទារប្រាក់កំចី |
| កាលបរិច្ឆេទ | ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៧ វេលាម៉ោង ១០:០០ ព្រឹក |
| ឈ្មោះ | គ្រឿង បុប្ផា |
| អាយុ | ៤៤ ឆ្នាំ |
| អាសយដ្ឋាន | No. 34 ផ្លូវលេខ 00 សង្កាត់ផ្សារកណ្តាល ខ័ណ្ឌដូនពេញ ភ្នំពេញ |
| សច្ចាប្រណិធាន<br>និងបញ្ហាផ្សេងៗ | ☑ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ (ឬចៅក្រម) បានពន្យល់អំពីគោលគំនិតនៃការធ្វើសច្ចាប្រណិធាន និង ប្រកាសអំពី :<br>☑ ទណ្ឌកម្មដែលត្រូវដាក់ចំពោះការភូតភរកុហករបស់សាក្សី<br>☐ ទណ្ឌកម្មដែលត្រូវដាក់ចំពោះការភូតភរកុហករបស់សាមីភាគី<br>☐ ទណ្ឌកម្មដែលត្រូវដាក់ចំពោះការផ្តល់សក្ខីកម្មក្លែងក្លាយរបស់អ្នកធ្វើកោសលវិច័យ ។<br>បន្ទាប់មក ប្រធានក្រុមប្រឹក្សាជំនុំជម្រះបានបង្គាប់ឱ្យធ្វើសច្ចាប្រណិធាន ។<br>☐ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ (ឬចៅក្រម) បានប្រកាសរក្សានូវអានុភាពនៃសច្ចាប្រណិធានដែលបានធ្វើពីមុន ។<br>☐ បុគ្គលដែលនឹងត្រូវបានសាកសួរបន្ទាប់ :<br>☐ សាក្សី ☐ អ្នកធ្វើកោសលវិច័យ<br>☐ មិននៅក្នុងសាលសវនាការ<br>☐ នៅក្នុងសាលសវនាការ ដោយបានទទួលការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ (ឬចៅក្រម)<br>☐ |
| ចំណុចសំខាន់ៗនៃសេចក្តីថ្លែងការណ៍ | |
| ដូចរៀបរាប់នៅក្នុងឯកសារឧបសម្ព័ន្ធ | |
| ចប់ | |
| | |
| | |

( កំណត់ ១) សូមគូសសញ្ញា ✓ នៅក្នុងប្រអប់ ☐ ដែលសមស្រប ។

នៅក្នុងសេចក្តីថ្លែងការណ៍នេះ ត្រូវសរសេរ "ចប់" នៅបន្ទាត់បន្ទាប់ពី "បញ្ចប់សេចក្តីថ្លែងការណ៍" ។

(អត្ថាធិប្បាយអំពីការសួរពីអត្តសញ្ញាណ និងសច្ចាប្រណិធាន)

1 *ចៅក្រម* ឥឡូវនេះ ខ្ញុំសុំសួរអំពីរឿងក្តីលើកនេះ ។ ស្តីពីអង្គហេតុដែលគ្មានវិវាទរវាងភាគីទាំងសងខាង ខ្ញុំសុំសួរសំនួរនាំមុខ ។ យ៉ាងដូចម្តេចដែរ លោកតំណាងដើមចោទ និងលោកតំណាងចុងចម្លើយ ?

*តំណាងដោយអាណត្តិទាំងសងខាង* សូមអញ្ជើញ ។

*ចៅក្រម* ហើយខ្ញុំសុំហៅលោកខៀវអាត ថាជាដើមចោទ លោកសូកបូរា ថាជា ចុងចម្លើយ ហើយអ្នកស្រី ខ្ញុំសុំហៅថា សាក្សី ។ យល់ឬទេ ?

2 *គ្រឿង បុប្ផា* ចាំ សូមអញ្ជើញ ។

3 *ចៅក្រម* អ្នកស្រីត្រូវជាប្រពន្ធសុកបូរាមែនឬទេ ?

4 *គ្រឿង បុប្ផា* ចាំ ។

5 *ចៅក្រម* អ្នកស្រីបានទៅផ្ទះដើមចោទខៀវអាត នៅថ្ងៃទី១ មិថុនា ឆ្នាំ ២០០៦ ជាមួយចុងចម្លើយមែនឬទេ ?

6 *គ្រឿង បុប្ផា* ចាំ ពិតមែន ។

7 *ចៅក្រម* តើអ្នកស្រីអញ្ជើញទៅនោះ ក្នុងគោលបំណងអ្វីដែរ ?

8 *គ្រឿង បុប្ផា* ប្តីខ្ញុំគាត់និយាយថា ទៅសងប្រាក់កំចី ឱ្យលោកខៀវអាត ហើយនាងខ្ញុំក៏សុំទៅជាមួយទៅ ។

9 *ចៅក្រម* សូមអ្នកស្រីនិយាយសង្ខេបអំពីរឿងអ្វីៗដែលដើមចោទនិងចុងចម្លើយបាននិយាយគ្នាពេលនោះផង ។

10 *គ្រឿង បុប្ផា* ប្តីខ្ញុំបានសងជូនលោកខៀវអាត ៦០០០ដូល្លារ ដែលជាប្រាក់មួយភាគនៃប្រាក់កំចី ។ បន្ទាប់មក ដើមចោទសួរថា គិតយ៉ាងណាដែរអំពីប្រាក់ដែលនៅសល់ ៣៦០០ដូល្លារនោះ ។ ប្តីខ្ញុំក៏ពន្យល់អំពីជម្ងឺរបស់ឪពុកគាត់ ហើយលោក ខៀវអាតក៏មានចិត្តអាណិតអាសូរដល់គាត់ ហើយក៏បានប្រាប់ថា ៣៦០០ ដូល្លារនោះ មិនបាច់សងទេ ។

11 *ចៅក្រម* ខ្ញុំសុំសួរតាមលំដាប់លំដោយ ។ ប្រាក់ ៦០០០ដូល្លារនោះ តើអ្នកស្រីដឹងថា ត្រៀមយ៉ាងណាដែរឬទេ ?

12 *គ្រឿង បុប្ផា* ចាំ ដឹងដែរ ។

13 *ចៅក្រម* តើបានពីណាមក ?

14 *គ្រឿង បុប្ផា* ប្តីនាងខ្ញុំបាននិយាយថា ត្រូវសងប្រាក់ជូនលោកខៀវអាត ដូច្នេះត្រូវសន្សំ ។ តែឪពុកប្តីខ្ញុំមានជម្ងឺ ហើយត្រូវការប្រាក់ ។ ដើម្បីព្យាបាលជម្ងឺឪពុកប្តីនាងខ្ញុំ គាត់បានចំណាយ

អស់ច្រើន ។ ប្រាក់ដែលនៅសល់ក្នុងគណនីធនាគារ មាន ៥០០០ដូល្លារ ហើយបូកនឹងប្រាក់កំចី ១០០០ដូល្លារដែលបានខ្ចីពីពូនាងខ្ញុំនោះ មានទាំងអស់ ៦០០០ដូល្លារ ។

15 *ចៅក្រម* តើចុងចម្លើយបាននិយាយយ៉ាងណាដែរ ពេលសងនោះ ?

16 *គ្រឿង បុប្ផា* ប្ដីនាងខ្ញុំបាននិយាយថា "មិនអាចត្រៀមបានគ្រប់ចំនួនទេ ដូច្នេះសុំសង ៦០០០ដូល្លារសិន" ហើយគាត់ក៏ជូន ៦០០០ដូល្លារទៅដើមចោទទៅ ។

17 *ចៅក្រម* ដើមចោទនិយាយយ៉ាងណាដែរ ?

18 *គ្រឿង បុប្ផា* ចាំ ! លោកខៀវអាតបានសួរថា "នៅសល់៣៦០០ដូល្លារនោះ គិតយ៉ាងណា ដែរ?"

19 *ចៅក្រម* ពេលនោះ តើស្ថានភាពដើមចោទយ៉ាងណាដែរ ?

20 *គ្រឿង បុប្ផា* លោកខៀវអាត ដូចជាខឹងយ៉ាងខ្លាំង គួរឱ្យខ្លាចបន្តិចដែរ ។ ដោយសារតែសងបានតែមួយភាគ ហេតុនេះហើយ គាត់ច្បាស់ជាខឹងហើយ ។

21 *ចៅក្រម* តើចុងចម្លើយបាននិយាយយ៉ាងណាដែរ ស្ដីពីប្រាក់ ៣៦០០ដូល្លារ ?

22 *គ្រឿង បុប្ផា* ប្ដីនាងខ្ញុំបាននិយាយថា "បំណុលដែលនៅសល់ សូមចាំបន្តិចទៀត" ។

23 *ចៅក្រម* តើគាត់បានពន្យល់អំពីមូលហេតុដែលចង់ពន្យារការសងនោះដែរឬទេ ?

24 *គ្រឿង បុប្ផា* ចាំ ! ប្ដីនាងខ្ញុំបាននិយាយថា ឪពុកគាត់កើតមហារីក ហើយត្រូវទៅវះនៅបាងកក ត្រូវចំណាយអស់ច្រើន ។

25 *ចៅក្រម* អំបាញ់មិញ អ្នកស្រីបាននិយាយអំពី ការសន្សំប្រាក់ដើម្បីសង តើសន្សំនៅក្នុងគណនីធនាគាររបស់អ្នកណា ហើយបានប៉ុន្មានដែរ ?

26 *គ្រឿង បុប្ផា* គណនីធនាគារប្ដីនាងខ្ញុំ ។ និយាយត្រង់ទៅ នាងខ្ញុំមិនដឹងថាសន្សំបានប៉ុន្មានទេ ។ តែគាត់បានប្រាប់លោកខៀវអាតថា គាត់សន្សំបាន ១ម៉ឺនដូល្លារ ។

27 *ចៅក្រម* តើចុងចម្លើយបានសន្យាថា ពេលណាទើបសងដែរឬទេ ?

28 *គ្រឿង បុប្ផា* អត់ទេ គាត់គ្រាន់តែសុំឱ្យចាំបន្តិចទៀតប៉ុណ្ណោះ ។

29 *ចៅក្រម* តើអ្នកស្រីសាមីខ្លួនគិតឃើញថា អង្កាល់ទើបអាចរកប្រាក់ ៣៦០០ដូល្លារសងបាន?

30 *គ្រឿង បុប្ផា* នាងខ្ញុំគិតថា នឹងសងឆាប់ៗ តែមិនបានគិតថា អង្កាល់ទេ ទើបអាចរកប្រាក់នោះសងបាន ។

31 *ចៅក្រម* តើអ្នកស្រីបានពិគ្រោះជាមួយនឹងចុងចម្លើយអំពីការសងបំណុលនេះដែរឬទេ ?

32 *គ្រឿង បុប្ផា* ទេ នាងខ្ញុំមិនដែលបានពិគ្រោះទេ ។

33 *ចៅក្រម* ពេលនោះ តើចុងចម្លើយមានអ្វីជាទីរំពឹង ដើម្បីរកប្រាក់៣៦០០ដូល្លារនោះ ដែរឬទេ ?

34 *គ្រឿង បុប្ផា* នាងខ្ញុំគិតថា នឹងខំប្រឹងប្រែងធ្វើការទាំងពីរនាក់ដើម្បីសងបំណុលនោះ ។

35 *ចៅក្រម* ពេលនោះ តើចុងចម្លើយបាននិយាយអ្វីខ្លះ ក្រៅពីនេះ ជាមួយដើមចោទ?

36 *គ្រឿង បុប្ផា* ប្តីនាងខ្ញុំបានអង្វរគាត់ជាច្រើនដងថា "ក្នុងនាមជាមិត្តសម្លាញ់ សូមជួយគ្នា ផង" ។

37 *ចៅក្រម* តើអ្នកស្រីបាននិយាយអ្វីខ្លះដែរ ?

38 *គ្រឿង បុប្ផា* នាងខ្ញុំក៏បាននិយាយជាច្រើនដងដែរថា "សូមជួយខ្ញុំទាំងពីរផង" ។

39 *ចៅក្រម* ពេលនោះ តើដើមចោទមានប្រតិកម្មយ៉ាងណាដែរ ?

40 *គ្រឿង បុប្ផា* លោកខ្សៅអាតក៏មានប្រសាសន៍ថា "ដឹងហើយ មិនអីទេ។ ៣៦០០ដូល្លារ នោះ
មិនបាច់សងទេ" ។

41 *ចៅក្រម* គេនិយាយថា មិនបាច់សង មែនឬទេ ?

42 *គ្រឿង បុប្ផា* ចាំ អញ្ចឹងមែន។

43 *ចៅក្រម* តើពេលនោះ អ្នកទាំងពីរធ្វើយ៉ាងណាដែរ ?

44 *គ្រឿង បុប្ផា* នាងខ្ញុំនឹងប្តីនាងខ្ញុំ សប្បាយរីករាយយ៉ាងខ្លាំង ហើយបានថ្លែងអំណរគុណគាត់
ជាច្រើនដង។

45 *ចៅក្រម* ស្តីពីវិក័យបត្រ តើបាននិយាយអ្វីខ្លះដែរ ?

46 *គ្រឿង បុប្ផា* បានដែរ ។ ពេលសង៦០០០ដូល្លារ ដំបូងនោះ ប្តីនាងខ្ញុំបានសុំឱ្យលោក ខ្សៅអាត
ចេញវិក័យបត្រដែរ តែគាត់បានបដិសេធមិនចេញឱ្យ។

47 *ចៅក្រម* តើដើមចោទបាននិយាយអ្វីខ្លះ ពេលបដិសេធមិនសរសេរនោះ ?

48 *គ្រឿង បុប្ផា* ចាំ លោកខ្សៅអាតបាននិយាយថា "ដោយសារតែសងមិនគ្រប់ចំនួន ដូច្នេះហើយ
មិនអាចចេញវិក័យបត្របានទេ" ។

49 *ចៅក្រម* ពេលគាត់និយាយថា មិនអាចចេញវិក័យបត្របាន តើចុងចម្លើយនិយាយ អ្វីខ្លះដែរ ?

50 *គ្រឿង បុប្ផា* នាងខ្ញុំមិនចាំដែរ ។

51 *ចៅក្រម* តើចុងចម្លើយបានសុំឱ្យដើមចោទចេញវិក័យបត្រតែម្តង ឬយ៉ាងណាដែរ ?

52 *គ្រឿង បុប្ផា* នាងខ្ញុំចាំមិនច្បាស់ដែរ ប្រហែលតែម្តងក៏មិនដឹង ។

53 *ចៅក្រម* តើអ្នកស្រីបានសុំឱ្យដើមចោទចេញវិក័យបត្រដែរឬទេ ?

54 *គ្រឿង បុប្ផា* ទេ មិនបានសុំទេ។

55 *ចៅក្រម* ហេតុអ្វីបានជាអ្នកស្រីមិនសុំឱ្យគេចេញវិក័យបត្រដូច្នេះ ?

56 *គ្រឿង បុប្ផា* ដោយសារតែនេះគឺជារឿងរវាងប្តីនាងខ្ញុំ និងលោកខ្សៅអាត ដូច្នេះនាងខ្ញុំគិតឃើញថា
នាងខ្ញុំមិនគួរចេញមុខខ្លាំងពេកទេ។

57 *ចៅក្រម* អ្នកស្រីទៅជាមួយប្តីដើម្បីធ្វើអ្វីដែរ ?

58 *គ្រឿង បុប្ផា* ដោយសារតែប្តីនាងខ្ញុំមិនអាចសងឱ្យបានគ្រប់ចំនួន ហេតុនេះហើយ នាងខ្ញុំក៏បានទៅជាមួយ ដើម្បីសុំពន្យារពេលសងនោះ ។

59 *ចៅក្រម* តើអ្នកស្រីយល់ឃើញយ៉ាងណាដែរ អំពីការដែលគេមិនចេញវិក័យបត្រជូន នោះ ?

60 *គ្រឿង បុប្ផា* ពេលនោះ នាងខ្ញុំមិនបានគិតឃើញអ្វីទាំងអស់ ។ ហើយប្តីនាងខ្ញុំមិនបាននិយាយអ្វីលើសពីនេះ ដូច្នេះហើយ នាងខ្ញុំក៏គិតឃើញថា មិនបញ្ហាដែរ ។

61 *ចៅក្រម* តើអ្នកស្រីមិនបានគិតថា បើអត់វិក័យបត្រទៅ ថ្ងៃក្រោយនឹងមានបញ្ហាថា បានសង ឬមិនបានសងទេឬ ?

62 *គ្រឿង បុប្ផា* លោកចៅក្រមមានប្រសាសន៍អញ្ចឹងទៅ នាងខ្ញុំយល់ឃើញអញ្ចឹងដែរ ។ តែពេលនោះគិតមិនឃើញទេ ។

63 *ចៅក្រម* ក្រោយពេលនិយាយអំពីការមិនសរសេរវិក័យបត្រនោះ ទើបដើមចោទបាននិយាយអំពីការលើកលែងប្រាក់ ៣៦០០ដូល្លារនោះ មែនឬទេ ?

64 *គ្រឿង បុប្ផា* ចា៎ អញ្ចឹងមែន ។

65 *ចៅក្រម* ពេលនិយាយថា មិនចេញវិក័យបត្រនោះ តើដើមចោទមានស្ថានភាពយ៉ាង ណាដែរ ?

66 *គ្រឿង បុប្ផា* ពេលនោះ គាត់មិនស្រួលចិត្តទេ ។

67 *ចៅក្រម* ក្រោយពេលនិយាយថា លើកលែង៣៦០០ដូល្លារនោះ តើដើមចោទមានស្ថានភាពយ៉ាងណាដែរ ?

68 *គ្រឿង បុប្ផា* ដូចជាស្ងប់ចិត្ត ។

69 *ចៅក្រម* ពីពេលដែលគាត់និយាយថា មិនចេញវិក័យបត្ររហូតដល់ពេលដែលគាត់បានលើកលែងបំណុលដែលនៅសល់នោះ មានប្រហែលប៉ុន្មាននាទីដែរ ?

70 *គ្រឿង បុប្ផា* នាងខ្ញុំចាំមិនច្បាស់ទេ មើលទៅប្រហែលជា ពី៥ ទៅ១០នាទី ។

71 *ចៅក្រម* ក្រោយពេលមានការលើកលែងបំណុលនោះ តើចុងចម្លើយ ឬអ្នកស្រីបានសុំឱ្យដើមចោទចេញវិក័យបត្រស្តីពីការសង ៦០០០ដូល្លារនោះដែរឬទេ ?

72 *គ្រឿង បុប្ផា* ទេ ទាំងប្តីនាងខ្ញុំ ទាំងនាងខ្ញុំ មិនបានសុំទេ ។

73 *ចៅក្រម* ហេតុអ្វីបានជាមិនបានសុំអញ្ចឹង ?

74 *គ្រឿង បុប្ផា* នាងខ្ញុំសប្បាយចិត្តយ៉ាងខ្លាំងអំពីការលើកលែងបំណុលនោះ បានជាមិនបានគិតដល់ការសុំវិក័យបត្រនោះទេ ។ ប្តីនាងខ្ញុំក៏ប្រហែលជាដូចគ្នាដែរ ។

75 *ចៅក្រម* ចូលដល់ខែកក្កដា ដើមចោទបានចាប់ផ្តើមទៅផ្ទះអ្នកស្រី មែនឬទេ ?

76 *គ្រឿង បុប្ផា* ចាំ ។

77 *ចៅក្រម* តើដើមចោទទៅដើម្បីអ្វីដែរ ?

78 *គ្រឿង បុប្ផា* គាត់បានមកផ្ទះនាងខ្ញុំដោយមិនបានគ្រោងទុក ហើយបានទាមទារឱ្យប្តីនាងខ្ញុំ និងនាងខ្ញុំសងប្រាក់ ៣៦០០ដូល្លារ ។

79 *ចៅក្រម* គាត់បានទាមទារឱ្យសងដោយបញ្ជាក់ទឹកប្រាក់ ៣៦០០ដូល្លារ ឬយ៉ាងណាដែរ ?

80 *គ្រឿង បុប្ផា* ចាំ ។ គាត់ទាមទារឱ្យសងប្រាក់ ៣៦០០ដូល្លារ ។

81 *ចៅក្រម* តើដើមចោទបានទៅផ្ទះអ្នកស្រី ដាស់តឿនឱ្យសងរបៀបហ្នឹងប៉ុន្មានដងដែរ ?

82 *គ្រឿង បុប្ផា* សរុបទាំងអស់ប៉ុន្មានដង នាងខ្ញុំចាំមិនច្បាស់ដែរ តែមកមួយអាទិត្យប្រហែល ជាម្តង ។

83 *ចៅក្រម* ចំពោះការទាមទារនោះ តើចុងចម្លើយធ្វើយ៉ាងណាដែរ ?

84 *គ្រឿង បុប្ផា* ដំបូង គាត់និយាយទៅកាន់លោកខ្សៅរ៍អាតថា "ក្រែងឯងបានលើកលែង ប្រាក់៣៦០០ ដូល្លារនោះហើយ មិនអីចឹង" ។ តែលោកខ្សៅរ៍អាតនិយាយហើយនិយាយទៀតថា "មិនដែលនិយាយលើកលែងទាល់តែសោះ" ។ ហើយពី ខែសីហាមក ប្តីនាងខ្ញុំគាត់លែងចង់ជួប ហើយធ្វើពុតជាមិននៅផ្ទះ ។

85 *ចៅក្រម* តើអ្នកស្រីបាននិយាយអ្វីខ្លះជាមួយនឹងដើមចោទ ?

86 *គ្រឿង បុប្ផា* ចាំ ! ប្តីនាងខ្ញុំគាត់បានប្រាប់ឱ្យនាងខ្ញុំប្រាប់លោកខ្សៅរ៍អាតថា គាត់មិននៅផ្ទះ ទេ ។ ឮដូច្នោះ លោកខ្សៅរ៍អាតខឹងយ៉ាងខ្លាំង ហើយស្រែកជេរថា "សងលុយ អញមក! អាភរ! អាចោរ!" ហើយក៏ធាក់ទ្វារផ្ទះនាងខ្ញុំ ។

87 *ចៅក្រម* ក្រោយពេលដែលដើមចោទបានទៅផ្ទះអ្នកស្រីដើម្បីដាស់តឿនឱ្យសង បំណុល៣៦០០ ដូល្លារដែលនៅសល់នោះ តើបាននិយាយអំពីវិក័យបត្រ ទឹកប្រាក់ចំនួន ៦០០០ដូល្លារនោះដែរឬទេ ?

88 *គ្រឿង បុប្ផា* ទេ  នាងខ្ញុំមិនដឹងដែរ ។

89 *ចៅក្រម* ខ្ញុំសូមបញ្ចប់ការសាកសួររបស់ខ្ញុំត្រឹមនេះហើយ ។ តើលោកតំណាងចុងចម្លើយមានសំនួរឬទេ ?

90 *តំណាងចុងចម្លើយ* បាទ ។ ខ្ញុំជាតំណាងចុងចម្លើយ នឹងសួរដូចតទៅ ។

91 *តំណាងចុងចម្លើយ* ប្រាក់៦០០០ដូល្លារដែលយកទៅសង នោះ តើជាក្រដាស់ប្រាក់អ្វីខ្លះ ហើយមានប៉ុន្មានសន្លឹកដែរ ? អ្នកស្រីចាំឬទេ ។

92 *គ្រឿង បុប្ផា* ចាំ ! ក្រដាស់ប្រាក់ ២០ដូល្លារ មានទាំងអស់ ៣០០សន្លឹក ។

93 *តំណាងចុងចម្លើយ* ហេតុអ្វីបានជាអ្នកស្រីចាំអញ្ចឹង ?

94 *គ្រឿង បុប្ផា* នាងខ្ញុំចាំច្បាស់ណាស់ ដោយសារតែពេលនោះ ប្ដីនាងខ្ញុំឱ្យនាងខ្ញុំរាប់។ ហើយប្ដីនាងខ្ញុំបានប្រគល់ស្បោងនោះ ទៅជូនលោកខៀវអាត។

95 *តំណាងចុងចម្លើយ* តើខ្លួនអ្នកស្រីផ្ទាល់ ធ្លាប់ខ្ចី ឬធ្លាប់ឱ្យគេខ្ចីប្រាក់ដែរឬទេ ?

96 *គ្រឿង បុប្ផា* ទេ មិនដែលទេ។

97 *តំណាងចុងចម្លើយ* តើអ្នកស្រីយល់អំពីសារៈសំខាន់នៃវិក័យបត្រដែរឬទេ ?

98 *គ្រឿង បុប្ផា* ទេ មិនដែលគិតអ្វីឱ្យបានជ្រៅទេ។

99 *តំណាងចុងចម្លើយ* ខ្ញុំសុំប្ដូរសំនួរថ្មី។ ដើមចោទបានទៅផ្ទះអ្នកស្រីនិងចុងចម្លើយឱ្យសងបំណុល ពីខែកក្កដាមក តើនៅខែមិថុនា គេបានទៅដាស់តឿនឱ្យសងដែរឬទេ ?

100 *គ្រឿង បុប្ផា* ទេ មិនដែលទេ។

101 *តំណាងចុងចម្លើយ* ដូច្នេះយ៉ាងតិចណាស់ក៏ពីថ្ងៃទី១មិថុនា មក ប្រហែលជាមួយខែ ដើមចោទមិនបានដាស់តឿនទេ មិនអីចឹង។

102 *គ្រឿង បុប្ផា* ចាំ ពិតមែន។

103 *តំណាងចុងចម្លើយ* ពីខែកក្កដាមក ដើមចោទទាមទារឱ្យសងប៉ុន្មានដែរ ?

104 *គ្រឿង បុប្ផា* ចាំ ៣៦០០ដូល្លារ។

105 *តំណាងចុងចម្លើយ* គាត់មិនមែនទាមទារឱ្យសង ៨០០០ឬ ៩៦០០ដូល្លារទេ ឬ?

106 *គ្រឿង បុប្ផា* ទេ។ មិនដែលទាល់តែសោះ។

107 *តំណាងចុងចម្លើយ* ខ្ញុំសូមបញ្ចប់សំនួរត្រឹមនេះ។

108 *ចៅក្រម* សូមអរគុណ។ សូមអញ្ជើញលោកតំណាងដើមចោទ បើមានសំនួរ។

109 *តំណាងដើមចោទ* សូមអរគុណ លោកចៅក្រម។ បន្ទាប់មក ខ្ញុំសុំសួរ។

110 *តំណាងដើមចោទ* តើអ្នកស្រីបានដឹងថា ពីពេលមុន ដើមចោទបានខ្ចីប្រាក់ពីចុងចម្លើយឬទេ ?

111 *គ្រឿង បុប្ផា* ទេ នាងខ្ញុំមិនដឹងទេ ។

112 *តំណាងដើមចោទ* តើអ្នកស្រីបានដឹងថា នៅក្នុងគណនីធនាគាររបស់ចុងចម្លើយ មានប្រាក់ប៉ុន្មានដែរឬទេ ?

113 *គ្រឿង បុប្ផា* ទេ មិនដែលបានដឹងទេ។

114 *តំណាងដើមចោទ* តើការព្យាបាលជម្ងឺរបស់ឪពុកចុងចម្លើយនោះ ត្រូវបានបន្តទៀត ក្រោយខែ មិថុនា ឆ្នាំ ២០០៦ ដែរឬទេ ?

115 *គ្រឿង បុប្ផា* ដោយសារតែជម្ងឺមហារីក ដូច្នេះត្រូវបានបន្តទៀត។

116 *តំណាងដើមចោទ* តើបានចំណាយអស់ប៉ុន្មានដែរ សំរាប់ការព្យាបាលនោះ ?

117 *គ្រឿង បុប្ផា* នាងខ្ញុំមិនបានដឹងដែរ ។

118 *តំណាងដើមចោទ* នៅរោងពុម្ពដែលជាកន្លែងអាជីវកម្មរបស់អ្នកស្រី និងចុងចម្លើយនោះ ពេលដែលអតិថិជនបង់ប្រាក់អ្នកស្រីចេញវិក័យបត្រឱ្យគេដែរ មែនឬទេ ?

119 *គ្រឿង បុប្ផា* ចា៎ នាងខ្ញុំតែងតែចេញឱ្យ ។

120 *តំណាងដើមចោទ* ការចេញវិក័យបត្រនេះ គឺសំរាប់បង្ការកុំឱ្យមានបញ្ហាថា បានបង់រួច ឬមិន ទាន់បង់ មិនអីចឹង ?

121 *គ្រឿង បុប្ផា* ចា៎ អញ្ចឹងមែន ។

122 *តំណាងដើមចោទ* មានន័យថា វិក័យបត្រគឺជាវត្ថុសំរាប់ បញ្ជាក់ការបង់ប្រាក់ មិនអីចឹង ?

123 *គ្រឿង បុប្ផា* តាមធម្មតា វាអញ្ចឹងមែន ។ តែរវាងប្តីនាងខ្ញុំ និងលោកខៀវអាត គាត់ទាំងពីរជាមិត្តភក្តិនឹងគ្នា នាងខ្ញុំគិតឃើញ ថា ជារឿងផ្សេងទេ ។

124 *តំណាងដើមចោទ* ខ្ញុំសូមបញ្ចប់ការសាកសួររបស់ខ្ញុំនេះ ។

125 *ចៅក្រម* តើលោកតំណាងចុងចម្លើយ មានសំនួរបន្ថែមឬទេ ?

126 *តំណាងចុងចម្លើយ* បាទ អត់ទេ លោកចៅក្រម ។

127 *ចៅក្រម* បើអត់ទេ ខ្ញុំសូមបញ្ចប់ការសាកសួរសាក្សីនេះ ។ សូមអរគុណអ្នកស្រី ។

ចប់

ក្រឡាបញ្ជីតុលាការ



ស៊ុន សេយ៉ុង

ចៅក្រម



ប៉ែន បូរាវី

# ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិត ដែលខ្ញុំបានឃើញ បានឮ បានដឹង និង បានចាំផ្ទាល់ ។

បើខ្ញុំឆ្លើយមិនពិត ដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្ស អ្នកតា និង បារមីដ៏សក្តិសិទ្ធិទាំងអស់ បរាមុខខ្ញុំ ឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និង ស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួញឱ្យខ្ញុំមានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូន កូនចៅ ញាតិផៅសណ្តាន ជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ ។

ទម្រង់លេខ៥ ( កំណត់ហេតុអំពីការសាកសួរសាក្សី ជាអាទិ៍)

| | |
|---|---|
| កំណត់ហេតុអំពីការសាកសួរ ☐ សាក្សី ☑ សាមីភាគី ☐ អ្នកធ្វើកោសលវិច័យ ☐<br>( កំណត់ហេតុនេះ ត្រូវជាផ្នែកមួយនៃកំណត់ហេតុដែលត្រូវធ្វើឡើងនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ លើកទី១ ) | |
| សញ្ញាណនៃរឿងក្តី | លេខ ១១៧ ចុះថ្ងៃទី ១២ មករា ២០០៧<br>រឿងក្តីទាមទារប្រាក់កំចី |
| កាលបរិច្ឆេទ | ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៧ វេលាម៉ោង ១០:០០ ព្រឹក |
| ឈ្មោះ | សុក បូរា |
| អាយុ | ៤៦ ឆ្នាំ |
| អាសយដ្ឋាន | No. 34 ផ្លូវលេខ 00 សង្កាត់ផ្សារកណ្តាល ខ័ណ្ឌដូនពេញ ភ្នំពេញ |
| សច្ចាប្រណិធាន<br>និងបញ្ហាផ្សេងៗ | ☑ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ (ឬចៅក្រម) បានពន្យល់អំពីគោលគំនិតនៃការធ្វើសច្ចាប្រណិធាន និង ប្រកាសអំពី :<br>☐ ទណ្ឌកម្មដែលត្រូវដាក់ចំពោះការភូតភរកុហករបស់សាក្សី<br>☑ ទណ្ឌកម្មដែលត្រូវដាក់ចំពោះការភូតភរកុហករបស់សាមីភាគី<br>☐ ទណ្ឌកម្មដែលត្រូវដាក់ចំពោះការផ្តល់សក្ខីកម្មក្លែងក្លាយរបស់អ្នកធ្វើកោសលវិច័យ ។<br>បន្ទាប់មក ប្រធានក្រុមប្រឹក្សាជំនុំជម្រះបានបង្គាប់ឱ្យធ្វើសច្ចាប្រណិធាន ។<br>☐ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ (ឬចៅក្រម) បានប្រកាសរក្សានូវអានុភាពនៃសច្ចាប្រណិធានដែលបានធ្វើពីមុន ។<br>☐ បុគ្គលដែលនឹងត្រូវបានសាកសួរបន្ទាប់ :<br>☐ សាក្សី ☐ អ្នកធ្វើកោសលវិច័យ<br>☐ មិននៅក្នុងសាលសវនាការ<br>☐ នៅក្នុងសាលសវនាការ ដោយបានទទួលការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ (ឬចៅក្រម)<br>☐ |
| ចំណុចសំខាន់ៗនៃសេចក្តីថ្លែងការណ៍ | |
| ដូចរៀបរាប់នៅក្នុងឯកសារឧបសម្ព័ន្ធ | |
| | ចប់ |
| | |
| | |

( កំណត់ ១) សូមគូសសញ្ញា ✓ នៅក្នុងប្រអប់ ☐ ដែលសមស្រប ។

នៅក្នុងសេចក្តីថ្លែងការណ៍នេះ ត្រូវសរសេរ "ចប់" នៅបន្ទាត់បន្ទាប់ពី "បញ្ចប់សេចក្តីថ្លែងការណ៍" ។

(អត្ថាធិប្បាយអំពីនីតិវិធីធ្វើសច្ចាប្រណិធាន)

1 *ចៅក្រម* បន្ទាប់ពីនេះ ខ្ញុំសូមសួរសំណួរពាក់ព័ន្ធនឹងរឿងក្តីនេះ ។

2

3 *ចៅក្រម* ចុងចម្លើយបានខ្ចី ហើយបានទទួលប្រាក់ ៨០០០ដុល្លារ ពីដើមចោទ ដោយបានធ្វើកិច្ចសន្យានៅថ្ងៃទី១ មិថុនា ឆ្នាំ ២០០៤ ដោយកំណត់រយៈពេលខ្ចី ២៤ខែ ការប្រាក់១០%ក្នុងមួយឆ្នាំ និងការប្រាក់នៃការយឺតយ៉ាវ ២០%ក្នុង មួយឆ្នាំ មែនឬទេ ?

4 *សុក បូរា* បាទ ពិតមែនលោកចៅក្រម ។

5 *ចៅក្រម* នៅថ្ងៃទី១ មិថុនា ឆ្នាំ ២០០៦ ចុងចម្លើយបានទៅផ្ទះលោកខៀវអាត ដែលជាដើមចោទ ជាមួយប្រពន្ធ មែនឬទេ ?

6 *សុក បូរា* បាទ មែន ។

7 *ចៅក្រម* តើលោកអញ្ជើញទៅផ្ទះគាត់ ក្នុងគោលបំណងអ្វីដែរ ?

8 *សុក បូរា* ខ្ញុំទៅផ្ទះលោកខៀវអាត ដើម្បីសងប្រាក់៦០០០ដុល្លារ ដែលជាប្រាក់កំចីមួយភាគ ។

9 *ចៅក្រម* តើលោកត្រូវសងប៉ុន្មានដែរ ?

10 *សុក បូរា* ប្រាក់ដើម បូកសរុបនិងការប្រាក់សំរាប់ពីរឆ្នាំទៀតគឺ ៩៦០០ដុល្លារ ។

11 *ចៅក្រម* តើលោកបានត្រៀម ៩៦០០ដុល្លារឬយ៉ាងណាដែរ ?

12 *សុក បូរា* បាទ ខ្ញុំបានសន្សំមួយខែ ពី៣០០ ទៅ៥០០ ដុល្លារ ដាក់ក្នុងគណនីធនាគារខ្ញុំ បូកសរុបបាន១ម៉ឺនដុល្លារ ។

13 *ចៅក្រម* មានដល់ទៅ១ម៉ឺនដុល្លារដែរ ហេតុអ្វីបានជាលោកមិនសងឱ្យអស់ទៅ ?

14 *សុក បូរា* នៅខួង់ខែមីនា ឆ្នាំ ២០០៦ ឪពុកខ្ញុំ គាត់ក្អកខ្លាំង ហើយគាត់ទៅពេទ្យ គ្រូពេទ្យពិនិត្យទៅឃើញថា គាត់មានជម្ងឺមហារីកសួត ។ ហើយត្រូវទៅវះ នៅបាងកក ចំណាយអស់ប្រហែល ១ម៉ឺនដុល្លារ ។ ខ្ញុំបានខ្ចីប្រាក់ពីសាច់ញាតិខ្លះ១ដែរ តែមិនគ្រប់ ហើយក៏បានដក ៥០០០ដុល្លារពីប្រាក់ដែលខ្ញុំបានសន្សំ ដើម្បីសងនោះទៅ ។

15 *ចៅក្រម* ដូច្នេះ ៦០០០ដុល្លារនោះ តើលោកបានមកពីណាដែរ ?

16 *សុក បូរា* ខ្ញុំបានដក ៥០០០ដុល្លារ ពីគណនីធនាគារខ្ញុំ ហើយ ១០០០ដុល្លារទៀត បានខ្ចីពីពូខាងប្រពន្ធខ្ញុំ ឈ្មោះសៅដារា ។

17 *ចៅក្រម* ដូច្នេះលោកបាននិយាយប្រាប់លោកសៅដារាថា ខ្ចី ១០០០ដុល្លារ ដើម្បីសង

ឱ្យដើមចោទ មែនឬទេ ?

18 *សុក បូរា* ទេ មិនបាននិយាយអំពីបំណុលនេះទេ ព្រោះខ្មាស់គាត់ ។

19 *ចៅក្រម* មុនថ្ងៃទី១ មិថុនា ឆ្នាំ ២០០៦នោះ តើលោកបាននិយាយអំពីជម្ងឺរបស់ឪពុកលោកទៅឱ្យដើមចោទដឹង ដើម្បីសុំពន្យារពេលសងដែរឬទេ ?

20 *សុក បូរា* អត់ទេ មិនដែលសុំពន្យារពេលទេ ។

21 *ចៅក្រម* ហេតុអ្វីបានជាមិនសុំពន្យារពេលមុន?

22 *សុក បូរា* ខ្មាស់គាត់ ដោយសារតែអាចសងបានតែមួយភាគ ហើយគិតឃើញថា ប្រហែលជាអាចរកប្រាក់មកសងគាត់បានគ្រប់ចំនួន ។

23 *ចៅក្រម* ពេលទៅផ្ទះដើមចោទ ល្ងាចថ្ងៃទី១មិថុនានោះ តើលោកបានប្រាប់ដើមចោទមុនដែរឬទេ ?

24 *សុក បូរា* បាទ មុននឹងទៅ ថ្ងៃនោះ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំនឹងយកប្រាក់ទៅសងគាត់ ។

25 *ចៅក្រម* ពេលនោះ តើលោកបាននិយាយប្រាប់គាត់ថា អាចសងតែមួយភាគ គឺ ៦០០០ ដូល្លារដែរឬទេ ?

26 *សុក បូរា* ទេ ខ្ញុំមិនបានប្រាប់ទេ ។

27 *ចៅក្រម* តើលោកបានប្រាប់ឱ្យដើមចោទ ត្រៀមវិក័យបត្រទុកមុនដែរឬទេ ?

28 *សុក បូរា* ទេ មិនបានទេ ។

29 *ចៅក្រម* ហេតុអ្វីបានជាមិនប្រាប់គាត់ជាមុន ថា យក៦០០០ដូល្លារទៅសងគាត់ ហើយឱ្យគាត់ត្រៀមវិក័យបត្រដែរទៅ ។

30 *សុក បូរា* ពេលនោះ ខ្ញុំគិតឃើញតែបញ្ហាសងមិនបានគ្រប់ចំនួន ក្រៅពីហ្នឹងគ្មានគិតឃើញអ្វីទាំងអស់ ។

31 *ចៅក្រម* តើនៅផ្ទះដើមចោទ លោកបាននិយាយអ្វីខ្លះដែរ ?

32 *សុក បូរា* ខ្ញុំបានសងលោកខៀវអាត ៦០០០ ដូល្លារ ។ នៅ ៣៦០០ដូល្លារទៀត ខ្ញុំបានសុំឱ្យគាត់ពន្យារពេលបន្តិច ។ ពេលនោះ ខ្ញុំបានប្រាប់គាត់អំពីជម្ងឺរបស់ ឪពុកខ្ញុំ ហើយគាត់ក៏មានចិត្តអាណិតអាសូរខ្ញុំ គាត់ក៏លើកលែងបំណុល ៣៦០០ដូល្លារនោះទៅ ។ ពេលនោះ ខ្ញុំបានសុំឱ្យគាត់ចេញវិក័យបត្រ ៦០០០ដូល្លារនោះដែរ តែគាត់ប្រកែកមិនចេញឱ្យខ្ញុំទេ ។

33 *ចៅក្រម* ពេលសងប្រាក់នោះ តើលោកបាននិយាយអ្វីខ្លះចំពោះដើមចោទ ?

34 *សុក បូរា* ខ្ញុំបាននិយាយថា "ខ្ញុំត្រៀមប្រាក់មិនបានគ្រប់ចំនួនទេ ។ ថ្ងៃនេះ ខ្ញុំយកមកតែ ៦០០០ ដូល្លារប៉ុណ្ណោះ សូមចេញវិក័យបត្រ ៦០០០ដូល្លារ ឱ្យខ្ញុំផង "ហើយ

ក៏ហុចប្រាក់ ៦០០០ដូល្លារដែលខ្ញុំបានដាក់ក្នុងស្បោងមួយ ជូនគាត់ទៅ។

35 *ចៅក្រម* សូមពន្យល់អំពីក្រដាស់ប្រាក់៦០០០ដូល្លារនោះផង។

36 *សុក បូរា* ក្រដាស់ ២០ដូល្លារ ចំនួន៣០០សន្លឹក។

37 *ចៅក្រម* លោកបានសងប្រាក់ ៦០០០ដូល្លារ ហើយបានសុំឱ្យគាត់សរសេរវិក័យបត្រ មែនឬទេ ?

38 *សុក បូរា* បាទ ពិតមែន ។

39 *ចៅក្រម* ពេលនោះ តើដើមចោទមានប្រតិកម្មយ៉ាងណាដែរ .?

40 *សុក បូរា* គាត់បាននិយាយថា "ពិតមែនតែបានទទួលប្រាក់ ៦០០០ដូល្លារ តែដោយសារមិនបានគ្រប់ចំនួន ដូច្នេះមិនអាចចេញវិក័យបត្របានទេ" ។

41 *ចៅក្រម* ហេតុអ្វីបានជាចុងចម្លើយសុំឱ្យដើមចោទចេញវិក័យបត្រដូច្នេះ ?

42 *សុក បូរា* ពេលខ្ចី ឬសងប្រាក់ ខ្ញុំតែងតែគិតឃើញថា ត្រូវមានវិក័យបត្រ ។

43 *ចៅក្រម* ពីមុនៗ តើចុងចម្លើយធ្លាប់ឱ្យដើមចោទខ្ចីប្រាក់ដែរឬទេ ?

44 *សុក បូរា* បាទ ដែលដែរ ។

45 *ចៅក្រម* ចាំះ ពេលដែលដើមចោទសងប្រាក់កំចីនោះ តើលោកបានចេញវិក័យបត្រឱ្យគាត់ដែរឬទេ ?

46 *សុក បូរា* បាទ បានសរសេរដែរ។

47 *ចៅក្រម* ពេលនោះ តើលោកសរសេរដោយខ្លួនឯង ឬក៏ដើមចោទប្រាប់ឱ្យសរសេរ ?

48 *សុក បូរា* លោកខៀវអាតជាមនុស្សប្រឹតប្រៀងណាស់ គាត់ជាអ្នកប្រាប់ឱ្យខ្ញុំសរសេរ។

49 *ចៅក្រម* លើកនេះ នៅថ្ងៃទី១ មិថុនានោះ ពេលសង ៦០០០ដូល្លារ គេបាននិយាយថាមិនចេញវិក័យបត្រ តើលោកគិតឃើញយ៉ាងណាដែរ ?

50 *សុក បូរា* សងមិនគ្រប់ចំនួន គាត់មិនចេញវិក័យបត្រ ដូចជាមិនសមសោះ។ ក៏ប៉ុន្តែពេលនោះ ខ្ញុំគិតឃើញថា ដើមចោទខឹងខ្លាំងដោយសារតែមិនបានសងឱ្យគាត់គ្រប់ចំនួន ដូច្នេះខ្ញុំក៏គិតឃើញថា មិនដឹងធ្វើម៉េច។

51 *ចៅក្រម* តើលោកបានទារឱ្យគាត់សរសេរវិក័យបត្រម្តងទៀតឬទេ ?

52 *សុក បូរា* អត់ទេ ។

53 *ចៅក្រម* ហេតុអ្វីបានជាលោកមិនទាមទារឱ្យដើមចោទសរសេរវិក័យបត្រចំពោះទឹកប្រាក់ ៦០០០ដូល្លារនោះម្តងទៀត។

54 *សុក បូរា* ខ្ញុំនិងដើមចោទ ត្រូវជាមិត្តភក្តិយូរណាស់មកហើយ ដូច្នេះខ្ញុំមិនដែលគិតឃើញថា នឹងមានបញ្ហាសង ឬអត់នេះទេ។ ពេលនោះ ខ្ញុំសងនៅខ្វះ៣៦០០ដូល្លារទៀត ហើយគ្មានអ្វីអាចដោះសារកើត ផងដែរ។

55 *ចៅក្រម* ចំពោះប្រាក់ដែលនៅសល់ ៣៦០០ដូល្លារនោះ តើដើមចោទបាននិយាយយ៉ាង ណាដែរ ?

56 *សុក បូរា* គាត់បាននិយាយថា "ប្រាក់៣៦០០ ដូល្លារដែលនៅសល់នោះ ពេលណាទើប អាចសងបាន"។

57 *ចៅក្រម* តើលោកឆ្លើយយ៉ាងណាដែរ ?

58 *សុក បូរា* ខ្ញុំសូមទោសគាត់ ហើយឆ្លើយថា "ខ្ញុំនឹងខំសងឱ្យបានយ៉ាងឆាប់។ ខ្ញុំខំសន្សំបាន ១ម៉ឺនដូល្លារដែរ តែឪពុកខ្ញុំមានជម្ងឺ ត្រូវវះនៅបាងកក ហើយអាចសងបានតែ ៦០០០ដូល្លារទេ"។

59 *ចៅក្រម* តើលោកគិតសង៣៦០០ដូល្លារនោះពេលណាដែរ ?

60 *សុក បូរា* ខ្ញុំគិតថា នឹងខំប្រឹងប្រែងសងឱ្យបានរហ័ស ។

61 *ចៅក្រម* តើលោកគិតរកប្រាក់យ៉ាងណាដើម្បីសង?

62 *សុក បូរា* ខ្ញុំគិតថា នឹងខំប្រឹងប្រែងធ្វើការ ហើយសន្សំសំរាប់សង។

63 *ចៅក្រម* តើជម្ងឺឪពុកលោក វះហើយបានជាសះស្បើយហើយឬនៅ ?

64 *សុក បូរា* អត់ទេ។ ដោយសារតែជាជម្ងឺមហារីកដូច្នេះក្រោយពីវះនៅបាងកកនៅខែ ឧសភា ហើយ គ្រូពេទ្យនិយាយថា ត្រឡប់មកកម្ពុជាវិញ ត្រូវព្យាបាលបន្តទៀត។

65 *ចៅក្រម* ក្រោយពេលវះហើយ តើគ្រូពេទ្យបាននិយាយថា ដើម្បីព្យាបាល ត្រូវចំណាយ អស់ប៉ុន្មានទៀត ឬទេ ?

66 *សុក បូរា* បាទមាន ។ គាត់ប្រាប់ថា ត្រូវចំណាយអស់ប្រហែល ១ម៉ឺនដូល្លារទៀត ។

67 *ចៅក្រម* ជាក់ស្តែង តើលោកបានបង់ចំណាយសំរាប់ព្យាបាលអស់ប៉ុន្មានដែរ ក្រោយ វះកាត់នោះ។

68 *សុក បូរា* ឪពុកខ្ញុំគាត់ស្លាប់នៅខែធ្នូ ឆ្នាំ ២០០៦ ក្រោយពេលត្រឡប់ពីបាងកកនៅខែ កក្កដាមក ចំណាយអស់ប្រហែល ៨០០០ដូល្លារទៀត។

69 *ចៅក្រម* តើលោកបានបង់តែម្តង ឬយ៉ាងណាដែរ ?

70 *សុក បូរា* ទេ។ តាមខ្ញុំចាំ នៅខែកក្កដា ខ្ញុំបានបង់ថ្លៃពេទ្យប្រហែលខ្ទង់៤០០០ដូល្លារ ហើយពីខែសីហា ដល់ខែធ្នូ ខ្ញុំបានបង់ប្រហែល១០០០ដូល្លារក្នុងមួយខែ។

71 *ចៅក្រម* តើប្រាក់នោះ លោករកបានពីណាដែរ ?

72 *សុក បូរា* ខ្ញុំបានខ្ចីពីគេខ្លះៗ ហើយសន្សំសំចៃដោយកាត់បន្ថយចំណាយប្រចាំថ្ងៃ។

73 *ចៅក្រម* ពេលដែលលោកនិយាយអំពីជម្ងឺរបស់ឪពុកលោកទៅ តើដើមចោទមានប្រតិកម្មយ៉ាងណាដែរ ?

74 *សុក បូរា* គាត់និយាយថា "អូ!អីចឹង!ឯងក៏ពិបាកណាស់ណាដែរហ្ន៎! ប្រាក់ដែលនៅខ្វះនោះមិនបាច់សងទេ" ។

75 *ចៅក្រម* តើពេលនោះ លោកធ្វើយ៉ាងណាដែរ ?

76 *សុក បូរា* ពេលនោះ ខ្ញុំភ្ញាក់យ៉ាងខ្លាំង ហើយនិយាយចំពោះលោកខៀវអាតថា "សូមអរគុណ។ នេះចំជាមិត្តសម្លាញ់មែន" ។ ហើយពេលនោះ ប្រពន្ធខ្ញុំដែលនៅចំហៀងខ្ញុំក៏បានថ្លែងអំណរគុណផងដែរ ។

77 *ចៅក្រម* ដូច្នេះ លោកគ្មានគិតរំពឹងថា ដើមចោទនឹងលើកលែង ៣៦០០ដូល្លារឱ្យទេ មិនអីចឹង ?

78 *សុក បូរា* បាទ  អត់ទេ។

79 *ចៅក្រម* ហេតុអ្វីបានជាអីចឹង ?

80 *សុក បូរា* ទឹកប្រាក់ ៣៦០០ដូល្លារ មិនជាតិចទេ។ ក៏ប៉ុន្តែ ដើមចោទជាអ្នកមានដែរ ហើយខ្ញុំក៏បានគិតឃើញខ្លះដែរថា  ប្រហែលជាអាចមានការលើកលែងក៏មិនដឹង។

81 *ចៅក្រម* ក្រោយពេលគេសួរលោកថា  អង្កាល់ទើបអាចសងប្រាក់ដែលនៅសល់ រហូតដល់ពេលគេលើកលែងនោះ តើមានរយៈពេលប្រហែលប៉ុន្មានដែរ ?

82 *សុក បូរា* ខ្ញុំចាំមិនច្បាស់ទេ តែប្រហែលជា ១០នាទីមើលទៅ ។

83 *ចៅក្រម* ក្នុងរយៈពេល ១០នាទីនោះ តើលោកបាននិយាយអ្វីក្រៅពីជម្ងឺរបស់ឪពុកលោកដែរឬទេ ?

84 *សុក បូរា* ក្រៅពីនោះ អត់ទេ ។

85 *ចៅក្រម* ក្រោយពេលគេលើកលែងនោះ តើ លោកបានសុំឱ្យគេចេញវិក័យបត្រ ៦000 ដូល្លារនោះដែរឬទេ ?

86 *សុក បូរា* ទេ  អត់បានសុំទេ ។

87 *ចៅក្រម* ហេតុអ្វីដែរ ?

88 *សុក បូរា* ដោយសារតែគេលើកលែង ខ្ញុំក៏សប្បាយចិត្តខ្លាំង ភ្លេចរឿងហ្នឹងទៅ ។

89 *ចៅក្រម* តើបានសុំឱ្យគេសរសេរសំបុត្រស្នាមអំពីការលើកលែងនោះដែរ ឬទេ ?

90 *សុក បូរា* ទេ  មិនបានសុំទេ ។

91 *ចៅក្រម* ហេតុអ្វីដែរ ?

92 *សុក ប៊ូរ៉ា* ដោយសារតែគាត់ជាមិត្តផង ហើយណាមួយ ខ្ញុំសប្បាយចិត្តខ្លាំងដោយសារការលើកលែងនោះ គ្មានទឹកឃើញអ្វីទេ ពេលនោះ ។

93 *ចៅក្រម* ក្រោយថ្ងៃទី១ មិថុនា តើដើមចោទបានទាក់ទងនឹងលោកដែរឬទេ ?

94 *សុក ប៊ូរ៉ា* ក្នុងខែមិថុនានោះ គេមិនបានទាក់ទងមកទេ ។ តែចូលខែកក្កដា ស្រាប់តែគាត់ទាមទារឱ្យខ្ញុំសង ៣៦០០ដុល្លារ ។

95 *ចៅក្រម* ពេលគេនិយាយដូច្នេះ តើលោកគិតធ្វើយ៉ាងណាដែរ ?

96 *សុក ប៊ូរ៉ា* ខ្ញុំគិតឃើញថា វាមិនសម ព្រោះគាត់បានលើកលែង៣៦០០ដុល្លារឱ្យខ្ញុំរួច ហើយ ។ ដូច្នេះហើយបានជា ដំបូងខ្ញុំបានជួបគាត់ប៉ុន្មានដងដែរ តែក្រោយពីនោះ ខ្ញុំបានធ្វើជាអត់នៅផ្ទះ ។ លុះចូលដល់ខ្ទង់ខែកក្កដា ស្រាប់តែខ្សែវអាតបានមកផ្ទះខ្ញុំសឹងតែរាល់ថ្ងៃ ហើយស្រែកជេរខ្ញុំថា "អាចោរ! សងប្រាក់អញមក! ៗ" ។

97 *ចៅក្រម* ហេតុអ្វីបានជាដើមចោទធ្វើដូច្នេះ ?

98 *សុក ប៊ូរ៉ា* ខ្ញុំមិនដឹងអំពីមូលហេតុទេ ។ ខ្ញុំគិតឃើញថា គាត់ធ្វើអញ្ចឹងទៅ ដូចជាក្បត់មិត្តភក្តិដែរ ។

99 *ចៅក្រម* ក្រោយខែកក្កដា តើលោកធ្លាប់បានបញ្ជាក់ពីទៅដើមចោទថា លោកបានសង ៦០០០ដុល្លាររួចហើយ ឬទេ ?

100 *សុក ប៊ូរ៉ា* ទេ មិនដែលទេ ។

101 *ចៅក្រម* ខ្ញុំសូមបញ្ចប់សំនួររបស់ខ្ញុំត្រឹមនេះហើយ ។ លោកតំណាងចុងចម្លើយ តើលោកចង់សួរបញ្ជាក់អ្វីបន្ថែមទៀត ឬទេ ?

102 *តំណាងចុងចម្លើយ* បាទ លោកចៅក្រម ។ បន្ទាប់ពីនេះ ខ្ញុំសូមសួរ ដូច្នេះសូមចុងចម្លើយ មើលទៅលោកចៅក្រម ហើយឆ្លើយឱ្យឮបានច្បាស់ៗ ។

103 *តំណាងចុងចម្លើយ* លោកចៅក្រម ខ្ញុំសុំបង្ហាញភស្តុតាង Y1 តើបានឬទេ ?

104 *ចៅក្រម* សូមអញ្ជើញ ។

(បង្ហាញភស្តុតាង Y1 បណ្តើរ) (1:00:49)

105 *តំណាងចុងចម្លើយ* តាមរបាយការណ៍ធនាគារនេះ នៅថ្ងៃទី១មិថុនា លោកបានដកប្រាក់ ៥០០០ ដុល្លារពីគណនីលោក ហើយនេះគឺជាប្រាក់មួយភាគនៃប្រាក់ ៦០០០ដុល្លារ ដែលលោកបានសងទៅឱ្យដើមចោទ មែនឬទេ ?

106 *សុក ប៊ូរ៉ា* បាទ ហ្នឹងហើយ ។

107 *តំណាងចុងចម្លើយ* នៅថ្ងៃទី១ មិថុនា ឆ្នាំ ២០០៦ នោះ លោកគ្មានគិតឃើញថា ដើមចោទនឹងធ្វើបណ្តឹងនៅថ្ងៃណាមួយទេ មិនអីចឹង ។

108 *សុក បូរា* មិនដែលនឹកឃើញទាល់តែសោះ ។

109 *តំណាងចុងចម្លើយ* លោកបានបង់ថ្លៃព្យាបាលជម្ងឺឪពុកលោក នៅខែកក្កដា មិនមែនខែមិថុនាទេ មិនអីចឹង ?

110 *សុក បូរា* បាទ មែន ។

111 *តំណាងចុងចម្លើយ* មានន័យថា នៅខែមិថុនា លោកបានដកប្រាក់ពីធនាគារនោះ គឺសំរាប់តែសងបំណុលទៅឱ្យដើមចោទប៉ុណ្ណោះ ក្រៅពីនេះ លោកគ្មានមូលហេតុអ្វីនឹងដកប្រាក់ទេ មិនអីចឹង ?

112 *សុក បូរា* បាន មែនហើយ ។ នៅថ្ងៃទី១ មិថុនានោះ ខ្ញុំមិនដែលគិតឃើញថា ដកប្រាក់ដើម្បីយកមកសំអាងហេតុភូតភរថា ខ្ញុំបានសងប្រាក់ទៅឱ្យខៀវអាត ក្នុងរឿងក្តីនេះជាដាច់ខាត ។

113 *តំណាងចុងចម្លើយ* លោកចៅក្រម ខ្ញុំសុំបង្ហាញភស្តុតាង Y2 តើបានឬទេ ?

114 *ចៅក្រម* បាទ សូមអញ្ជើញ ។

(តំណាងចុងចម្លើយ: បង្ហាញភស្តុតាង Y2 បណ្តើរ) (1:02:49)

115 *តំណាងចុងចម្លើយ* នេះគឺជាកិច្ចសន្យាខ្ចីបរិភោគដែលលោកបានធ្វើជាមួយនឹងលោកសៅដារា អំពីប្រាក់កំចី ១០០០ដូល្លារ ហើយដែលជាប្រាក់មួយភាគ នៃប្រាក់៦០០០ ដូល្លារ មែនឬទេ ?

116 *សុក បូរា* បាទ មែន ។ បូកនឹងប្រាក់ដែលបានដកពីធនាគារទៅ សរុបទាំងអស់បាន ៦០០០ដូល្លារ ។

117 *តំណាងចុងចម្លើយ* ប្រាក់៦០០០ដូល្លារដែលលោកបានសងឱ្យដើមចោទ តើលោកបានឃើញដើមចោទចំណាយទៅលើអ្វីដែរឬទេ ?

118 *សុក បូរា* បាទ ឃើញ ។

119 *តំណាងចុងចម្លើយ* តើគាត់ចាយទៅលើអ្វីដែរ ។

120 *សុក បូរា* តាមមើល គាត់យកទៅទិញរថយន្ត ម៉ាកតូយ៉ូតាកាំរីហើយ ។ ពេលមុនខ្ញុំមិនដែលឃើញគាត់មានរថយន្តកាំរីទេ តែក្រោយថ្ងៃទី១មិថុនាខ្ញុំឃើញខៀវអារុណ កូនប្រុសច្បងលោកខៀវអាត ជិះរថយន្តកាំរីប៉ុន្មានដងដែរ ។

121 *តំណាងចុងចម្លើយ* ចំពោះលោក ៗមានចិត្តសុំទោសដើមចោទដោយសារតែលោកមិនអាចសងឱ្យបានគ្រប់ចំនួន គឺ៩៦០០ដូល្លារ នៅថ្ងៃទី១ មិថុនានោះតាមកិច្ចសន្យាមែន ឬទេ ?

122 *សុក បូរា* បាទ ពិតមែន ។

123 *តំណាងចុងចម្លើយ* ដោយសារតែមានចិត្តដូចនេះហើយ បានជាលោកមិនអាចទាមទារខ្លាំងឱ្យដើមចោទចេញវិក័យបត្រ មែនឬទេ?

124 *សុក បូរា* បាទពិតមែនហើយ ។ ដោយសារតែមានចិត្តសុំទោសនេះហើយ បានជាខ្ញុំមិនហ៊ានទាមទារខ្លាំង ឱ្យគាត់ចេញវិក័យបត្រនោះ ។ ឥឡូវនេះ ខ្ញុំមានការសោកស្ដាយយ៉ាងខ្លាំង ។

125 *តំណាងចុងចម្លើយ* ខ្ញុំសូមបញ្ចប់សំនួរត្រឹមនេះហើយ ។

126 *ចៅក្រម* សូមអញ្ជើញលោកតំណាងដើមចោទ ។

127 *តំណាងដើមចោទ* លោកចៅក្រម ខ្ញុំមានសំនួរមួយចំនួនដែរ ។

128 *តំណាងដើមចោទ* ខ្ញុំសុំសួរពាក់ព័ន្ធនឹងវិក័យបត្រ ។ ពេលដែលដើមចោទនិយាយថា គាត់មិនអាចចេញវិក័យបត្រជូន ដោយសារតែសងមិនគ្រប់ចំនួន ហេតុអ្វីបានជាពេលនោះលោកមិននិយាយវិញថា បើមិនសរសេរវិក័យបត្រទេ សូមសង ៦០០០ដូល្លារមកវិញអីចឹង ?

129 *សុក បូរា* ខ្ញុំមិនបាននិយាយទេ ។

130 *តំណាងដើមចោទ* ពេលមុន ពេលដែលដើមចោទសងប្រាក់កំចី ១០០០ដូល្លារជូនលោក១បាន ចេញវិក័យបត្រតាមការទាមទាររបស់ដើមចោទ មិនអីចឹង ។ ហេតុអ្វីបានជាលោកមិនទាមទារដូចគ្នាដែរទៅ ?

131 *សុក បូរា* បាទ ខ្ញុំមិនបានទាមទារទេ ។

132 *តំណាងដើមចោទ* លោកដឹងដែរថា វិក័យបត្រ គឺជាវត្ថុសំរាប់បញ្ជាក់ថា បានសងប្រាក់ មិនអី ចឹង ។

133 *សុក បូរា* បាទ ដឹងដែរ ។ ក៏ប៉ុន្តែដោយសារតែលោកខៀវអាត ជាមិត្តភក្តិខ្ញុំ ហេតុនេះ ហើយខ្ញុំក៏មិនគិតឃើញថា វាធ្ងន់ដល់ម្លឹងទេ ។

134 *តំណាងដើមចោទ* លោកបានខ្ចីប្រាក់ពីលោកសៅដារា ដែលជាសាច់ញាតិនោះ ដោយមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរមិនអីចឹង ។

135 *សុក បូរា* បាទមែន ។

136 *តំណាងដើមចោទ* ទោះជាវវាងសាច់ញាតិក៏ដោយ ក៏លោកបានសន្យាបង់ការប្រាក់ត្រឹមត្រូវ មិនអីចឹង?

137 *សុក បូរា* បាទ ។

138 *តំណាងដើមចោទ* ទោះជាច្បាប់យ៉ាងណាក៏ដោយ តែរវាងសាច់ញាតិ ខ្ញុំយល់ឃើញថា មិនចាំបាច់មានកិច្ចសន្យាជាលាយលក្ខណ៍អក្សរទេ មិនអីចឹង?

139 *សុក បូរា* នេះគឺដោយសារតែ ១០០០ដុល្លារ ជាទឹកប្រាក់ចំនួនច្រើន ហេតុនេះហើយ ខ្ញុំក៏មិនចង់ឱ្យមានវិវាទស្តីពីខ្លឹមសារនៃកិច្ចសន្យានោះ ឬមិនចង់ឱ្យមានបញ្ហាថា បានប្រគល់ប្រាក់ ជាដើម នៅពេលក្រោយ ដូច្នេះហើយទោះជាសាច់ញាតិ ក៏ដោយ ក៏ខ្ញុំត្រូវធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរដែរ ។

140 *តំណាងដើមចោទ* ដូច្នេះមានន័យថា ទោះជារវាងសាច់ញាតិក៏ដោយ ក៏លោកយល់ឃើញថា កិច្ចសន្យាមានសារៈសំខាន់ណាស់ពាក់ព័ន្ធនឹងការខ្ចីប្រាក់ មិនអីចឹង?

141 *សុក បូរា* ・・・・បាទ។

142 *តំណាងដើមចោទ* ហើយរវាងដើមចោទ ដែលគ្រាន់តែជាមិត្តនោះ លោកក៏ដឹងណាស់ហើយថា វិក័យបត្រមានសារៈសំខាន់ណាស់ មែនឬទេ ?

143 *សុក បូរា* ・・・・・・・・(ឱនក្បាល មិននិយាយអ្វីទាំងអស់)

144 *តំណាងដើមចោទ* បើលោកមិនឆ្លើយទេ ខ្ញុំសូមសួរសំនួរផ្សេងទៀត។ យោលតាមសំដីរបស់ លោក ៗបានសង៦០០០ដូល្លារ ហើយដើមចោទបាន លើកលែង៣៦០០ ដូល្លារ ដូច្នេះលោក អស់មានជំពាក់បំណុលដើមចោទទៀតហើយ មិនអីចឹង។

145 *សុក បូរា* បាទ។

146 *តំណាងដើមចោទ* បើអីចឹង ប្រសិនជាលោកសុំឱ្យដើមចោទចេញវិក័យបត្រ គេច្បាស់ជាចេញ ឱ្យហើយ មិនអីចឹង?

147 *សុក បូរា* ប្រហែលជាអីចឹងក៏មិនដឹងដែរ។ ប៉ុន្តែ ខ្ញុំមិនបានសុំទេ ដូច្នេះមិនដឹងជាឆ្លើយ យ៉ាងណាទេ។

148 *តំណាងដើមចោទ* បន្ទាប់មក ខ្ញុំសូមសួរអំពីចំណាយសំរាប់ព្យាបាលឪពុកចុងចម្លើយជាបន្តបន្ទាប់ នោះវិញ បូកសរុបអស់៨០០០ដូល្លារ តើលោករកបានពីណាមក? តើលោក ខ្ចីពីអ្នកណាខ្លះ?

149 *សុក បូរា* ខ្ញុំបានខ្ចីពីច្រើននាក់ ដូច្នេះចាំមិនច្បាស់ទេ ។

150 *តំណាងដើមចោទ* នៅដំណាក់កាលនៃខែកក្កដា លោកបាននិយាយថា លោកបានបង់អស់ ៤០០០ដូល្លារ តើលោកខ្ចីប្រាក់នោះពីអ្នកណាដែរ?

151 *សុក បូរា* គឺជាប្រាក់ដែលបានមកពីធ្វើការ ហើយនិងប្រាក់កំចី។

152 *តំណាងដើមចោទ* តើលោកខ្ចីពីអ្នកណាដែរ?

153 *សុក បូរា* ខ្ញុំមិនចាំទេ។

154 *តំណាងដើមចោទ* ពេលខែកក្កដានោះ ប្រសិនជាមានអ្នកឱ្យលោកខ្ចី ហេតុអ្វីបានជាលោកមិនខ្ចី ពីអ្នកនោះ ដើម្បីសងដើមចោទ ៩៦០០ដូល្លារនៅថ្ងៃទី១ មិថុនាដែរទៅ ?

155 *សុក បូរា* ពេលនោះ ខ្ញុំមិនបានខ្ចីទេ ។

156 *តំណាងដើមចោទ* នៅថ្ងៃទី១ មិថុនា លោកបានដក៥០០០ដូល្លារ ហើយនៅក្នុងគណនីធនាគារ របស់លោក នៅសល់២០០ដូល្លារ ។ ហេតុអ្វីបានជាលោកមិនយក ២០០ ដូល្លារនោះ ទៅបង់ថ្លៃពេទ្យដែរទៅ?

157 *សុក បូរា* ប្រហែលជាបានយកទៅបង់ដែរក៏មិនដឹង ចាំមិនច្បាស់ទេ ។

158 *តំណាងដើមចោទ* តាមពិត លោកបានយកប្រាក់ ៦០០០ដូល្លារដែលលោកនិយាយថា សងទៅ ឱ្យដើមចោទនោះ បង់សំរាប់ព្យាបាលឪពុកលោកបន្តទៀតមិនអីចឹង ?

159 *សុក បូរា* ទេ មិនមែនទេ។ ខ្ញុំមិនភូតភរទេ សូមជឿខ្ញុំចុះ។

160 *តំណាងដើមចោទ* ខ្ញុំសូមបញ្ចប់ត្រឹមនេះហើយ លោកចៅក្រម។

161 *ចៅក្រម* លោកតំណាងចុងចម្លើយ តើលោកមានសំនួរបន្ថែមឬទេ ?

162 *តំណាងចុងចម្លើយ* បាទអត់ទេ លោកចៅក្រម ។

163 *ចៅក្រម* បើអីចឹង ខ្ញុំសុំសួរមួយទៀត។ ស្តីពីវិក័យបត្របង់ថ្លៃពេទ្យ តើលោកមាន ឬទេ ?

164 *សុក បូរា* ប្រហែលជាខ្ញុំចោលអស់ទៅហើយ ។

165 *ចៅក្រម* បាទ សូមអរគុណ។

166 *ចៅក្រម* ដូច្នេះ ខ្ញុំសូមបញ្ចប់ការសាកសួរ ចុងចម្លើយត្រឹមនេះ។ សូមអរគុណ ចុងចម្លើយ ។

ចប់

ក្រឡាបញ្ជីតុលាការ



ស៊ុន សេយ៉ុង

ចៅក្រម



ប៉ែន បូរាវី

## ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិត ដែលខ្ញុំបានឃើញ បានឮ បានដឹង និង បានចាំផ្ទាល់ ។

បើខ្ញុំឆ្លើយមិនពិត ដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្ស អ្នកតា និង បារមីដ៏សក្តិសិទ្ធិទាំងអស់ បរាមុខខ្ញុំ ឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និង ស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួញឱ្យខ្ញុំមានទ្រព្យសម្បត្តិសម្បូរណ៌ហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូន កូនចៅ ញាតិផៅសណ្តាន ជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ ។

ទម្រង់លេខ៥ ( កំណត់ហេតុអំពីការសាកសួរសាក្សី ជាអាទិ៍)

<table>
<tr><td colspan="2">កំណត់ហេតុអំពីការសាកសួរ ☐ សាក្សី ☑ សាមីភាគី ☐ អ្នកធ្វើកោសល្យវិច័យ ☐<br>( កំណត់ហេតុនេះ ត្រូវជាផ្នែកមួយនៃកំណត់ហេតុដែលត្រូវធ្វើឡើង ក្នុងការទាញហេតុផលដោយផ្ទាល់មាត់ លើកទី ១ )</td></tr>
<tr><td>សញ្ញាណនៃរឿងក្តី</td><td>លេខ ១១៧ ចុះថ្ងៃទី ១២ មករា ២០០៧<br>រឿងក្តីទាមទារប្រាក់កំចី</td></tr>
<tr><td>កាលបរិច្ឆេទ</td><td>ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៧ វេលាម៉ោង ១០:០០ ព្រឹក</td></tr>
<tr><td>ឈ្មោះ</td><td>ខៀវ អាត</td></tr>
<tr><td>អាយុ</td><td>៤៦ ឆ្នាំ</td></tr>
<tr><td>អាសយដ្ឋាន</td><td>No. 12 ផ្លូវលេខ 00 សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ</td></tr>
<tr><td>សច្ចាប្រណិធាន<br>និងបញ្ហាផ្សេងៗ</td><td>☑ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ (ឬចៅក្រម) បានពន្យល់អំពីគោលគំនិតនៃការធ្វើសច្ចាប្រណិធាន និង ប្រកាសអំពី :<br>☐ ទណ្ឌកម្មដែលត្រូវដាក់ចំពោះការភូតភរកុហករបស់សាក្សី<br>☑ ទណ្ឌកម្មដែលត្រូវដាក់ចំពោះការភូតភរកុហករបស់សាមីភាគី<br>☐ ទណ្ឌកម្មដែលត្រូវដាក់ចំពោះការផ្តល់សក្ខីកម្មក្លែងក្លាយរបស់អ្នកធ្វើកោសល្យវិច័យ ។<br>បន្ទាប់មក ប្រធានក្រុមប្រឹក្សាជំនុំជម្រះបានបង្គាប់ឱ្យធ្វើសច្ចាប្រណិធាន ។<br>☐ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ (ឬចៅក្រម) បានប្រកាសរក្សានូវអានុភាពនៃសច្ចាប្រណិធានដែលបានធ្វើពីមុន ។<br>☐ បុគ្គលដែលនឹងត្រូវបានសាកសួរបន្ទាប់ :<br>☐ សាក្សី ☐ អ្នកធ្វើកោសល្យវិច័យ<br>☐ មិននៅក្នុងសាលសវនាការ<br>☐ នៅក្នុងសាលសវនាការ ដោយបានទទួលការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ (ឬចៅក្រម)<br>☐</td></tr>
<tr><td colspan="2">ចំណុចសំខាន់ៗនៃសេចក្តីថ្លែងការណ៍</td></tr>
<tr><td colspan="2">ដូចរៀបរាប់នៅក្នុងឯកសារឧបសម្ព័ន្ធ</td></tr>
<tr><td colspan="2">ចប់</td></tr>
<tr><td colspan="2"></td></tr>
<tr><td colspan="2"></td></tr>
</table>

( កំណត់ ១) សូមគូសសញ្ញា ✓ នៅក្នុងប្រអប់ ☐ ដែលសមស្រប ។

នៅក្នុងសេចក្តីថ្លែងការណ៍នេះ ត្រូវសរសេរ "ចប់" នៅបន្ទាត់បន្ទាប់ពី "បញ្ចប់សេចក្តីថ្លែងការណ៍" ។

(អត្ថាធិប្បាយអំពីនីតិវិធីធ្វើសច្ចាប្រណិធាន)

1 *ចៅក្រម* ឥឡូវនេះ ខ្ញុំសុំសួរដើមចោទអំពីរឿងក្ដីនេះមុន។

2 *ចៅក្រម* នៅថ្ងៃទី១ មិថុនា ២០០៦ នោះ ចុងចម្លើយ និងប្រពន្ធគាត់ បានអញ្ជើញទៅផ្ទះលោក មិនអីចឹង។

3 *ខៀវ អាត* បាទ លោកចៅក្រម។

4 *ចៅក្រម* ពេលនោះ ចុងចម្លើយបានអញ្ជើញទៅផ្ទះលោក មានការអ្វីដែរ ?

5 *ខៀវ អាត* ថ្ងៃនោះ ជាថ្ងៃដែលត្រូវសងប្រាក់កំចីនិងការប្រាក់ បូកសរុប ៩៦០០ដូល្លារ ហើយសុកបូរានោះ គេមកនិយាយប្រាប់ថា មិនអាចសងប្រាក់នោះបានទេ។

6 *ចៅក្រម* ពេលនោះ ចុងចម្លើយបានសងប្រាក់ មួយភាគនៃប្រាក់ ៩៦០០ដូល្លារនោះ គឺគាត់បានសង ៦០០០ដូល្លារ មែនឬទេ ?

7 *ខៀវ អាត* ទេ លោកចៅក្រម តែមួយដូល្លារ ក៏គ្មានបានទទួលដែរ។

8 *ចៅក្រម* តើចុងចម្លើយបាននិយាយអ្វីខ្លះ អំពីមូលហេតុដែលគាត់មិនអាចសងបានពេលនោះ ?

9 *ខៀវ អាត* គាត់និយាយថា "ឪពុកមានជម្ងឺ មហារីកនៅខែមីនា ហើយខែឧសភា បានទៅវះនៅបាងកក អស់ចំណាយច្រើន ហើយរកប្រាក់សងមិនបាន"។

10 *ចៅក្រម* ពេលឮអីចឹង តើលោកគិតឃើញយ៉ាងណាដែរ ?

11 *ខៀវ អាត* និយាយត្រង់ទៅ ខ្ញុំគិតថា ច្បាស់ជា គាត់សងហើយ តែដល់គាត់មិនសងអញ្ចឹងទៅ ខ្ញុំក៏ភ្ញាក់ដែរ ហើយខឹងគាត់យ៉ាងខ្លាំង។

12 *ចៅក្រម* ពេលនោះ តើលោកនិយាយយ៉ាងណាដែរ ?

13 *ខៀវ អាត* ខ្ញុំបាននិយាយថា "ខ្ញុំជឿឯង ហើយបានឱ្យឯងខ្ចីប្រាក់ ៨០០០ដូល្លារដល់ទៅពីរ ឆ្នាំ។ ចង់ឱ្យឯងសងទាំងប្រាក់ដើម ៨០០០ដូល្លារ ទាំងការប្រាក់ ១៦០០ដូល្លារ បូកសរុប ៩៦០០ដូល្លារ"។

14 *ចៅក្រម* ពេលនោះ តើចុងចម្លើយគេឆ្លើយយ៉ាងណាដែរ ?

15 *ខៀវ អាត* ពេលនោះ គាត់ឆ្លើយថា សូមចាំបន្តិចខ្ញុំនឹងបានប្រាក់មួយចំនួនធំ គាត់នឹងសង។

16 *ចៅក្រម* ពេលនោះ តើចុងចម្លើយបាននិយាយថា ពេលណាទើបគាត់អាចរកប្រាក់មកសងវិញដែរឬទេ ?

17 *ខៀវ អាត* ទេ គាត់មិនបាននិយាយថា ពេលណាទើបគាត់អាចសងបានទេ ដូច្នេះហើយ ខ្ញុំបានគិតឃើញថា គាត់ច្បាស់ជាគ្មានអ្វីជាទីរំពឹងនឹងរកបានទេ។

18 *ចៅក្រម* ពេលនោះ តើស្ថានភាពរបស់ចុងចម្លើយយ៉ាងណាដែរ ?

19 *ខៀវ អាត* ពេលនោះ គាត់និយាយហើយនិយាយទៀតថា "សូមទោស១" ឬ ក៏ "យើងជាមិត្តភក្តិនឹងគ្នា សូមចាំមួយរយៈពេល"។

20 *ចៅក្រម* ពេលនោះ តើប្រពន្ធចុងចម្លើយបាននិយាយអ្វីខ្លះដែរ ?

21 *ខៀវ អាត* គាត់ឱនក្បាលសូមទោសបណ្តើរ និយាយបណ្តើរថា "សូមទោស។ សូមចាំមួយរយៈពេលសិន"។

22 *ចៅក្រម* តើលោកយល់ឃើញយ៉ាងណាដែរ ពេលដែលឃើញ និងឮចុងចម្លើយ ឬប្រពន្ធគាត់និយាយដូច្នេះ ?

23 *ខៀវ អាត* ខ្ញុំមានចិត្តអាណិត្តគាត់បន្តិចដែរ។

24 *ចៅក្រម* តើលោកមានអារម្មណ៍អាណិត្តអាសូរគាត់ ហើយមានចិត្តចង់លើកលែងបំណុលឱ្យគាត់ដែរឬទេ ?

25 *ខៀវ អាត* ទេ មិនដែលមានចិត្តអីចឹងទាល់តែសោះ។

26 *ចៅក្រម* តើលោកមានចិត្តពន្យារពេលសងដែរឬទេ ?

27 *ខៀវ អាត* ខ្ញុំមានចិត្តអីចឹងខ្លះ១ដែរ។

28 *ចៅក្រម* ពេលនោះ តើលោកបានប្រាប់គាត់ថា លោកពន្យារពេលសងដែរឬទេ ?

29 *ខៀវ អាត* ទេ ខ្ញុំមិនបាននិយាយពន្យារទេ។

30 *ចៅក្រម* តើហេតុអ្វីបានជាមិននិយាយ .?

31 *ខៀវ អាត* ពេលនោះ ខ្ញុំកំពុងតែគិតតើត្រូវធ្វើយ៉ាងម្តេចដែរ ស្រាប់តែសុកបូរាបាននិយាយថាសុំខ្ចីប្រាក់ថែមទៀត។ ដល់ឮអញ្ចឹងទៅ ខ្ញុំក៏លែងនិយាយអំពីការពន្យារនោះទៅ ។

32 *ចៅក្រម* ពេលនោះ តើចុងចម្លើយបាននិយាយសុំខ្ចីថែមប៉ុន្មានទៀត ?

33 *ខៀវ អាត* ៤000ដូល្លារទៀត ។

34 *ចៅក្រម* តើគាត់បានពន្យល់មូលហេតុដែលគាត់ចង់ខ្ចី៤000ដូល្លារនោះដែរឬទេ ?

35 *ខៀវ អាត* គាត់និយាយថា "ត្រូវការចំណាយព្យាបាលជម្ងឺឪពុក ដូច្នេះសុំខ្ចីថែមទៀត"។

36 *ចៅក្រម* ពេលគាត់និយាយដូច្នេះ តើលោកបានឆ្លើយយ៉ាងណាដែរ ?

37 *ខៀវ អាត* ខ្ញុំបានឆ្លើយថា "អ្នកឯងមិនសងខ្ញុំផងខ្ញុំមិនអាចឱ្យខ្ចីថែមទៀតទេ។ ឥឡូវនេះត្រូវសង៩៦០០ដូល្លារមុនសិន ហើយបើចង់ខ្ចី ៤០០០ដូល្លារទៀត ចាំគិត ក្រោយ"។

38 *ចៅក្រម* ចុងចម្លើយនិយាយយ៉ាងណាដែរ ?

39 *ខៀវ អាត* គេឆ្លើយថា "ដឹងហើយ ចាំយើងគិត"ហើយគាត់ក៏ចេញទៅយ៉ាងប្រញាប់។

40 *ចៅក្រម* ខ្ញុំសូមបញ្ជាក់ម្តងទៀត ចុងចម្លើយមិនបានសង ៦០០០ដូល្លារ ហើយលោកក៏មិនបានលើកលែង៣៦០០ដូល្លារដែរ មិនអីចឹង ?

41 *ខៀវ អាត* ត្រឹមត្រូវហើយលោកចៅក្រម។

42 *ចៅក្រម* បន្ទាប់ពីចុងចម្លើយបានត្រឡប់ទៅផ្ទះគាត់វិញ នៅថ្ងៃទី១ មិថុនា នោះ តើលោកបានដាស់តឿនឱ្យគាត់សងដែរឬទេ ?

43 *ខៀវ អាត* បាទ បានដាស់តឿន។ ខ្ញុំបានទៅដល់ផ្ទះចុងចម្លើយផ្ទាល់តែម្តង ហើយដាស់តឿនឱ្យគាត់សងបំណុលនោះ។

44 *ចៅក្រម* តើពេលណាទៅ ?

45 *ខៀវ អាត* ថ្ងៃ ចាំមិនច្បាស់ទេ ។ ប្រហែលជាខ្ទង់ដើមខែកក្កដា ឆ្នាំ ២០០៦ មើលទៅ ។

46 *ចៅក្រម* ហេតុអ្វីបានជាមិនបានដាស់តឿនក្រោយថ្ងៃទី១ មិថុនា រហូតដល់ខែកក្កដាអីចឹង ?

47 *ខៀវ អាត* ដោយសារតែខ្ញុំរវល់រៀបចំការកូនស្រីច្បង នៅថ្ងៃទី ១៨មិថុនា ហើយម្យ៉ាងទៀតដោយសារតែជាមិត្ត ហើយខ្ញុំក៏ជឿទុកចិត្តគាត់ទៅ ។ ម្យ៉ាងទៀត ពេលដែលឪពុកគាត់មានជម្ងឺដូច្នេះ ទៅទារគាត់ដូចជ្រុលពេកដែរ។

48 *ចៅក្រម* ពេលទៅទារបំណុលនោះ តើចុងចម្លើយមានប្រតិកម្មយ៉ាងណាដែរ ?

49 *ខៀវ អាត* គាត់បាននិយាយថា ជម្ងឺឪពុកគាត់មិនទាន់ជានៅឡើយទេ ហើយត្រូវចំណាយលើការព្យាបាលទៀត សូមចាំមួយរយៈពេលសិន ហើយគាត់មិនបានសងខ្ញុំទេ។

50 *ចៅក្រម* ពីខែកក្កដាមក តើលោកបានដាស់តឿនឱ្យចុងចម្លើយសងបំណុលប៉ុន្មានដងដែរ ?

51 *ខៀវ អាត* ខ្ញុំចាំមិនច្បាស់ទេ តែប្រហែលមួយអាទិត្យម្តង ។

52 *ចៅក្រម* តើលោកបានដាស់តឿនដល់ពេលណាដែរ ?

53 *ខៀវ អាត* នៅខែធ្នូ ខ្ញុំបានទៅពិគ្រោះនឹងមេធាវី រីឯការដាស់តឿននោះ ខ្ញុំក៏បានធ្វើរហូតដល់ពេលទៅពិគ្រោះនោះ។

54 *ចៅក្រម* ខ្ញុំសូមបញ្ចប់ការសាកសួររបស់ខ្ញុំត្រឹមនេះហើយ។ សូមលោកតំណាងដើមចោទអញ្ជើញសួរបន្ត ?







55 *តំណាងដើមចោទ* បាទ លោកចៅក្រម ! ដូច្នេះ ក្នុងនាមជាតំណាងដើមចោទ ខ្ញុំសុំសួរដូចតទៅ ។ សូមលោកឆ្លើយឱ្យបានច្បាស់លាស់ ខ្លាំងៗ ដើម្បីឱ្យលោកចៅក្រមបានឮផង ។

*ខៀវ អាត* បាទ ។

56 *តំណាងដើមចោទ* នៅថ្ងៃទី ១ មិថុនា នោះ  តើលោកមានក្រដាស់សំរាប់សរសេរវិក័យបត្រឬទេ ?

57 *ខៀវ អាត* បាទ មាន ។

58 *តំណាងដើមចោទ* ហេតុអ្វីបានជាលោកមានក្រដាស់នោះដូច្នេះ ?

59 *ខៀវ អាត* នៅផ្ទះខ្ញុំ ៗបានបើកហាងលក់ខោអាវ ជាមួយគ្នា ដូច្នេះខ្ញុំមានក្រដាស់ត្រៀមសំរាប់សរសេរវិក័យបត្រ ។ ប្រសិនជា សុកបូរាគាត់សងប្រាក់ខ្ញុំមែន  ខ្ញុំច្បាស់ជាយកក្រដាស់នោះសរសេរវិក័យបត្រឱ្យគាត់ហើយ  ។

60 *តំណាងដើមចោទ* ពីមុនៗ រវាងលោក និងចុងចម្លើយ តើធ្លាប់បានឱ្យគាត់ខ្ចីប្រាក់ ឬធ្លាប់ខ្ចីប្រាក់ពីគាត់ដែរឬទេ ?

61 *ខៀវ អាត* បាទ ធ្លាប់ ។ ពេលមុន ខ្ញុំខ្វះប្រាក់ដើម្បីរៀបអាពាហ៍ពិពាហ៍  ។ តាមខ្ញុំចាំ ខ្ញុំបានខ្ចីពីសុកបូរា ១000ដូល្លារ ។

*តំណាងដើមចោទ* ពេលនោះ  លោកបានសងគេ មិនអីចឹង?

*ខៀវ អាត* បាទ ។

62 *តំណាងដើមចោទ* ពេលដែលលោកសងប្រាក់នោះទៅឱ្យគេវិញ តើលោកបានទទួលវិក័យបត្រ ដែរឬទេ ?

63 *ខៀវ អាត* បាទ  ពេលនោះ ខ្ញុំបានសុំឱ្យសុកបូរា ចេញវិក័យបត្រឱ្យខ្ញុំ  ។

64 *តំណាងដើមចោទ* ដើមចោទ  តើលោកធ្លាប់ឱ្យអ្នកផ្សេងក្រៅពីចុងចម្លើយនេះ ខ្ចីប្រាក់ដែរឬទេ ?

65 *ខៀវ អាត* បាន ធ្លាប់  ប្រហែល៧ ឬ ៨ ដងដែរ ។

66 *តំណាងដើមចោទ* តើដែលមិនចេញវិក័យបត្រឱ្យគេពេលគេសងវិញដែរឬទេ ?

67 *ខៀវ អាត* អត់ដែលទេ  ។

68 *តំណាងដើមចោទ* រហូតដល់ពេលថ្មីៗនេះ តើកូនបំណុល របស់លោកធ្លាប់សងតែមួយភាគ ឬក៏ធ្លាប់សងបណ្តាក់ដែរឬទេ?

69 *ខៀវ អាត* បាទ ដែល ។

70 *តំណាងដើមចោទ* ពេលដែលបានទទួលតែមួយភាគ តើលោកបានចេញវិក័យបត្រដោយបញ្ជាក់នូវទឹកប្រាក់មួយភាគនោះដែរឬទេ ?

71 *ខៀវ អាត* បាទ  ខ្ញុំចេញវិក័យបត្រអីចឹងរាល់ពេល ។

72 *តំណាងដើមចោទ* ហេតុអ្វីបានជាពេលទទួលតែមួយភាគក៏លោកចេញវិក័យបត្រដូច្នេះ ?

73 *ខៀវ អាត* គំនិតរបស់ខ្ញុំគឺ វិក័យបត្រជាឯកសារសំរាប់បញ្ជាក់ថា បានទទួលប្រាក់ប៉ុន្មាន ឱ្យច្បាស់លាស់ គ្មានពាក់ព័ន្ធនឹងការសងទាំងអស់ ឬសងមួយភាគទេ ។

74 *តំណាងដើមចោទ* ឥឡូវនេះ ខ្ញុំចង់សួរអំពីរឿងផ្សេង ដោយបង្ហាញភស្តុតាង X2 ដែលបានពិនិត្យរួច ហើយនោះ តើបានឬមិនបាន ?

75 *ចៅក្រម* បាទ សូមអញ្ជើញ ។

（ បង្ហាញភស្តុតាងជាឯកសារ X 2）

76 *តំណាងដើមចោទ* នេះគឺជារបាយការណ៍គណនីធនាគារកម្ពុជារបស់លោក។ មើលតាមរបាយការណ៍នេះ នៅថ្ងៃទី១៥ មិថុនា ឆ្នាំ ២០០៦ លោកបានដក១ម៉ឺនដូល្លារមិនអីចឹង។

77 *ខៀវ អាត* បាទ។

78 *តំណាងដើមចោទ* តើលោកដកធ្វើអ្វីដែរ ?

79 *ខៀវ អាត* ៥០០០ដូល្លារ សំរាប់រៀបអាពាហ៍ពិពាហ៍កូនស្រីច្បង ហើយ ៥០០០ ដូល្លារទៀត សំរាប់ទិញរថយន្តតូយ៉ូតាការ៉ីចាស់។

80 *តំណាងដើមចោទ* លោកចៅក្រម បន្ទាប់មកខ្ញុំចង់បង្ហាញភស្តុតាង X3 ដែលបានពិនិត្យហើយ ដើម្បីសួរសំនួរទៀត។

81 *ចៅក្រម* បាទ សូមអញ្ជើញ ។

（បង្ហាញភស្តុតាងជាឯកសារ X 3）

82 *តំណាងដើមចោទ* នេះគឺជាវិក័យបត្រពេលលោកទិញរថយន្តការ៉ី តម្លៃ ៥០០០ដូល្លារ ដូចដែលលោកបានថ្លែងការណ៍អំបាញ់មិញនេះ។

83 *ខៀវ អាត* បាទ មែន។

84 *តំណាងដើមចោទ* ពីខែកក្កដាមក លោកបានដាស់តឿនចុងចម្លើយថា "សង ៩៦០០ដូល្លារមក" មែនឬទេ ?

85 *ខៀវ អាត* មិនមែនទេ ។ ខ្ញុំគ្រាន់តែនិយាយថា "សងប្រាក់ខ្ញុំមក" តែប៉ុណ្ណោះ មិនបាននិយាយទឹកប្រាក់ទេ។ ក៏ប៉ុន្តែ ជាការធម្មតាទេ នេះមានន័យថា "សង៩៦០០ដូល្លារមក"។

86 *តំណាងដើមចោទ* ពាក្យថា "ប្រាក់" នេះ មានន័យថា "សង៩៦០០ដូល្លារ" មែនទេ ?

87 *ខៀវ អាត* បាទ។

88 *តំណាងដើមចោទ* សូមអរគុណ។

89 *តំណាងដើមចោទ* លោកចៅក្រម  ខ្ញុំតំណាងដើមចោទសូមបញ្ចប់សំនួរ ។

90 *ចៅក្រម* បាទ ។ បន្ទាប់មក សូមអញ្ជើញលោកតំណាងចុងចម្លើយសួរ ។

91 *តំណាងចុងចម្លើយ* បាទ សូមអរគុណលោកចៅក្រម ។ បន្ទាប់មក ខ្ញុំ តំណាងចុងចម្លើយសូមសួរ ។

92 *តំណាងចុងចម្លើយ* នៅថ្ងៃទី ១ មិថុនា លោកគិតឃើញថា ចុងចម្លើយនឹងសងប្រាក់៩៦០០ ដូល្លារ មិនអីចឹង ?

93 *ខៀវ អាត* បាទ អញ្ចឹងហើយ ។

94 *តំណាងចុងចម្លើយ* លោកបានរៀបអាពាហ៍ពាហ៍កូនស្រីច្បងរបស់លោក ដោយរំពឹងទៅលើប្រាក់ ៩៦០០ ដូល្លារដែលគេនឹងសងនោះមិនអញ្ចឹង ?

95 *ខៀវ អាត* បាទ   ....... ប្រហែលជាអញ្ចឹងក៏មិនដឹង ។

96 *តំណាងចុងចម្លើយ* អាពាហ៍ពិពាហ៍របស់កូនលោក តើលោកចំណាយអស់ប៉ុន្មានដែរ ?

97 *ខៀវ អាត* ចំណាយសរុប ខ្ញុំមិនចាំច្បាស់ដែរ តែខ្ញុំបានចេញ ៥០០០ដូល្លារ  ។

98 *តំណាងចុងចម្លើយ* តាមពិត លោកចាយអស់ច្រើនជាងហ្នឹងមែនឬទេ ?

99 *ខៀវ អាត* ចំណងដៃក៏យកមកចាយសំរាប់អាពាហ៍ពិពាហ៍នោះដែរ ដូច្នេះសរុបអស់ប៉ុន្មាន មិនដឹងដែរ  ។

100 *តំណាងចុងចម្លើយ* តើលោកមានគណនីធនាគារណាផ្សេងទៀត ក្រៅពីគណនីធនាគារដែលលោកបាន ដាក់មកតុលាការដែរឬទេ ?

101 *ខៀវ អាត* គណនីធនាគារឈ្មោះខ្ញុំ  ក្រៅពីនេះគ្មានទេ  ។

102 *តំណាងចុងចម្លើយ* ក្រែងលោកបានបញ្ចូលប្រាក់ ៦០០០ ដូល្លារ ដែលចុងចម្លើយបានសងនៅថ្ងៃទី១ មិថុនានោះ ទៅក្នុងគណនីផ្សេង ទេដឹង ?

103 *ខៀវ អាត* អំបាញ់មិញ ខ្ញុំបាននិយាយថា ក្រៅពីនេះ ខ្ញុំគ្មានគណនីផ្សេងទេ ។ ខ្ញុំមិនបានទទួល ៦០០០ដូល្លារនោះទាល់តែសោះ  ។

104 *តំណាងចុងចម្លើយ* បន្ទាប់មក  ខ្ញុំសូមសួរសំនួរផ្សេងវិញ ។លោកបានទិញរថយន្តតម្លៃ ៥០០០ដូល្លារ ឱ្យកូនប្រុសច្បងលោក មិនអីចឹង ?

105 *ខៀវ អាត* បាទ មែន  ។

106 *តំណាងចុងចម្លើយ* តើលោកបានគិតថាទិញរថយន្តនោះពេលណាដែរ ?

107 *ខៀវ អាត* ខ្ញុំចាំមិនច្បាស់ដែរ ក្រោយពេលបានកំណត់ថ្ងៃខែអាពាហ៍ពិពាហ៍កូនស្រីខ្ញុំ ដូច្នេះប្រហែលខែកុម្ភៈ ឆ្នាំ ២០០៦ ។

108 *តំណាងចុងចម្លើយ* ដូច្នេះ លោកបានរំពឹងថា នឹងបានទទួល៩៦០០ដូល្លារនៅថ្ងៃទី១ មិថុនា ដើម្បីទិញ

រថយន្តនោះ មិនអីចឹង ។

109 *ខៀវ អាត* បាទ ។

110 *តំណាងចុងចម្លើយ* តាមសំដីអំបាញ់មិញ លោកនិយាយថា លោកគ្មានគណនីធនាគារផ្សេង ក្រៅពីនេះទេ ហើយលោកបានដក ១០០០០ដូល្លារ នៅសល់តែ ៥៥០០ ដូល្លារប៉ុណ្ណោះ ហើយនេះគឺជាទ្រព្យសម្បត្តិទាំងអស់របស់លោក មែនឬទេ ?

111 *ខៀវ អាត* អីចឹងហើយ ។

112 *តំណាងចុងចម្លើយ* តើលោកមានចំណូលមួយខែប្រហែលប៉ុន្មានដែរ ?

113 *ខៀវ អាត* តាមខែដែរ គិតជាមធ្យមប្រហែល ១០០០ដូល្លារ ។

114 *តំណាងចុងចម្លើយ* ក្នុងស្ថានភាពដូចនេះ ហេតុអ្វីបានជាលោកមិនពន្យារពេលទិញរថយន្តនៅខែមិថុនានោះ ។

115 *ខៀវ អាត* ដោយសារតែខ្ញុំចង់ធ្វើយ៉ាងណាឱ្យមានសមភាពរវាងកូនប្រុសច្បង និង កូនស្រីច្បង បានជាខ្ញុំបានដកប្រាក់១ម៉ឺនដូល្លារទៅទិញតាមការគ្រោងទុកនោះ ទៅ ។

116 *តំណាងចុងចម្លើយ* គេមិនសងប្រាក់គ្រប់ចំនួន តើលោកខឹងឬទេ ?

117 *ខៀវ អាត* ខ្ញុំខឹងខ្លាំងណាស់ ។ គាត់មិនគោរពពាក្យសន្យារបស់គាត់ ។

118 *តំណាងចុងចម្លើយ* ចុងចម្លើយមានអាកប្បកិរិយាសូមទោសលោក ដោយសារនៅថ្ងៃទី១ មិថុនា គាត់មិនបានសងបំណុលទាំងអស់ មែនឬទេ ?

119 *ខៀវ អាត* បាទ ប្រហែលដែរ ។

120 *តំណាងចុងចម្លើយ* គេសងសងលោក ៦០០០ដូល្លារ តែដោយសារគេសងមិនបានគ្រប់ចំនួន ដូច្នេះហើយបានជាលោកខឹងគេ លោកមិនចេញវិក័យបត្រឱ្យគេ មិនអីចឹង ?

121 *ខៀវ អាត* លោកនិយាយជ្រុលហើយ នេះជារឿងដែលលោកប្រឌិត ។ ខ្ញុំបាននិយាយប៉ុន្មានដងហើយថា ខ្ញុំមិនដែលបានទទួលប្រាក់ ៦០០០ដូល្លារទេ ។

122 *តំណាងចុងចម្លើយ* លោកឆ្លៀតឱកាសដែលចុងចម្លើយមានចិត្តភ័យខ្លាចដោយសារគេមិន បានសងឱ្យគ្រប់ចំនួន មែនឬទេ ?

123 *ខៀវ អាត* ទេ មិនមែនជាដាច់ខាត ។

124 *តំណាងចុងចម្លើយ* នៅថ្ងៃទី១ មិថុនានោះ ដោយសារតែឮថា ឪពុកចុងចម្លើយមានជម្ងឺ លោកក៏មានចិត្តអាណិត្តអាសូរគេដែរ មែនឬទេ ?

125 *ខៀវ អាត* ខ្ញុំក៏ជាមនុស្សមានចិត្តធម៌ដែរ ។

126 *តំណាងចុងចម្លើយ* ដូច្នេះហើយ លោកបានលើកលែង៣៦០០ដូល្លារនោះ មិនអីចឹង ?

127 *ខៀវ អាត* ស៊ីទៅ ៣៦០០ដូល្លារនោះ ។ ខ្ញុំបាននិយាយហើយនិយាយទៀតថា ខ្ញុំមិនបានទទួល ៦០០០ដូល្លារទេ ។ សូមកុំសួរភ្លីផ្លើអីចឹងទៀត ។ (ខឹងឡើងក្រហមមុខ)

128 *ចៅក្រម* លោកតំណាងចុងចម្លើយ សូមឈប់សួរចំណុចហ្នឹងទៅ ។ បើមានសំនួរក្រៅពីនេះ សូមសួរបន្ត ។

129 *តំណាងចុងចម្លើយ* បាទ លោកចៅក្រម ។ ខ្ញុំយល់ហើយ ។

ខ្ញុំសូមបញ្ចប់សំនួរត្រឹមនេះហើយ ។

130 *ចៅក្រម* លោកតំណាងដើមចោទ តើលោកមានសំនួរបន្ថែមឬទេ ?

131 *តំណាងដើមចោទ* បាទ អត់ទេ លោកចៅក្រម ។

132 *ចៅក្រម* បើអត់ទេ ខ្ញុំសូមបញ្ចប់ការសាកសួរសាមីដើមចោទ ។ សូមអរគុណដើមចោទ ។

ចប់

ក្រឡាបញ្ជីតុលាការ



ស៊ុន សេយ៉ុង

ចៅក្រម



ប៉ែន បូរាវី

## ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិត ដែលខ្ញុំបានឃើញ បានឮ បានដឹង និង បានចាំផ្ទាល់ ។

បើខ្ញុំឆ្លើយមិនពិត ដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្ស អ្នកតា និង បារមី ដ៏សក្តិសិទ្ធិទាំងអស់ បរាមុខខ្ញុំ ឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និង ស្លាប់តែហោងយ៉ាង វេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួញឱ្យខ្ញុំមានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និង រស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូន កូនចៅ ញាតិផៅសណ្តាន ជារៀង រហូតគ្រប់ជាតិកុំបីអាក់ខានឡើយ ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការក្រុងភ្នំពេញ
រឿងក្តីលេខ ១១៧ ចុះថ្ងៃទី ១២ មករា ២០០៧
រឿងក្តីទាមទារប្រាក់កំចី
ដើមចោទ ខៀវ អាត
ចុងចម្លើយ សុក បូរា

ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០០៧
ជូនចំពោះលោកប្រធានតុលាការក្រុងភ្នំពេញ

មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទ

មាស ពេជ្រ

# ពាក្យស្នើសុំដាក់ភស្តុតាង

ការស្នើសុំឱ្យសាកសួរសាមីភាគី

1 ការបង្ហាញអំពីសាមីភាគីដើមចោទ
សាមីភាគីដើមចោទ ខៀវ អាត (សាកសួរចំបង ៣០នាទី)
អាស័យដ្ឋាន : No. 12 ផ្លូវលេខ 00 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

2 គោលគំនិតនៃការបញ្ជាក់ភស្តុតាង
ដើមចោទមិនបានទទួលនូវសំណងមួយភាគ ចំនួន៦០០០ដុល្លារទេ។
ដើមចោទមិនបានលើកលែងប្រាក់ដែលនៅសល់ទេ។

3 ចំណុចដែលសាកសួរ

- តើបានទទួលប្រាក់ ៦០០០ដុល្លារដែលចុងចម្លើយបានសង នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ ២០០៦ ឬទេ?
- នៅថ្ងៃដដែលនោះ តើដើមចោទបាននិយាយលើកលែងចោលនូវបំណុលចំពោះចុងចម្លើយដែរឬទេ ?
- នៅថ្ងៃដដែលនោះ ពេលទៅផ្ទះដើមចោទ តើចុងចម្លើយបាននិយាយរឿងអ្វីខ្លះដែរ ?
- ពេលដែលទទួលប្រាក់ តើដើមចោទធ្វើវិក័យបត្រឬទេ ?
- នៅខ្ទង់ខែមិថុនា ឆ្នាំ ២០០៦ តើដើមចោទបានទិញរថយន្តចាស់ ម៉ាកការីដែរឬទេ ?
- តើបានប្រាក់ពីណា ដើម្បីទិញរថយន្តនោះ ?
- ពីខែកក្កដា ឆ្នាំ ២០០៦ មក តើបានទាមទារឱ្យចុងចម្លើយសងដែរឬទេ ?
- ចំណុចផ្សេងទៀត ដែលពាក់ព័ន្ធ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការក្រុងភ្នំពេញ
រឿងក្តីលេខ ១១៧ ចុះថ្ងៃទី១២ មករា ២០០៧
រឿងក្តីទាមទារប្រាក់កំចី
ដើមចោទ ខៀវ អាត
ចុងចម្លើយ សុក បូរ៉ា

ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០០៧
ជូនចំពោះលោកប្រធានតុលាការក្រុងភ្នំពេញ

មេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយ

វីរៈ បុត្រ

# ពាក្យស្នើសុំដាក់ភស្តុតាង

ទី១ ការស្នើសុំឱ្យសាកសួរសាក្សី

1 ការបង្ហាញអំពីសាក្សី
សាក្សី គ្រឿង បុប្ផា (សាកសួរចំបង ១៥នាទី)
អាស័យដ្ឋាន : ផ្ទះលេខ ៣៤ សង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ រាជធានីភ្នំពេញ

2 គោលកំនិតនៃការបញ្ជាក់ភស្តុតាង
ចុងចម្លើយបានសងមួយភាគដែលមានចំនួន ៦០០០ដុល្លារ ។
ដើមចោទបានបង្ហាញឆន្ទៈលើកលែងចោលនូវប្រាក់ដែលនៅសល់ ចំពោះចុងចម្លើយ ។

3 ចំណុចដែលសាកសួរ

- តើនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ ២០០៦ សាក្សីបានទៅផ្ទះដើមចោទដែរឬទេ ? តើទៅជាមួយអ្នកណា ? តើទៅនោះដើម្បីធ្វើអ្វីដែរ ?
- តើចុងចម្លើយបានបង់ប្រាក់ ៦០០០ដុល្លារ ឱ្យដើមចោទដែរឬទេ ?
- តើចុងចម្លើយបានទទួលវិក័យបត្រពីដើមចោទឬទេ ? ហេតុអ្វីបានជាគាត់មិនបានទទួល ?
- ស្តីពីប្រាក់ដែលនៅសល់ ក្រៅពី៦០០០ដុល្លារនោះ តើដើមចោទបានបង្ហាញឆន្ទៈលើកលែងចោលដែរឬទេ?
- ពីខែកក្កដា ឆ្នាំ ២០០៦មក តើដើមចោទបានដាស់តឿនឱ្យសងដែរឬទេ ?

- ចំណុចផ្សេងទៀត ដែលពាក់ព័ន្ធ ។

ទី២ ការស្នើសុំឱ្យសាកសួរសាមីភាគី

1 ការបង្ហាញអំពីសាមីភាគីចុងចម្លើយ

សាមីភាគីចុងចម្លើយ សុក បូរា

អាស័យដ្ឋាន ដូចអាស័យដ្ឋានរបស់សាក្សីដែរ ។

2 គោលគំនិតនៃការបញ្ជាក់ភស្តុតាង

ចុងចម្លើយបានសងមួយភាគដែលមានចំនួន ៦000ដុល្លារ ។

ដើមចោទបានបង្ហាញឆន្ទៈលើកលែងចោលនូវប្រាក់ដែលនៅសល់ ចំពោះចុងចម្លើយ ។

3 ចំណុចសាកសួរ

- តើបានរកប្រាក់ ៨000ដុល្លារ និងការប្រាក់សម្រាប់សងឱ្យដើមចោទដែរឬទេ ?
- តើហេតុអ្វីបានជាមានការពិបាកនឹងសង ?
- តើបានធ្វើយ៉ាងណាដែរ ដើម្បីរកប្រាក់ដែលនៅសល់នោះ ?
- នៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២00៦ តើបានខ្ចីប្រាក់ ១000ដុល្លារ ពីសៅដារ៉ាដែរឬទេ ?
- នៅថ្ងៃដដែលនោះ តើចុងចម្លើយបានដកប្រាក់ ៥000ដុល្លារ ពីគណនីធនាគាររបស់ខ្លួនដែរឬទេ ?
- នៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២00៦ តើចុងចម្លើយបានបង់ប្រាក់ ៦000 ដុល្លារឱ្យដើមចោទដែរឬទ ?
- តើចុងចម្លើយបានទទួលវិក័យបត្រពីដើមចោទដែរឬទេ ? ហេតុអ្វីបានជាមិនបានទទួល ?
- តើដើមចោទបានបង្ហាញឆន្ទៈលើកលែងចោលនូវប្រាក់ដែលនៅសល់ ក្រៅពី ៦000ដុល្លារដែរឬទេ ?
- ពីខែកក្កដា ឆ្នាំ ២00៦ មក តើដើមចោទបានដាស់តឿនឱ្យសងដែរឬទេ ?
- ចំណុចផ្សេងទៀតដែលពាក់ព័ន្ធ ។

# លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

ថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧

អាសយដ្ឋាន : No. 12 ផ្លូវលេខ 00 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
អាណត្តិទាយក : ខៀវអាត អត្តសញ្ញាណបណ្ណលេខ : ១១១១

តាមរយៈលិខិតនេះ ខ្ញុំសូមតែងតាំងមេធាវីខាងក្រោមនេះ ឱ្យធ្វើជាតំណាងដោយអាណត្តិរបស់ខ្ញុំ ព្រមទាំងប្រគល់សិទ្ធិបំពេញកិច្ចការខាងក្រោម ដែលពាក់ព័ន្ធទៅនឹងរឿងក្តីនេះ :

មេធាវី : មាស ពេជ្រ
អាសយដ្ឋាន : ××, ○○, ភ្នំពេញ
ទូរស័ព្ទ : 000-000-000
ទូរសារ : 000-000-111

ការពិពណ៌នា

I. រឿងក្តី :

1. ភាគីម្ខាងទៀត
   ចុងចម្លើយ : សុក បូរា
2. តុលាការ :
   តុលាការក្រុងភ្នំពេញ
3. សញ្ញាណនៃរឿងក្តី :
   រឿងក្តីទាមទារឱ្យសងប្រាក់កំចីចំពោះចុងចម្លើយ ដោយដើមចោទ

II. ចំណុចដែលអាណត្តិ

1. សិទ្ធិអំណាចពេញលេញក្នុងការធ្វើសកម្មភាពតំណាងឱ្យដើមចោទ
2. ការដាក់ពាក្យបណ្តឹងតប
3. ការដកពាក្យបណ្តឹង ការផ្សះផ្សា ការបោះបង់ឬការទទួលស្គាល់ការទាមទារ ឬ ការចូលរួមអន្តរាគមន៍ក្នុង បណ្តឹង
4. ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ ឬ ពាក្យបណ្តឹងតវ៉ា ឬការដកពាក្យបណ្តឹងទាំងនេះ
5. ការតែងតាំងអនុតំណាង

# លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

ថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៧

អាសយដ្ឋាន : No. 34 ផ្លូវលេខ 00 សង្កាត់ផ្សារកណ្តាល ខ័ណ្ឌដូនពេញ ភ្នំពេញ
អាណត្តិទាយក : សុក បូរ៉ា អត្តសញ្ញាណបណ្ណលេខ : ២២២២

តាមរយៈលិខិតនេះ ខ្ញុំសូមតែងតាំងមេធាវីខាងក្រោមនេះ ឱ្យធ្វើជាតំណាងដោយអាណត្តិរបស់ខ្ញុំ ព្រមទាំងប្រគល់សិទ្ធិបំពេញកិច្ចការខាងក្រោម ដែលពាក់ព័ន្ធទៅនឹងរឿងក្តីនេះ :

មេធាវី : វីរៈ បុត្រ
អាសយដ្ឋាន : △△ , □□ , ភ្នំពេញ
ទូរស័ព្ទ : 000-000-222
ទូរសារ : 000-000-333

ការពិពណ៌នា

I. រឿងក្តី :

1. ភាគីម្ខាងទៀត
   ដើមចោទ : ខៀវ អាត
2. តុលាការ :
   តុលាការក្រុងភ្នំពេញ
3. សញ្ញាណនៃរឿងក្តី : លេខ ១១៧ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៧
   រឿងក្តីទាមទារប្រាក់កំចី

II. ចំណុចដែលអាណត្តិ

1. សិទ្ធិអំណាចពេញលេញក្នុងការធ្វើសកម្មភាពតំណាងឱ្យចុងចម្លើយ
2. ការដាក់ពាក្យបណ្តឹងតប
3. ការដកពាក្យបណ្តឹង ការផ្សះផ្សា ការបោះបង់ឬការទទួលស្គាល់ការទាមទារ ឬ ការចូលរួមអន្តរាគមន៍ក្នុងបណ្តឹង
4. ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ ឬ ពាក្យបណ្តឹងតវ៉ា ឬការដកពាក្យបណ្តឹងទាំងនេះ
5. ការតែងតាំងអនុតំណាង

ឧបសម្ព័ន្ធ

## (គំរូ)របាយការណ៍អំពីការបញ្ជូន

ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី

| |
|---|
| កាលបរិច្ឆេទធ្វើចេញ : ថ្ងៃទី ....១៤....... ខែ ..មករា........... ឆ្នាំ ..២០០៧......... |
| លេខសំណុំរឿង : ... លេខ ១១៧ .ថ្ងៃទី ១២ មករា ២០០៧ ......... |
| ឈ្មោះឯកសារដែលត្រូវបានបញ្ជូន : ឯកសារចម្លងនៃពាក្យបណ្ដឹង, លិខិតដាស់តឿនឱ្យដាក់ឯកសារចម្លើយ, ដីកាកោះហៅឱ្យបង្ហាញខ្លួននៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសំរាប់ការទាញហេតុផល (ថ្ងៃទី៩ កុម្ភៈ២០០៧ ម៉ោង ១០ព្រឹក), ឯកសារចម្លងនៃភស្តុតាង X1 |
| ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : ...."អ" ......... |
| អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : ..(រំលងចោល) ......... |
| ឈ្មោះជនដែលត្រូវទទួលការបញ្ជូន: .....សុក បូរា ......... |

**ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារផ្ទាល់ខ្លួន :**.........................................

ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន (កត្តាប្រៃសណីយ៍ អាជ្ញាសាលា ឬ ក្រឡាបញ្ជី)

| | |
|---|---|
| ទីកន្លែងដែលបានធ្វើការបញ្ជូន :...ផ្ទះលេខ ៣៤ សង្កាត់ផ្សារកណ្ដាល ខណ្ឌដូនពេញ រាជធានីភ្នំពេញ ......... | |
| កាលបរិច្ឆេទនៃការបញ្ជូន : ថ្ងៃទី ...១៧.....ខែ....មករា.... ឆ្នាំ ..២០០៧.......... ម៉ោង ...១២:០០.......... ព្រឹក/ (រសៀល) | |
| **វិធីដាក់ស្ដែងក្នុងការបញ្ជូន** | |
| ☐ ១ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ |
| | ☐ ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូន នូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអានអក្សរ |
| ☑ ២ | បានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅទីកន្លែងដែលត្រូវបញ្ជូននោះទេ |
| | ☐ អ្នកបម្រើ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ ☑ អ្នកនៅជាមួយ |
| | ឈ្មោះ : គ្រឿង បុប្ផា |
| ☐ ៣ | ឯកសារត្រូវបានទុកនៅឯទីកន្លែងដែលត្រូវធ្វើការបញ្ជូន ដោយហេតុថាបុគ្គលខាងក្រោមនេះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល |
| | ☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបម្រើ<br>☐ អ្នកនៅជាមួយ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ |
| | ឈ្មោះ : |
| ☑ **ខ្ញុំបានបញ្ជូនឯកសារតាមវិធីដូចខាងលើ** | |
| ☐ **ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះឡើយ** | |
| កាលបរិច្ឆេទធ្វើរបាយការណ៍ : ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៧ ......... | |
| ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍ : "អ" | |

**កំណត់សំគាល់សម្រាប់អ្នកប្រតិបត្តិការបញ្ជូន :**

១. ប្រសិនបើជនដែលទទួលឯកសារជាក់ស្តែង (ជនដែលត្រូវទទួលការបញ្ជូន ឬ បុគ្គលផ្សេង) មិនចេះសរសេរ ឬចុះហត្ថលេខា ឬមិនអាចផ្តិតម្រាមដៃបានទេ អ្នកប្រតិបត្តិការបញ្ជូនត្រូវចុះនិទ្ទេសពីការណ៍នោះនៅកន្លែង "**ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង**"

២. "ទីកន្លែងដែលបានធ្វើការបញ្ជូន" ត្រូវតែសរសេរឱ្យបានច្បាស់ៗ និងត្រឹមត្រូវ ។

៣. ប្រសិនបើការបញ្ជូនបានធ្វើឡើងតាមចំណុចលេខ ១ អ្នកបញ្ជូនត្រូវគូស ☑ ហើយប្រសិនបើបានពន្យល់ជូនពីខ្លឹមសារសង្ខេប ត្រូវគូស ☑ នៅក្នុងប្រអប់ដែរ។ ប្រសិនបើការបញ្ជូនបានធ្វើឡើងតាមចំណុចលេខ ២ ត្រូវគូស ☑ នៅក្នុងប្រអប់មុខលេខ ២ ហើយត្រូវបញ្ជាក់ពីបុគ្គលទទួលដោយគូស ☑ នៅក្នុងប្រអប់កំណត់បុគ្គលទទួល និងសរសេរឈ្មោះបុគ្គលដែលបានទទួលនោះផង ។ ប្រសិនបើការបញ្ជូនបានធ្វើឡើងតាមចំណុចលេខ ៣ អ្នកបញ្ជូន ត្រូវគូស ☑ នៅក្នុងប្រអប់មុខលេខ ៣ ហើយត្រូវបញ្ជាក់ពីបុគ្គលដែលមិនព្រមទទួលការបញ្ជូន ដោយគ្មានហេតុផលនេះ ដោយការគូស ☑នៅក្នុងប្រអប់កំណត់បុគ្គលដែលមិនព្រមទទួលការបញ្ជូន ហើយត្រូវសរសេរឈ្មោះបុគ្គលដែលមិនព្រមទទួលការបញ្ជូននោះចូលផង ។

៤. ក្នុងករណីដែលអ្នកធ្វើរបាយការណ៍មិនអាចធ្វើការបញ្ជូនឯកសារបានសម្រេច អ្នកធ្វើរបាយការណ៍នោះត្រូវគូស ☑ នៅក្នុងប្រអប់នៅពីមុខឃ្លាដែលសរសេរថា "**ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះ**" ។

**ឧបសម្ព័ន្ធទី២**

សាលក្រមរដ្ឋប្បវេណី

លេខៈ ៨២៩ ម ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**

-លេខ ៨២៩ "ម"

ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩។

-សំណុំរឿងរដ្ឋប្បវេណីលេខ១១៧៤

ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨។

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ៣០ នាទី រសៀល នៅសាលសវនាការទី៥។

## ចៅក្រមជំនុំជម្រះ

លោក **ភូយ សៅ** ចៅក្រម និងជាអនុប្រធានសាលាដំបូង

## ក្រឡាបញ្ជី

លោក **ផល សុភ័ក្ត្រ** ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

**ដើមចោទ** ៖ ឈ្មោះ ដ ភេទប្រុស ជនជាតិជប៉ុន កាន់លិខិតឆ្លងដែនលេខ មានអាសយដ្ឋានបច្ចុប្បន្ននៅ Kyoto Japan។ មេធាវីតំណាងដោយអាណត្តិលោកមេធាវី **រស់ មុនិន្ទ** និងលោកស្រីមេធាវី **អ ម្រិត** មានការិយាល័យក្រុមមេធាវី ខេមឡូ មានអាសយដ្ឋានអាគារស្កាស្ក័រលេខ២៧២ ជាន់ទី២ មហាវិថីព្រះសីហនុ កែងនឹងផ្លូវលេខ១៤៣ សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**ចុងចម្លើយ** ៖ ឈ្មោះ ច ភេទប្រុស សញ្ជាតិខ្មែរ កាន់លិខិតឆ្លងដែនលេខ មានអាសយដ្ឋាន រាជធានីភ្នំពេញ។ មេធាវីតំណាងដោយអាណត្តិលោកមេធាវី **អ៊ុំ ប៉ូលី** មានការិយាល័យក្រុមមេធាវី ជេស៊ី ដែលមានអាសយដ្ឋាននៅអាគារផ្សារទំនើបបាយ័នជិតទីស្តីការគណៈរដ្ឋមន្ត្រី អាគារលេខ ៣៣-៣៤ ជាន់ទី៤ បន្ទប់ ៤០២A ផ្លូវ លេខ១១៤ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

## អង្គហេតុ និងចំណុចវិវាទ

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ៖**

១. បង្គាប់ឲ្យចុងចម្លើយសងប្រាក់កម្ចីចំនួន ៥៣.៧៨២ ( ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបប្រាំពីរ) ដុល្លារអាមេរិក។

២. បង្គាប់ឲ្យចុងចម្លើយបង់ការប្រាក់ ៥ (ប្រាំ) ភាគរយ ក្នុងមួយឆ្នាំ តាមការកំណត់របស់ច្បាប់ ដោយគិតចាប់ពីថ្ងៃទី ០២ ខែមីនា ឆ្នាំ២០១៨ រហូតដល់ពេលសងរួច។

៣. បង្គាប់ឲ្យចុងចម្លើយបង់ថ្លៃការខូចខាត សេវាកម្មច្បាប់ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក។

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

## ខ. ដំណើររឿងក្ដីដោយសង្ខេប ៖

កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ចុងចម្លើយឈ្មោះ ថ បានចុះកិច្ចសន្យាខ្ចីប្រាក់ជាមួយដើមចោទចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លាអាមេរិក។ តាមរយៈកិច្ចសន្យាខ្ចីប្រាក់ដដែលឈ្មោះ ថ បានសន្យាថានឹងសងប្រាក់ដែលបានខ្ចីមកដើមចោទវិញ ត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១។ ការខ្ចីប្រាក់នេះធ្វើឡើងក្នុងគោលបំណងដើម្បីទទួលបានប្រាក់ជាទុនក្នុងការធ្វើកសិកម្ម ដែលនេះគឺជាអ្វីតែមួយគត់ដែលធ្វើឱ្យដើមចោទគិតថាឈ្មោះ ថ នឹងមានលទ្ធភាពសងប្រាក់កម្ចីខាងលើមកដើមចោទវិញ។ ប៉ុន្តែតាមរយៈការអនុវត្តកិច្ចសន្យានាពេលកន្លងមក ដើមចោទមានក្តីបារម្ភយ៉ាងខ្លាំង ចំពោះលទ្ធភាពនៃការអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនដែលក្តីបារម្ភនោះកើតឡើងដោយសារការមិនសហការល្អរបស់ឈ្មោះ ថ ដែលស្ដែងឡើងតាមរយៈភាពមិនដំណើការក្នុងការធ្វើកសិកម្ម ព្រមទាំងភាពលំបាកក្នុងការទំនាក់ទំនងផ្ទាល់ និងទទួលព័ត៌មានអំពីបច្ចុប្បន្នភាពនៃគម្រោងធ្វើកសិកម្ម ក៏ដូចជាការធ្លាក់ចុះនូវស្ថានភាពហិរញ្ញវត្ថុរបស់ចុងចម្លើយ។ ជាមួយនឹងក្តីបារម្ភនេះដែរ នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ ដើមចោទបានធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅឈ្មោះ ថ អំពីការជូនដំណឹងអំពីការរំលាយកិច្ចសន្យាខ្ចីប្រាក់ខាងលើ នោះ ក្នុងគោលបំណងទទួលបានមកវិញនូវការធ្វើបដិទានលើប្រាក់កម្ចីចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លាអាមេរិក ប៉ុន្តែមិនត្រូវបានឈ្មោះ ថ អនុវត្តតាមឡើយ។ ក្រោយមក ដើមចោទបានព្យាយាមជូនដំណឹងជាច្រើនសារទៀតទៅឈ្មោះ ថ ប៉ុន្តែឈ្មោះ ថ បដិសេធមិនទទួលយកការជូនដំណឹងទាំងនោះ ហើយក៏មិនព្រមសងទឹកប្រាក់កម្ចីទាំងនោះទោះបីជាកិច្ចសន្យាខ្ចីប្រាក់ខាងលើត្រូវបានរំលាយហើយក៏ដោយ។

## គ. ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទ ៖

១. តាមរយៈកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ឈ្មោះ ថ បានខ្ចីប្រាក់ចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លាអាមេរិក ពីឈ្មោះ ង ។ តាមរយៈកិច្ចសន្យាខ្ចីប្រាក់ដដែលឈ្មោះ ថ បានសន្យាថានឹងសងប្រាក់ដែលបានខ្ចី មកកូនក្តីរបស់យើងខ្ញុំវិញត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១។ សូមបញ្ជាក់ផងដែរថាការខ្ចីប្រាក់ របស់ឈ្មោះ ថ ធ្វើឡើងក្នុងគោលបំណងដើម្បីទទួលបានប្រាក់ជាទុនក្នុងការធ្វើកសិកម្ម ដែលនេះគឺជាអ្វីតែមួយគត់ដែលធ្វើឱ្យកូនក្តីយើងខ្ញុំជឿជាក់ថាឈ្មោះ ថ នឹងមានលទ្ធភាពសងប្រាក់កម្ចីខាងលើមកវិញ។

២. ប៉ុន្តែតាមរយៈការអនុវត្តកិច្ចសន្យានាពេលកន្លងមក កូនក្តីយើងខ្ញុំមានក្តីបារម្ភយ៉ាងខ្លាំង ចំពោះលទ្ធភាពនៃការអនុវត្តសិទ្ធិលើបំណុលរបស់គាត់ ដែលក្តីបារម្ភនោះកើតឡើងដោយសារការមិនសហការល្អរបស់លោក ថ ដែលស្ដែងឡើងតាមរយៈភាពមិនដំណើការក្នុងការធ្វើកសិកម្ម ព្រមទាំងភាពលំបាកក្នុងការទំនាក់ទំនងផ្ទាល់ និងទទួលព័ត៌មានអំពីបច្ចុប្បន្នភាពនៃគម្រោងធ្វើកសិកម្ម ក៏ដូចជាការធ្លាក់ចុះនូវស្ថានភាពហិរញ្ញវត្ថុរបស់ចុងចម្លើយរូបនេះផងដែរ។

៣. ជាមួយនឹងក្តីបារម្ភនេះកាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ យើងខ្ញុំបានធ្វើការជូនដំណឹងជាលាយ លក្ខណ៍អក្សរទៅលោក ថ អំពីការជូនដំណឹងអំពីការរំលាយកិច្ចសន្យាខ្ចីប្រាក់ខាងលើ នោះ ក្នុងគោលបំណងទទួលបានមកវិញនូវការធ្វើបដិទានលើប្រាក់កម្ចីចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបី ពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លារអាមេរិក ប៉ុន្តែមិនត្រូវបានលោក ថ អនុវត្តតាមឡើយ។

៤. ក្រោយមក យើងបានព្យាយាមជូនដំណឹងជាច្រើនសារទៀតទៅលោក ច ប៉ុន្តែលោក ច បដិសេធមិនទទួលយកការជូនដំណឹងទាំងនោះ ហើយក៏មិនព្រមសងទឹកប្រាក់កម្ចីទាំងនោះ ទោះបីជាកិច្ចសន្យាខ្ចីប្រាក់ខាងលើត្រូវបានរំលាយហើយក៏ដោយ។

## ឃ. ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយ ៖

១. ចំពោះចំណុចទី១ សូមធ្វើការច្រានចោលការទាមទាររបស់ដើមចោទ និងប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

២. ការទទួលស្គាល់ ឬមិនទទួលស្គាល់អង្គហេតុដែលអះអាងដោយដើមចោទ

ទី១. អង្គហេតុស្តីពីការចុះកិច្ចសន្យាខ្ចីប្រាក់ ត្រង់ចំណុចរ៉ូម៉ាំង ២.១ នៃពាក្យបណ្តឹងរបស់ដើមចោទ ចុងចម្លើយមិនទទួលស្គាល់។

ទី២. អង្គហេតុស្តីពីការអនុវត្តសិទ្ធិលើបំណុល ត្រង់រ៉ូម៉ាំង ២.២ នៃពាក្យបណ្តឹងរបស់ដើមចោទ ចុងចម្លើយមិនទទួលស្គាល់។

ទី៣. អង្គហេតុស្តីពីការជូនដំណឹងអំពីការរំលាយកិច្ចសន្យា ចុងចម្លើយមិនបានដឹងនោះទេ។

ទី៤. ការជូនដំណឹងជាបន្តបន្ទាប់ត្រង់រ៉ូម៉ាំង ២.៤ ចុងចម្លើយមិនបានដឹងនោះទេ។

៣. ការពន្យល់អំពីទំនាក់ទំនងនៃអង្គហេតុ ដើមចោទបានអះអាងថា ចុងចម្លើយបានខ្ចីប្រាក់ចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លាអាមេរិក ដោយកំណត់ពេលសងនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយគ្មានការប្រាក់ ការទាមទារនេះមិនទាន់មានមូលដ្ឋានតាមផ្លូវច្បាប់នោះទេ ដោយហេតុថា ប្រសិនបើអង្គហេតុនេះ ជាអង្គហេតុខ្ចីប្រាក់ គប្បីតាក់តែងជាលិខិតខ្ចីប្រាក់ ដោយកំណត់អំពីការប្រាក់ គោលបំណងនៃការខ្ចី រយៈពេលនៃការខ្ចី ហើយមានលិខិតប្រគល់ទទួលប្រាក់កម្ចីនោះផងដែរ។ មួយវិញទៀតប្រសិនបើអង្គហេតុនោះ ជាអង្គហេតុខ្ចីប្រាក់មែន ក៏ប្រាក់កម្ចីនោះមិនទាន់ដល់ការកំណត់សងផងដែរ ផ្អែកតាមមាត្រា ៥៧៨ និងមាត្រា ៥៩១ នៃក្រមរដ្ឋប្បវេណី

សំណូមពរ ចុងចម្លើយស្នើសុំបញ្ចូលសំណុំរឿងរដ្ឋប្បវេណីលេខ ១១៧៣ និងលេខ ១១៧៤ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ជាសំណុំរឿងតែមួយ ដោយហេតុថា សំណុំរឿងទាំងពីរខាងលើនេះ គឺមានអង្គហេតុនៃការទាមទារតែមួយ ហើយក៏កើតឡើងនូវការបរិច្ឆេតតែមួយផងដែរ។ មួយវិញទៀតខ្លឹមសារនៃការទាមទារ គឺជាការទាមទារប្រាក់ដូចគ្នា ដោយមានចុងចម្លើយតែម្នាក់គត់។ លើសពីនេះទៅទៀត សំណុំរឿងទាំងពីរខាងលើនេះ មានអង្គហេតុ ភាគីពាក់ព័ន្ធ និងខ្លឹមសារនៃការទាមទារ ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ផ្អែកតាមមាត្រា ៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ង. សេចក្តីថ្លែងការណ៍តបរបស់មេធាវីតំណាងឲ្យអាណត្តិរបស់ដើមចោទ ៖

១. ទាក់ទងទៅនឹងខ្លឹមសារនៃសាលក្រម នាងខ្ញុំសូមធ្វើការបដិសេធ នូវការលើកឡើងរបស់មេធាវី តំណាងឲ្យចុងចម្លើយ និងសូមរក្សានូវខ្លឹមសារនៃសាលក្រម ដែលបានទាមដូចមានក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ ដដែល។

២. ទាក់ទងទៅនឹងអង្គហេតុ ដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុដែលបញ្ជាក់នៃការទាមទារ

២.១. ពាក់ព័ន្ធទៅនិងការលើកឡើងរបស់មេធាវីចុងចម្លើយ មិនទទួលស្គាល់កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ រវាងលោក ច ពីលោក ង ជាការលើកឡើងដែលផ្ទុយពីការពិត ដោយហេតុថា ពិតជាមានការខ្ចីប្រាក់ចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លាអាមេរិក ដោយឈ្មោះ ច ពីលោក ង ពិតប្រាកដមែន។ ទោះបីជាទំរង់នៃកិច្ចសន្យាខ្ចីប្រាក់នេះ ធ្វើឡើងជាភាសាបរទេស និងពុំមានចែងលំអិតអំពីចំណុចផ្សេងៗ ដូចកិច្ចសន្យាខ្ចីប្រាក់ទូទៅក្តី ក៏ប៉ុន្តែគូភាគីទាំងពីរបានបង្ហាញឆន្ទៈច្បាស់លាស់ក្នុងការចុះកិច្ចសន្យាខ្ចីប្រាក់ជាមួយគ្នា។ នៅក្នុងកិច្ចសន្យា

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

ប្រាក់នេះ បានកំណត់អំពីប្រាក់ដើមដែលបានខ្ចី និងរយៈពេលនៃការសងប្រាក់ ការបរិច្ឆេតនៃការចុះកិច្ចសន្យា អត្តសញ្ញាណរបស់ភូភាគី ហើយនិងមានការផ្តិតស្នាមមេដៃ និងចុះហត្ថលេខា ដោយគូភាគីផងដែរ យោងតាមមាត្រា៣១១ កិច្ចសន្យា គឺកើតចេញពីឆន្ទៈព្រមគ្នារបស់គូភាគី ក្នុងការបង្កើត កែប្រែ ឬរំលតកាតព្វកិច្ច។ ហេតុដូច្នេះកិច្ចសន្យាខ្ចីប្រាក់ I OWE YOU NOTE ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ គឺពិតជាកិច្ចសន្យាដែលកើតចេញពីឆន្ទៈភូភាគី និងគ្មានការក្លែងបន្លំឡើយ។

២.២. ពាក់ព័ន្ធទៅនិងការអនុវត្តសិទ្ធិលើបំណុល នាងខ្ញុំសូមធ្វើការបដិសេធ ចំពោះកាលើកឡើងរបស់មេធាវីតំណាងឱ្យចុងចម្លើយ ពីព្រោះការមិនទទួលស្គាល់អំពីសិទ្ធិលើបំណុល គឺជាការគេចវេះពីការអនុវត្តកាតព្វកិច្ចរបស់កូនបំណុលតែប៉ុណ្ណោះ។

២.៣. ពាក់ព័ន្ធទៅនិងការមិនបានទទួលការជូនដំណឹង នាងខ្ញុំសូមធ្វើការបដិសេធ ចំពោះកាលើកឡើងរបស់មេធាវីតំណាងឱ្យចុងចម្លើយ ដោយហេតុថា លិខិតជូនដំណឹងថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ អំពីការរំលាយកិច្ចសន្យាខ្ចីប្រាក់ទាំងពីរ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ជាមួយលោក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ជាមួយលោក ន គឺបានផ្ញើជូនទៅចុងចម្លើយហើយ ចុងចម្លើយបានចុះហត្ថលេខាទទួល នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៨ ម្យ៉ាងទៀត ទាក់ទងទៅនឹងការជូនដំណឹងជាបន្តបន្ទាប់ទៀត ចុងចម្លើយសុទ្ធតែបានដឹង ហើយចុងចម្លើយបានព្យាយាមទាក់ទងតាមទូរស័ព្ទមក មេធាវីតំណាងដើមបណ្តឹងផងដែរ នេះជាហេតុមួយដែលសបញ្ជាក់ឱ្យឃើញថា ចុងចម្លើយបានដឹងអំពីការជូនដំណឹងស្តីពីការរំលាយកិច្ចសន្យាខ្ចីប្រាក់ ហើយអនុភាពនៃការរំលាយកិច្ចសន្យា ក៏បានកើតឡើងតាំងពីពេលនោះរួចមកហើយដែរ។ យើងអាចសន្និដ្ឋានបានថា ចុងចម្លើយមានចេតនាគេចវេះក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ទោះជាខ្លួនធ្លាប់ទទួលស្គាល់ថា ខ្លួនបានទទួលប្រាក់គ្រប់ចំនួន ដែលខ្លួនបានខ្ចីពីដើមបណ្តឹងពិតមែនក៏ដោយ។

ពាក់ព័ន្ធទៅនឹងការសំណើរសុំបញ្ចូលសំណុំរឿងរដ្ឋប្បវេណីលេខ ១១៧៣ និងលេខ ១១៧៤ ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៨ ជាសំណុំរឿងតែមួយនោះ នាងខ្ញុំមិនមានការជំទាស់នោះទេ។ សំណូមពរស្នើសុំឱ្យតុលាការចេញសាលក្រមដូចការទាមទារ។

## ច. ចំណុចវិវាទៈ

១. តើកិច្ចសន្យាខ្ចីប្រាក់នេះ មានអត្ថិភាព និងសុពលភាពដែរឬទេ?

២. តើមានការជូនដំណឹង និងទំនាក់ទំនងជាបន្តបន្ទាប់ ពីលិខិតជូនដំណឹងស្តីពីការរំលាយកិច្ចសន្យាដែរឬទេ?

## សំអាងហេតុ

១. តុលាការពិនិត្យឃើញថា សំណុំរឿងរដ្ឋប្បវេណីលេខ ១១៧៤ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។ ដូច្នេះតុលាការអាចលើកយករឿងនេះមកចាត់ការតាមនីតិវិធីបាន ស្របតាមមាត្រា៧ មាត្រា៨ មាត្រា៩ និងមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២. ឃើញថាអ្នកតំណាងដោយអាណត្តិរបស់ដើមចោទ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ បានអះអាង និងស្នើសុំឱ្យតុលាការចេញសាលក្រមដូចមានក្នុងខ្លឹមសារនៃពាក្យបណ្តឹងដូចខាងក្រោម ៖

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

១. បង្គាប់ឱ្យចុងចម្លើយសងប្រាក់កម្ចីចំនួន ៥៣.៧៨២ ( ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបប្រាំពីរ) ដុល្លារអាមេរិក។

២. បង្គាប់ឱ្យចុងចម្លើយបង់ការប្រាក់ ៥ (ប្រាំ) ភាគរយ ក្នុងមួយឆ្នាំ តាមការកំណត់របស់ច្បាប់ ដោយគិតចាត់ពីថ្ងៃទី ០២ ខែមីនា ឆ្នាំ២០១៨ រហូតដល់ពេលសងរួច។

៣. បង្គាប់ឱ្យចុងចម្លើយបង់ថ្លៃការខូចខាត សេវាកម្មច្បាប់ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក។

អង្គហេតុដែលជាមូលហេតុនៃការទាមទារ តាមរយៈកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ឈ្មោះ ច បានខ្ចីប្រាក់ចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លាអាមេរិក ពីឈ្មោះ ង ។ តាមរយៈកិច្ចសន្យាខ្ចីប្រាក់ដដែលឈ្មោះ ច បានសន្យាថានឹងសងប្រាក់ដែលបានខ្ចីមកកូនក្តីរបស់ខ្លួនវិញត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១។ ការខ្ចីប្រាក់របស់ឈ្មោះ ច ធ្វើឡើងក្នុងគោលបំណងដើម្បីទទួលបានប្រាក់ជាទុនក្នុងការធ្វើកសិកម្ម ដែលនេះគឺជាអ្វីតែមួយគត់ដែលធ្វើឱ្យកូនក្តីខ្លួនជឿជាក់ថាឈ្មោះ ច នឹងមានលទ្ធភាពសងប្រាក់កម្ចីខាងលើមកវិញ។

ប៉ុន្តែតាមរយៈការអនុវត្តកិច្ចសន្យានាពេលកន្លងមក កូនក្តីខ្លួនមានក្តីបារម្ភយ៉ាងខ្លាំង ចំពោះលទ្ធភាពនៃការអនុវត្តសិទ្ធិលើបំណុលរបស់គាត់ ដែលក្តីបារម្ភនោះកើតឡើងដោយសារការមិនសហការល្អរបស់លោក ច ដែលស្តែងឡើងតាមរយៈភាពមិនដំណើការក្នុងការធ្វើកសិកម្ម ព្រមទាំងភាពលំបាកក្នុងការទំនាក់ទំនងផ្តល់ និងទទួលព័ត៌មានអំពីបច្ចុប្បន្នភាពនៃគម្រោងធ្វើកសិកម្ម ក៏ដូចជាការធ្លាក់ចុះនូវស្ថានភាពហិរញ្ញវត្ថុរបស់ចុងចម្លើយផងដែរ។

ជាមួយនឹងក្តីបារម្ភនេះ កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ ខ្លួនបានធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅលោក ច អំពីការជូនដំណឹងអំពីការរំលាយកិច្ចសន្យាខ្ចីប្រាក់ខាងលើនោះ ក្នុងគោលបំណងទទួលបានមកវិញនូវការធ្វើបដិទានលើប្រាក់កម្ចីចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លារអាមេរិក ប៉ុន្តែមិនត្រូវបានលោក ច អនុវត្តតាមឡើយ។

ក្រោយមកខ្លួនបានព្យាយាមជូនដំណឹងជាច្រើនសារទៀតទៅលោក ច ប៉ុន្តែលោក ច បដិសេធមិនទទួលយកការជូនដំណឹងទាំងនោះ ហើយក៏មិនព្រមសងទឹកប្រាក់កម្ចីទាំងនោះ ទោះបីជាកិច្ចសន្យាខ្ចីប្រាក់ខាងលើត្រូវបានរំលាយហើយក៏ដោយ។

ពាក់ព័ន្ធទៅនិងការលើកឡើងរបស់មេធាវីចុងចម្លើយ មិនទទួលស្គាល់កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ រវាងលោក ច ពីលោក ង ជាការលើកឡើងដែលផ្ទុយពីការពិត ដោយហេតុថាពិតជាមានការខ្ចីប្រាក់ចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លាអាមេរិក ដោយឈ្មោះ ច ពីលោក ង ពិតប្រាកដមែន។ ទោះបីជាទំរង់នៃកិច្ចសន្យាខ្ចីប្រាក់នេះ ធ្វើឡើងជាភាសាបរទេស និងពុំមានចែង លំអិតអំពីចំណុចផ្សេងៗ ដូចកិច្ចសន្យាខ្ចីប្រាក់ទូទៅក្តី ក៏ប៉ុន្តែគូភាគីទាំងពីរបានបង្ហាញឆន្ទៈច្បាស់លាស់ក្នុងការចុះកិច្ចសន្យាខ្ចីប្រាក់ជាមួយគ្នា។ នៅក្នុងកិច្ចសន្យាខ្ចីប្រាក់នេះ បានកំណត់អំពីប្រាក់ដើមដែលបានខ្ចី និងរយៈពេលនៃការសងប្រាក់ ការបរិច្ឆេតនៃការចុះកិច្ចសន្យាអត្តសញ្ញាណរបស់ភូភាគី ហើយនិងមានការផ្តិតស្នាមមេដៃ និងចុះហត្ថលេខាដោយគូភាគី ផងដែរ យោងតាមមាត្រា៣១១ កិច្ចសន្យា គឺកើតចេញពីឆន្ទៈព្រមគ្នារបស់គូភាគី ក្នុងការបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច។ ហេតុដូច្នេះកិច្ចសន្យាខ្ចីប្រាក់ I OWE YOU NOTE ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ គឺពិតជាកិច្ចសន្យាដែលកើតចេញពីឆន្ទៈ ភូភាគី និងគ្មានការក្លែងបន្លំឡើយ។

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

ពាក់ព័ន្ធទៅនឹងការអនុវត្តសិទ្ធិលើបំណុល ខ្លួនសូមធ្វើការបដិសេធ ចំពោះកាលើកឡើងរបស់មេធាវី តំណាងឲ្យចុងចម្លើយ ពីព្រោះការមិនទទួលស្គាល់អំពីសិទ្ធិលើបំណុល គឺជាការគេចវេះពីការអនុវត្តកាតព្វកិច្ចរបស់កូនបំណុលតែប៉ុណ្ណោះ។

ពាក់ព័ន្ធទៅនឹងការមិនបានទទួលការជូនដំណឹង ខ្លួនសូមធ្វើការបដិសេធ ចំពោះកាលើកឡើងរបស់មេធាវីតំណាងឲ្យចុងចម្លើយ ដោយហេតុថា លិខិតជូនដំណឹងថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ អំពីការរំលាយកិច្ចសន្យាខ្ចីប្រាក់ទាំងពីរ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ជាមួយលោក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ជាមួយលោក គឺបានផ្ញើជូនទៅចុងចម្លើយហើយ ចុងចម្លើយបានចុះហត្ថលេខាទទួល នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៨ ម្យ៉ាងទៀតទាក់ទងទៅនឹងការជូនដំណឹងជាបន្តបន្ទាប់ទៀត ចុងចម្លើយសុទ្ធតែបានដឹង ហើយចុងចម្លើយបានព្យាយាមទាក់ទងតាមទូរស័ព្ទមកមេធាវីតំណាងដើមបណ្តឹងផងដែរ នេះជាហេតុមួយដែលសបញ្ជាក់ឲ្យឃើញថា ចុងចម្លើយបានដឹងអំពីការជូនដំណឹងស្តីពីការរំលាយកិច្ចសន្យាខ្ចីប្រាក់ ហើយអនុភាពនៃការរំលាយកិច្ចសន្យា ក៏បានកើតឡើងតាំងពីពេលនោះរួចមកហើយដែរ។ ខ្លួនអាចសន្និដ្ឋានបានថា ចុងចម្លើយមានចេតនាគេចវេះក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ទោះជាខ្លួនធ្លាប់ទទួលស្គាល់ថាខ្លួនបានទទួលប្រាក់គ្រប់ចំនួន ដែលខ្លួនបានខ្ចីពីដើមបណ្តឹងពិតមែនក៏ដោយ។

៣. ឃើញថាអ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ បានអះអាងថា ៖

១. ចំពោះចំណុចទី១ សូមធ្វើការច្រានចោលការទាមទាររបស់ដើមចោទ និងប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

២. ការទទួលស្គាល់ ឬមិនទទួលស្គាល់អង្គហេតុដែលអះអាងដោយដើមចោទ

ទី១. អង្គហេតុស្តីពីការចុះកិច្ចសន្យាខ្ចីប្រាក់ ត្រង់ចំណុចវ៉ូម៉ាំង ២.១ នៃពាក្យបណ្តឹងរបស់ដើមចោទ ចុងចម្លើយមិនទទួលស្គាល់។

ទី២. អង្គហេតុស្តីពីការអនុវត្តសិទ្ធិលើបំណុល ត្រង់វ៉ូម៉ាំង ២.២ នៃពាក្យបណ្តឹងរបស់ដើមចោទ ចុងចម្លើយមិនទទួលស្គាល់។

ទី៣. អង្គហេតុស្តីពីការជូនដំណឹងអំពីការរំលាយកិច្ចសន្យា ចុងចម្លើយមិនបានដឹងនោះទេ។

ទី៤. ការជូនដំណឹងជាបន្តន្ទាប់ត្រង់វ៉ូម៉ាំង ២.៤ ចុងចម្លើយមិនបានដឹងនោះទេ។

៣. ការពន្យល់អំពីទំនាក់ទំនងនៃអង្គហេតុ ដើមចោទបានអះអាងថា ចុងចម្លើយបានខ្ចីប្រាក់ចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លាអាមេរិក ដោយកំណត់ពេលសងនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយគ្មានការប្រាក់ ការទាមទារនេះមិនទាន់មានមូលដ្ឋានតាមផ្លូវច្បាប់នោះទេ ដោយហេតុថា ប្រសិនបើអង្គហេតុនេះ ជាអង្គហេតុខ្ចីប្រាក់ គប្បីតាក់តែងជាលិខិតខ្ចីប្រាក់ ដោយកំណត់អំពីការប្រាក់ គោលបំណងនៃការខ្ចី រយៈពេលនៃការខ្ចី ហើយមានលិខិតប្រគល់ទទួលប្រាក់កម្ចីនោះផងដែរ។ មួយវិញទៀតប្រសិនបើអង្គហេតុនោះ ជាអង្គហេតុខ្ចីប្រាក់មែន ក៏ប្រាក់កម្ចីនោះមិនទាន់ដល់ការកំណត់សងផងដែរ ផ្អែកតាមមាត្រា ៥៧៨ និងមាត្រា ៥៩១ នៃក្រមរដ្ឋប្បវេណី។

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

៤. ឃើញថា ភាគីដើមចោទបានអះអាងថា ចុងចម្លើយពិតជាបានខ្ចីប្រាក់ខ្លួនចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយ ប៉ែតសិបពីរ) ដុល្លារអាមេរិក នោះ តុលាការបានរកឃើញថា ចុងចម្លើយពិតជាបានខ្ចីប្រាក់ពីដើមចោទពិតប្រាកដមែន ពីព្រោះថា ដើមចោទ និងចុងចម្លើយ បានធ្វើកិច្ចសន្យាខ្ចីប្រាក់ និងទទួលប្រាក់ ដូចមាននៅក្នុងលិខិតមួយដែលបាន សរសេរថា " I OWE YOU NOTE " ។ នៅក្នុងលិខិតនេះមានខ្លឹមសារគ្រប់គ្រាន់ ដែលបញ្ជាក់ថា អ្នកឱ្យខ្ចីប្រាក់ (Lender) ឈ្មោះ ជ និងអ្នកខ្ចីប្រាក់ (Borrower) ឈ្មោះ ច ហើយដែលចុងចម្លើយបាន ទទួលប្រាក់កម្ចីចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយ ប៉ែតសិបពីរ) ដុល្លារអាមេរិក។ ដូចនេះ តុលាការយល់ ឃើញថា ទម្រង់លិខិត " I OWE YOU NOTE " ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ពិតជាលិខិតកិច្ចសន្យាខ្ចីប្រាក់ ដែលគូភាគី ទាំងពីរ មានឆន្ទៈ ពិតប្រាកដ ដោយដើមចោទឱ្យខ្ចីប្រាក់ ហើយចុងចម្លើយទទួលយកប្រាក់កម្ចី។

៥. ឃើញថា អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានធ្វើសេចក្តីអះអាងថា ទោះបីជាចុងចម្លើយបានខ្ចីប្រាក់ពី ដើមចោទក៏ដោយ ក៏កាលបរិច្ឆេទនៃការសងក៏មិនទាន់មកដល់ដែរ គឺនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ ឯណោះ។ ត្រង់ ចំណុចការអះអាងនេះ តុលាការយល់ឃើញថា ជាអះអាងមិនមានមូលដ្ឋានឡើយ ពីព្រោះថា ចុងចម្លើយបានខ្ចីប្រាក់ពី ដើមចោទនេះទៅប្រកបមុខរបរដាំម្រុំ។ ប៉ុន្តែ អាជីវកម្មនេះជាក់ស្តែងឃើញថា មិនដំណើររីកចម្រើនទៅមុខឡើយ ហើយធ្វើឱ្យមានហានិភ័យខ្ពស់ ដែលចុងចម្លើយពិតជាមិនអាចសងប្រាក់កម្ចីត្រឡប់ទៅឱ្យដើមចោទវិញបានឡើយ ដូច ដែលដើមចោទបានអះអាងដូចខាងលើនេះ។ ដូច្នេះ ដើមចោទមានសិទ្ធិរំលាយកិច្ចសន្យា និងទាមទារប្រាក់កម្ចីមកវិញ ដោយមិនរង់ចាំដល់ពេលកំណត់សងឡើយ ស្របទៅតាមក្រមរដ្ឋប្បវេណី។

៦. ឃើញថា អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានធ្វើសេចក្តីអះអាងថា ចុងចម្លើយមិនបានទទួលដំណឹងពីការ រំលាយកិច្ចសន្យាឡើយ។ ត្រង់អង្គហេតុនេះ តុលាការរកឃើញថា ចុងចម្លើយ ពិតជាបានទទួលការជូនដំណឹងពីការ រំលាយកិច្ចសន្យាកម្ចីប្រាក់ ដែលដើមចោទបានជូនដំណឹង ដូចមានបញ្ជាក់នៅក្នុងលិខិតជូនដំណឹង ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ អំពីការរំលាយកិច្ចសន្យាខ្ចីប្រាក់ ហើយចុងចម្លើយពិតជាបានទទួលដំណឹងនេះ នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៨ ដោយចុងចម្លើយបានចុះហត្ថលេខាទទួលលិខិតជូនដំណឹងនេះ។ ជាងនេះទៅទៀតតុលាការរកឃើញថា ចុងចម្លើយ បានទទួលដំណឹងអំពីការរំលាយកិច្ចសន្យាកម្ចីនេះ ជាបន្តបន្ទាប់ក្រោយៗមកទៀត។

៧. ឃើញថាដើមចោទបានទាមទារឱ្យចុងចម្លើយបង់ការប្រាក់ ៥ (ប្រាំ) ភាគរយ ក្នុងមួយឆ្នាំ តាមការកំណត់របស់ច្បាប់ ដោយគិតចាត់ពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ រហូតដល់ពេលសងរួច។ ត្រង់ចំណុចនៃការទាមទារនេះ តុលាការពិនិត្យ ឃើញថា នៅក្នុងកិច្ចសន្យាកម្ចីប្រាក់នោះ គឺមិនបានចែងអំពីបង់ការប្រាក់នោះទេ។ម្យ៉ាងទៀត តុលាការរកឃើញថា នៅពេលដែលធ្វើកិច្ចសន្យានោះ គូភាគីទាំងពីរគ្មានចេតនា និងឆន្ទៈ ពិតប្រាកដណាមួយឈោងទៅដល់បង់ការប្រាក់នោះ ទេ។ ដូច្នេះ តុលាការគួតប្បីច្រានចោលការទាមទាររបស់ដើមចោទ។

៨. ឃើញថាតាមការអះអាង និងការទាមទាររបស់ដើមចោទ ដែលបានទាមទារឱ្យចុងចម្លើយបង់ថ្លៃការខូចខាត សេវាកម្ម ច្បាប់ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក។ ចំពោះចំណុចនេះ តុលាការពិនិត្យ នឹងសម្រេចតាមអង្គហេតុ អង្គច្បាប់ និងការខូចខាតជាក់ស្តែង ដែលកើតមានឡើង។

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

៨. ឃើញថាចំពោះដើមចោទបានទាមទារឲ្យតុលាការប្រកាសសាលក្រមនេះ អនុវត្តជាបណ្ដោះអាសន្ននោះ តុលាការគប្បីច្រានចោលការទាមទារនេះ ដោយតុលាការយល់ឃើញថា ជៀសវាងភាពស្មុគស្មាញ នៃការធ្វើបដិទានឡើងវិញ ដែលអាចកើតឡើងនៅពេលក្រោយ។

## សេចក្ដីសម្រេចបញ្ចប់

១. បង្គាប់ឲ្យចុងចម្លើយឈ្មោះ ច សងប្រាក់កម្ចីចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លារអាមេរិក ឲ្យទៅដើមចោទឈ្មោះ ង ។

២. ច្រានចោលការទាមទារ បង់ការប្រាក់ចំនួន ០៥ (ប្រាំ) ភាគរយ ក្នុងមួយឆ្នាំ របស់ដើមចោទ។

៣. បង្គាប់ឲ្យចុងចម្លើយឈ្មោះ ច បង់ថ្លៃសំណងការខូចខាតចំនួន ២.០០០.០០០ (ពីរលាន) រៀល ឲ្យទៅដើមចោទឈ្មោះ ង ។ ការទាមទារលើសពីនេះច្រានចោល។

៤. ច្រានចោលការទាមទាររបស់ដើមចោទ ដែលសុំការប្រកាសសាលក្រមនេះ អនុវត្តជាបណ្ដោះអាសន្ន។

៥. ឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្ដី។

សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ ចំពោះមុខអ្នកតំណាងដោយអាណត្តិរបស់ដើមចោទ និងចុងចម្លើយ។

ថ្ងៃព្រហស្បតិ៍ ០៣កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩

**ចៅក្រម**

ហត្ថលេខា និងត្រា ៖ **ក្ងួយ សៅ**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ០៣កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

បានឃើញ

**ចៅក្រម**

ក្ងួយ សៅ

ផល សុភ័ក្ត្រ

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្ដីជាក់ស្ដែង ហើយមិនមែនជាសាលក្រមគម្រូទេ